- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាដីធ្លី នៅក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអប្សរា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលមាត្រា៤ និងមាត្រា៥នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយ ចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦៩/៦១៣ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា ៤ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលមាត្រា៤ និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពី

ការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"

- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីបុរីសណ្ឋាគារ
- បានឃើញអនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការពង្រីកផ្ទៃដីបុរីសណ្ឋាគារអង្គរសៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរា
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៥ ស្តីពីការកាត់ផ្ទៃដីទំហំសរុប ១១៥,៤១ ហិកតា ចេញពីផ្ទៃដីបុរីសណ្ឋាគារអង្គរសៀមរាប ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅក្រុងសៀមរាប ខេត្តសៀមរាប
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៥ ស្តីពីការកាត់ផ្ទៃដីទំហំសរុប ១១១,៤៩ ហិកតា ចេញពីផ្ទៃដីបុរីសណ្ឋាគារអង្គរសៀមរាប ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅក្រុងសៀមរាប ខេត្តសៀមរាប
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាដីធ្លីនៅក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអប្សរា ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | អនុប្រធាន |
| ៣- អគ្គនាយកអាជ្ញាធរអប្សរា | អនុប្រធាន |
| ៤- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧- តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ៨- មេធាវីរាជរដ្ឋាភិបាល | សមាជិក |
| ៩- ស្នងការនៃស្នងការដ្ឋាននគរបាលខេត្ត | សមាជិក |
| ១០- មេបញ្ជាការនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត | សមាជិក |
| ១១- មេបញ្ជាការនៃបញ្ជាការដ្ឋានសឹករងខេត្ត | សមាជិក |
| ១២- មេធាវីអាជ្ញាធរអប្សរា | សមាជិក |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការនេះ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា ២ .-**

គណៈកម្មាធិការនេះ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំការពិគ្រោះយោបល់លើការងារដោះស្រាយបញ្ហាដីធ្លីនៅក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអប្សរា

- លើកយោបល់ជូនរាជរដ្ឋាភិបាលអំពីគោលនយោបាយ ផែនការសកម្មភាព នីតិវិធី និងវិធានការណ៍ពាក់ព័ន្ធ សម្រាប់ការអនុវត្តការងារនេះឱ្យបានជោគជ័យ
- ដឹកនាំការអនុវត្តគោលនយោបាយដែលបានដាក់ចេញឱ្យមានប្រសិទ្ធភាពខ្ពស់
- ត្រួតពិនិត្យនិងផ្តល់អនុសាសន៍ក្នុងការអនុវត្តគោលនយោបាយនេះ
- ជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីគោលនយោបាយ នីតិវិធី និងវិធានការណ៍ពាក់ព័ន្ធ ដើម្បីឱ្យប្រជាពលរដ្ឋចូលរួមអនុវត្តឱ្យបានជោគជ័យ
- កៀរគរប្រភពហិរញ្ញវត្ថុផ្សេងៗសម្រាប់អនុវត្តការងារនេះ
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រមុខរាជរដ្ឋាភិបាល។

**មាត្រា ៣ .-**

គណៈកម្មាធិការតម្រង់ទិសមានគណៈកម្មាធិការប្រតិបត្តិ ជាសេនាធិការ។ គណៈកម្មាធិការប្រតិបត្តិ ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ៤ .-**

គណៈកម្មាធិការតម្រង់ទិស មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបំពេញការងាររបស់ខ្លួន។

**មាត្រា ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***អន្លែងទទួល៖***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៦៧...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង សម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

ព្រះរាជាណាចក្រកម្ពុជា ទីស្តីការគណៈរដ្ឋមន្ត្រី

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥។ គណៈកម្មការនេះសរសេរជាអក្សរកាត់ថា "**គ.អ.ម.ក.**"។

**មាត្រា២ ._**

គណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ មានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| ១- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | អនុប្រធាន |
| ៣- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| ៤- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| ៥- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| ៦- រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ១រូប | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១រូប | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| ៩- អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | សមាជិក |
| ១០- អនុរដ្ឋលេខាធិការក្រសួងផែនការ | ១រូប | សមាជិក |
| ១១- អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ១រូប | សមាជិក |
| ១២- អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | សមាជិក |
| ១៣- អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១រូប | សមាជិក |
| ១៤- អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | ១រូប | សមាជិក |
| ១៥- តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១រូប | សមាជិក |
| ១៦- តំណាងក្រុមប្រឹក្សាអ្នកច្បាប់ | ១រូប | សមាជិក |
| ១៧- តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | ១រូប | សមាជិក |
| ១៨- តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១រូប | សមាជិក |
| ១៩- អគ្គលេខាធិការរងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | ១រូប | សមាជិក |
| ២០- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១រូប | សមាជិក |
| ២១- អគ្គនាយកនៃធនាគារជាតិនៃកម្ពុជា | ១រូប | សមាជិក |
| ២២- អគ្គនាយកនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១រូប | សមាជិក |

| | | |
|---|---|---|
| ២៣- អគ្គនាយកនៃក្រសួងអភិវឌ្ឍន៍ជនបទ | ១រូប | សមាជិក |
| ២៤- អគ្គនាយកនៃក្រសួងរ៉ែនិងថាមពល | ១រូប | សមាជិក |
| ២៥- ប្រធានទីភ្នាក់ងារជាតិមុខរបរនិងការងារ | | សមាជិក |
| ២៦- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | | សមាជិក។ |

**គ.អ.ម.ក.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ សមាគមនិយោជក សហជីព អង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានាចូលរួមផ្តល់យោបល់តាមការចាំបាច់។

## ជំពូកទី២
## ភារកិច្ចរបស់ គ.អ.ម.ក.

**មាត្រា៣ ._**

**គ.អ.ម.ក.** មានភារកិច្ចដូចតទៅ៖

- ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥
- រៀបចំផែនការអនុវត្តវិធានការនីមួយៗនៃគោលនយោបាយ ដោយមានកំណត់ពេលវេលាជាក់លាក់
- លើកសំណើនិងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល ដើម្បីធ្វើការសម្រេចចិត្តក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះមុខដែលបានកើតឡើងនៅក្នុងពេលអនុវត្ត
- រៀបចំផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាព
- សហការជាមួយអង្គការអន្តរជាតិខាងការងារនិងដៃគូអភិវឌ្ឍនានា ដើម្បីកៀរគរជំនួយបច្ចេកទេសនិងថវិកាសម្រាប់ការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឱ្យកាន់តែមានប្រសិទ្ធភាព
- កែសម្រួលនិងធ្វើបច្ចុប្បន្នកម្មគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ តាមពេលវេលានិងការចាំបាច់
- សម្របសម្រួលដំណើរការពិគ្រោះយោបល់នានា ទាំងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិទាក់ទងនឹងការអនុវត្តគោលនយោបាយជាតិស្តីមុខរបរនិងការងារ
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាលស្តីពីវឌ្ឍនភាពនិងបញ្ហាប្រឈមនៅក្នុងការអនុវត្ត ដោយផ្អែកលើគោលដៅនិងសូចនាករដែលបានកំណត់ក្នុងគោលនយោបាយ។

## ជំពូកទី៣
## ដំណើរការរបស់ គ.អ.ម.ក.

**មាត្រា៤ ._**

អនុប្រធាននិងសមាជិក **គ.អ.ម.ក.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.អ.ម.ក.**។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធានអាចកោះអញ្ជើញនិងដឹកនាំការប្រជុំជំនួសតាមការប្រគល់សិទ្ធិពីប្រធាន។

ក្នុងករណីអវត្តមានឬមានធុរៈមិនអាចចូលរួមប្រជុំបាន អនុប្រធានឬសមាជិក **គ.អ.ម.ក.** ត្រូវចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចចូលរួមប្រជុំជំនួស។

**មាត្រា៥ ._**

**គ.អ.ម.ក.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈសម្រាប់ដំណើរការការងារ។

**មាត្រា៦ ._**

**គ.អ.ម.ក.** មានអនុគណៈកម្មការអន្តរក្រសួងចំនួន៣និងគណៈកម្មការរាជធានី ខេត្តៈ

១- អនុគណៈកម្មការបង្កើនឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់។

២- អនុគណៈកម្មការលើកកម្ពស់ការអភិវឌ្ឍជំនាញនិងធនធានមនុស្ស។

៣- អនុគណៈកម្មការពង្រឹងអភិបាលកិច្ចទីផ្សារការងារ។

៤- គណៈកម្មការរាជធានី ខេត្ត។

អនុគណៈកម្មការទាំង៣ ត្រូវបានបង្កើតឡើងដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.អ.ម.ក.** ដែលមានសមាសភាពក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធជាសមាជិកតាមការចាំបាច់។

អនុគណៈកម្មការនីមួយៗនិងគណៈកម្មការរាជធានី ខេត្ត អាចអញ្ជើញតំណាងនិយោជក សហជីព អង្គការជាតិ និងអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា ចូលរួមផ្ដល់យោបល់តាមការកំណត់។

**មាត្រា៧ ._**

**គ.អ.ម.ក.** មានលេខាធិការដ្ឋានមួយសម្រាប់សម្របសម្រួលដំណើរការអនុវត្ត ដោយមានអគ្គនាយកនៃអគ្គនាយកដ្ឋានការងារជាប្រធានលេខាធិការដ្ឋាន។ លេខាធិការដ្ឋាននៃ **គ.អ.ម.ក.** ត្រូវបានបង្កើតឡើងដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.អ.ម.ក.**។

**មាត្រា៨ ._**

គណៈកម្មការរាជធានី ខេត្ត ត្រូវបានបង្កើតឡើងដោយសេចក្ដីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលមានតំណាងមន្ទីរនិងអង្គភាពពាក់ព័ន្ធជាសមាជិកតាមការចាំបាច់។ គណៈកម្មការរាជធានី ខេត្ត ត្រូវបានកំណត់ឱ្យប្រើប្រាស់ត្រារបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ដំណើរការការងារ។

គណៈកម្មការរាជធានី ខេត្ត មានលេខាធិការដ្ឋានមួយសម្រាប់សម្របសម្រួលដំណើរការ ដោយមានប្រធានមន្ទីរការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានី ខេត្ត ជាប្រធាន។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៩ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩៤ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០២៦ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦
- បានឃើញប្រកាសលេខ ១៨២៧ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦
- បានឃើញប្រកាសលេខ ១៨២៨ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាកម្មវិធីថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាពីជំពូក ៦៥ (ឧបត្ថម្ភកធន) ចំនួន ១ ៤០៤ ៦០០ ០០០រៀល (មួយប៊ីលាន បួនរយបួនលានប្រាំមួយរយពាន់រៀលគត់) មកជំពូក ៦០ (ការទិញ) ចំនួន ៣៧៥ ០០០ ០០០រៀល (បីរយចិតសិបប្រាំលានរៀលគត់) និងជំពូក ៦១ (សេវាកម្ម)ចំនួន ១ ០២៩ ៦០០ ០០០រៀល (មួយប៊ីលានម្ភៃប្រាំបួនលានប្រាំមួយពាន់រៀលគត់) ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៧៦ អនក្រ.បក

**អនុក្រឹត្យ**
**ស្ដីពី**
**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១៩៧ ៩០០ ០០០ រៀល (មួយរយកៅសិបប្រាំពីរលានប្រាំបួនរយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងព័ត៌មាន សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ចំណាយរៀបចំពិធីជួបជុំគ្នារវាងអ្នកសារព័ត៌មានអាជីព នៃបណ្តាប្រទេសអាស៊ានរយៈពេល ០៣ថ្ងៃ នៅព្រះរាជាណាចក្រកម្ពុជាចាប់ពីថ្ងៃទី ២៩ ដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨៦ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**<u>សម្រេច</u>**

**មាត្រា១.—**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៣០០ ០០០ ០០០ រៀល (បីរយលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦០ (ការទិញ) ចំនួន ២១០ ០០០ ០០០ រៀល និងជំពូក ៦១ (សេវាកម្ម) ចំនួន ៩០ ០០០ ០០០ រៀល ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២.—**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្តល់ជូនឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សម្រាប់ជួសជុល និងបំពាក់គ្រឿងសង្ហារឹមនៅក្នុងអគារ នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ។

**មាត្រា៣.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៣ ៧២២ ២០០ ០០០ រៀល (បីប៊ីលានប្រាំពីររយម្ភៃពីរលានពីររយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភកធន) ជូនទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្តល់ជូនរាជបណ្ឌិត្យសភាកម្ពុជា សម្រាប់គាំទ្រដល់គម្រោងស្រាវជ្រាវទាំងអស់ រួមទាំងគម្រោងស្រាវជ្រាវសង្ខេបទាំង ៤៤ ចំនួន ៣ ០០០លានរៀល, ឧបត្ថម្ភមន្ត្រីលេខាធិការដ្ឋានចំនួន ២១៤,៨លានរៀល, ទិញសម្ភារៈការិយាល័យ និងសម្ភារៈ IT ចំនួន ៣៤៣,៤ លានរៀល, និងរថយន្ត ០១គ្រឿង ចំនួន ១៦៤លានរៀល។

**មាត្រា៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៤១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧ្ងារ **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

## សម្រេច

**មាត្រា១:** បំពាក់គ្រឿងឥស្សរិយយស និងមេដាយមាសការងារ ជូនអ្នកបច្ចេកទេសប៉ូឡូញ និងសិល្បករគំនូរបុរាណកម្ពុជា ចំនួន ៣៩រូប ដែលមានស្នាដៃល្អក្នុងការពង្រឹងជញ្ជាំងថៃវ និងជួសជុលគំនូរបុរាណនៅតាមជញ្ជាំងថៃវជុំវិញព្រះវិហារព្រះកែវមរកត ព្រះបរមរាជវាំង ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦:

**ក- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:**

១- ឯកឧត្តម **ហ៊ី សាម៉ន**    ២- ទេពនិម្មិតវិចិត្រ **ជេត ចន**

**ខ- គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ ធិបឌិន្ទ:**

១- លោកបណ្ឌិត Solida Lim    ២- លោកស្រី Lim Anna Malgorzata

**គ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

១- លោកស្រី **ឈុន ស៊ីណា**    ២- លោកស្រី **ម៉ក់ សោភ័ន**

៣- លោកស្រី **មិញ ញើក**    ៤- លោកស្រី **អាន សំភាជន៍**

៥- លោកស្រី **ឈុន សុខា**

**ឃ- គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ សេនា:**

១- កញ្ញា Gursztyn Malgorzata    ២- កញ្ញា Dyniec Magdalena Ewa

**ង- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:**

១- កញ្ញា **រឿង ស្រីណា**
២- លោក **កែវ គឿន**
៣- លោក **ឃុំ ផាន់ណារ៉ា**
៤- លោក **ព្រំ ផាន់ណា**
៥- លោកស្រី **ឡុច ស៊ុនហ៊ីឈ្ហន៍**
៦- លោក **ជួន រី**

**ច- គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ អស្សឫទ្ធិ:**

១- កញ្ញា Chenc Agnieszka
២- កញ្ញា Radzimska Milena Sandra
៣- កញ្ញា Mindykowska Patrycja
៤- កញ្ញា Klaudia Elzbieta Rajmann
៥- កញ្ញា Paula karina Swituszak
៦- កញ្ញា Agata Malgorzata Rychlicka
៧- កញ្ញា Maja Ewa Rogowska
៨- លោក Andrzej Lukasz Skora
៩- លោក Pawlowicz Cezary Andrzej
១០- លោក Dariusz Mieczyslaw Glapinski
១១- លោក Chomik Zbigniew Jerzy
១២- លោក Lopat Ryszard Marian
១៣- លោក Pawlowicz Marek
១៤- លោក Dabrowski Benedykt

**ឆ- មេដាយមាសការងារ:**

១- លោក **ហ៊ុន ចំរើន**
២- លោក **សួន សារិទ្ធ**
៣- លោក **សាំង ចិសុទ្ធ**
៤- លោក **អោក ភេខ**
៥- លោកអាចារ្យ **រី**
៦- លោក **លុយ ដា**
៧- លោក **នោម ណៃត**
៨- លោក **ឯម ពៅ**

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អប្រសើរ។

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៥៤៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា ១ .-** តែងតាំង លោក **សេខ សុវណ្ណរ័ត្ននា** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជំនួសលោក **សេង ឡុត** ដែលបានទទួលភារកិច្ចថ្មី។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៥៤៣...អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាអគ្គនាយករង និងអធិការ នៅក្រសួងទេសចរណ៍ ដូចមានរាយនាមខាងក្រោម ៖

១- លោក **សំ ឧុទ្ធា** ជាអគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ

២- លោក **ទូ សុផល** ជាអធិការ នៃអគ្គាធិការដ្ឋាន ជំនួសលោក **សំ វុទ្ធា** ដែលបានទទួលភារកិច្ចថ្មី។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៥៤៤...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតក្របខ័ណ្ឌមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ប្តូរប្រភេទក្របខ័ណ្ឌតាមលទ្ធផលប្រឡងប្រជែងផ្ទៃក្នុង និងធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ថ្មី ជូនមន្ត្រីរាជការ ចំនួន **១១៤** រូប ទៅក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម នៅក្រសួងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១- លោក **មាស ឡុន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៤<br>មកមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ៤ |
| ២- លោកស្រី **ពៅ ធីតា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៤<br>មកមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ៤ |
| ៣- លោក **រស់ លឿន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៨<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៤- លោក **ហែម ចណ្ណា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៨<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៥- លោកស្រី **ឡុន ផល្លា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៦- លោកស្រី **អ៊ួច អេង** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៧- លោកស្រី **ង៉េះ សាម៉េត** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៨- លោកស្រី **ច័ន ចល័ក្ខ** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៩- លោក **មឿង តារិន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ១០- លោក **ម៉ែន ព្រឹក** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ១១- លោក **ឆាយ ជួងវិបុល** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ១២- លោក **ជី រតនា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ១៣- លោក **ហ៊ាត់ សុវណ្ណា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ១៤- លោក **ខេង ប៊ុនណាត** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |

១៥- លោកស្រី **ប៉ុក បូវត្ថា** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១៦- លោក **ផេង សារ៉ុម** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១៧- លោកស្រី **ឃិន សុវត្ថា** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១៨- លោកស្រី **ណុប សុខុម** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១៩- លោក **កែវ វី** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

២០- លោកស្រី **គង់ សុផា** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

២១- លោក **សេង វណ្ណា** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

២២- លោកស្រី **រ៉ិត សុជាតិ** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

២៣- លោក **ហ៊ូ ចាន់ស៊ីថុន** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

២៤- លោក **ប៉ុក វីរៈ** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

២៥- លោកស្រី **ជា ចាន់ធារី** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

២៦- លោក **ឡុង គីម៉េង** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

២៧- លោក **ស៊ុំ សុវណ្ណា** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

២៨- លោកស្រី **ហ៊ុន ឃីម** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

២៩- លោកស្រី **អ៊ុម មុនី** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៣០- លោក **ឡា គីមលីន** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៣១- លោក **មុំ ដារ៉ា** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៣២- លោក **ស្ងួន ឡូត** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៣៣- លោក **ទៀង ហ៊ីល្លីណា** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៣៤- លោក **គង់ សុខឡាង** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៣៥- លោក **លឹម គឹមឡុង** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៣៦- លោក **ស្ងួន សុខុម** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យមថ្នាក់លេខ ៤

៣៧- លោក **ហុង ហេង** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៣៨- លោក **នៅ អេងហៃ** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៣៩- លោក **ឈឹន ចន្ធី** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៤០- លោក **តិប សុធី** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៤១- លោក **ឈួត ថាន** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៤២- លោកស្រី **គយ សុខុម** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៤៣- លោក **ចាន់ សុវណ្ណា** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៤៤- លោកស្រី **ម៉ៅ ម៉ាលី** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៤៥- លោក **អ៊ុច ម៉ឺន** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៤៦- លោកស្រី **ម៉ៅ សុវត្ថារី** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

| | |
|---|---|
| ៤៧- លោកស្រី **យឹម សាវ៉ាត់** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៤៨- លោកស្រី **អ៊ិន សុនី** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៤៩- លោក **យ៉ុន ឈុនប៉ា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៥០- លោកស្រី **លី យ៉ាន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៥១- លោក **ប៊ុក រ៉ែន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៥២- លោក **អ៊ូច តីរម្យ** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៥៣- លោកស្រី **ស្វាយ សិដ្ឋា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៥៤- លោក **ណឹម សុខា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៥៥- លោក **ប៊ិន សុខ** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៥៦- លោក **ឡោះ សាវុធ** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៥៧- លោកស្រី **ផាង ស៊ីសុភា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៥៨- លោកស្រី **ទឹម គឹមលាង** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៥៩- លោក **មាស សេត** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៦០- លោក **សៅ វណ្ណា:** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៦១- លោក **សោម ទើន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៦២- លោក **ឈឹម សារុន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |

| | |
|---|---|
| ៦៣- លោក **យ៉ាន ច័ន្ទថា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៦៤- លោក **សឿន សៅវុទ្ធី** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៦៥- លោក **ផៃ ខៃ** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៦៦- លោក **ពិន ចាន់ណា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៦៧- លោក **អ៊ុំ សុខ** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៦៨- លោកស្រី **អ៊ុន ឡុន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៦៩- លោក **យី ធឿន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៧០- លោក **ទុំ រ៉ូ** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៧១- លោក **ភួច ប៊ុណ្ណា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៧២- លោក **ហ៊ី ហាប់** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៧៣- លោកស្រី **ម៊ុន ផល្លីន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៧៤- លោក **យ៉េម អួន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៧៥- លោក **ភឹម សុខា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៧៦- លោក **ជៀម សារិត** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៧៧- លោក **សែម រឿន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៧៨- លោក **ខាំ ប៉ៃសាំង** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |

| | |
|---|---|
| ៧៩- លោក **ស្រី ជុំ** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៨០- លោក **ឡឹក សានិល** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៨១- លោក **ពុត លឿម** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៨២- លោក **សេង ម៉ុនថា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៨៣- លោកស្រី **ព្រំ សុភាព** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៨៤- លោក **ម៉ាន់ ចែម** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៨៥- លោកស្រី **ហួត ពិសី** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៨៦- លោកស្រី **ម៉ុន ផន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៨៧- លោក **សំ ផល្លី** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៨៨- លោក **សៅ ធីតា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៨៩- លោក **សំរិត សាតា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៩០- លោក **តូច សេង** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៩១- លោក **មាស ម៉ានី** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៩២- លោកស្រី **សូ ម៉ាឡា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៩៣- លោក **មោង ឆាំ** | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៩<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ៩៤- លោក **អ៊ុក សំអុល** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |

៩៥- លោកស្រី **គង់ វណ្ណា** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៩៦- លោក **ភង សុវណ្ណារ៉ា** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៩៧- លោក **ជុំ ណុប** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៩៨- លោក **លី សុវណ្ណារិទ្ធិ** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

៩៩- លោក **យូ សេង** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១០០- លោក **ទឹម សំអុល** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១០១- លោក **ជិន អឿង** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១០២- លោក **នូ មាន** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១០៣- លោក **ជា រដ្ឋា** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១០៤- លោក **ហ៊ុន ឆារ៉ា** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១០៥- លោកស្រី **នុត ណារី** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១០៦- លោក **ឯក សារី** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១០៧- លោកស្រី **ជុំ សារ៉ែម** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១០៨- លោក **ម៉ុង ម៉ន** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១០៩- លោកស្រី **ម៉ៃ សុធី** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

១១០- លោក **ជួន អេន** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០
មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤

| | |
|---|---|
| ១១១- លោក **មិន ស៊ីន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ១១២- លោកស្រី **ហុង ថាវី** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ១១៣- លោក **អ៊ុក បុប្ផាផល្លា** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |
| ១១៤- លោក **ឌុល ឌុធ** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០<br>មកមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៤ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា **២***
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៥៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រឹតលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

## សម្រេច

**មាត្រា ១.-**

ផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន ០២រូប នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម **ម៉ិន រដ្ឋា** ពីនាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ទៅជានាយកអាកាសយានដ្ឋានអន្តរជាតិសៀមរាប។

២- ឯកឧត្តម **និត្យ វណ្ណា** ពីនាយកអាកាសយានដ្ឋានអន្តរជាតិសៀមរាប ទៅជានាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នដែលពាក់ពន្ធ័ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៥៤៧...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ដាក់មន្ត្រីរាជការចំនួន ១៨ រូប របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ | ថ្ងៃខែឆ្នាំចូលនិវត្តន៍ |
|---|---|---|---|
| ១ | លោក ហាំង នុបុត្រ | វរមន្ត្រី ថ្នាក់លេខ ២ | ១២/០១/២០១៥ |
| ២ | លោកស្រី ប៊ូ ប៊ុនថាច | វរមន្ត្រី ថ្នាក់លេខ ២ | ២០/០២/២០១៥ |

| | | | |
|---|---|---|---|
| ៣ | លោក សំ ផន | វរមន្ត្រី ថ្នាក់លេខ ៣ | ០៧/០៣/២០១៥ |
| ៤ | លោក កៅ ចំរើន | វរមន្ត្រី ថ្នាក់លេខ ៣ | ៣០/០៣/២០១៥ |
| ៥ | លោក អ៊ុយ កុសល | វរមន្ត្រី ថ្នាក់លេខ ៤ | ០៥/០៤/២០១៥ |
| ៦ | លោក ចាន់ ធី | វរមន្ត្រី ថ្នាក់លេខ ៣ | ២៥/០៥/២០១៥ |
| ៧ | លោក កែវ សុខាន់ | វរមន្ត្រី ថ្នាក់លេខ ៤ | ១០/០៥/២០១៥ |
| ៨ | លោក អ៊ុយ សារិន | វរមន្ត្រី ថ្នាក់លេខ ១ | ១៥/០៥/២០១៥ |
| ៩ | លោក ចាន់ ហឿន | វរមន្ត្រី ថ្នាក់លេខ ២ | ១៧/០៦/២០១៥ |
| ១០ | លោក ជូ ស្រ៊ុន | វរមន្ត្រី ថ្នាក់លេខ ៣ | ០៥/០៨/២០១៥ |
| ១១ | លោក ស៊ិន សម្ផល្ល | វរមន្ត្រី ថ្នាក់លេខ ៣ | ២៧/០៨/២០១៥ |
| ១២ | លោក ជា ហាក់ | វរមន្ត្រី ថ្នាក់លេខ ៣ | ១៨/០៩/២០១៥ |
| ១៣ | លោក ស៊ិន ណុយ | វរមន្ត្រី ថ្នាក់លេខ ១ | ១០/១០/២០១៥ |
| ១៤ | លោក អ៊ុក សកុណា | វរមន្ត្រី ថ្នាក់លេខ ៣ | ១១/១០/២០១៥ |
| ១៥ | លោក កាំង សួង | វរមន្ត្រី ថ្នាក់លេខ ២ | ២៥/១០/២០១៥ |
| ១៦ | លោក ទេព សារី | វរមន្ត្រី ថ្នាក់លេខ ២ | ០៨/១២/២០១៥ |
| ១៧ | លោកស្រី សរ គីមលី | វរមន្ត្រី ថ្នាក់លេខ ២ | ១០/១២/២០១៥ |
| ១៨ | លោក ជា សំបូរ | វរមន្ត្រី ថ្នាក់លេខ ៤ | ១១/១២/២០១៥ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...[illegible]...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៩/៨៣៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ស្តីពីលក្ខន្តិកៈដោយឡែកក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់ អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ

## សម្រេច

**មាត្រា ១** : ដំឡើងថ្នាក់ប្រចាំឆ្នាំ ជូនមន្ត្រីរាជការចំនួន ៣៦ (សាមសិបប្រាំមួយ) រូប ក្នុងឋានន្តរស័ក្តិសវនករដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម របស់អាជ្ញាធរសវនកម្មជាតិ ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៦ តទៅ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក ឆាយ នព្វគុណា | ពីសវនករដើមខ្សែ ថ្នាក់លេខ២ | មកសវនករដើមខ្សែ ថ្នាក់លេខ១ |
| ២- | លោក មាស ថាវ | ពីសវនករដើមខ្សែ ថ្នាក់លេខ២ | មកសវនករដើមខ្សែ ថ្នាក់លេខ១ |
| ៣- | លោក ចាន់ សារឹម | ពីសវនករដើមខ្សែ ថ្នាក់លេខ២ | មកសវនករដើមខ្សែ ថ្នាក់លេខ១ |
| ៤- | លោក ថន សុខាឫទ្ធិ | ពីសវនករដើមខ្សែ ថ្នាក់លេខ២ | មកសវនករដើមខ្សែ ថ្នាក់លេខ១ |
| ៥- | លោក តាន់ ប៊ុនវីរៈ | ពីសវនករដើមខ្សែ ថ្នាក់លេខ២ | មកសវនករដើមខ្សែ ថ្នាក់លេខ១ |
| ៦- | ឯកឧត្តម គឹម សុផល | ពីសវនករដើមខ្សែ ថ្នាក់លេខ៣ | មកសវនករដើមខ្សែ ថ្នាក់លេខ២ |

៧- ឯកឧត្តមព្រហ្ម វិចិត្រសុភ័ណ្ឌ ពីសវនករដើមខ្មែរថ្នាក់លេខ៣មកសវនករដើមខ្មែរ ថ្នាក់លេខ២
៨- លោក ឃឹម សេរីវឌ្ឍា ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
៩- លោក លី យ៉ារ៉េត ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
១០- លោក សោម សុធារ៉ា ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
១១- លោក ជា គឹមរ៉ាន្នី ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
១២- លោក ខូ ដាលីតូ ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
១៣- លោក ហាស់ ពណ្ណរិទ្ធ ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
១៤- លោក គង់ សុវណ្ណដារ៉ា ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
១៥- លោក ហេង ការ៉ូ ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
១៦- លោក ប៉ា សុផារ័ត្ន ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
១៧- លោកស្រី សុខ សុផល ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
១៨- លោកស្រី ងួន សុក្រពុំ ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
១៩- លោក ឆែម សុជាតិ ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើអខ្មែរ ថ្នាក់លេខ២
២០- លោក ស្ងួន សុធី ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
២១- លោក ហុក សឿន ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
២២- លោក សេក កុសាក់ ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
២៣- លោក អ៊ឹម សម្បត្តិ ពីសវនករដើមខ្មែរ ថ្នាក់លេខ៣ មកសវនករដើមខ្មែរ ថ្នាក់លេខ២
២៤- លោក អ៊ឹង សុខឆាយ ពីសវនករដើមខ្មែរ ថ្នាក់លេខ៤ មកសវនករដើមខ្មែរ ថ្នាក់លេខ៣
២៥- លោក រីន ចាន់ទ្រា ពីសវនករដើមខ្មែរ ថ្នាក់លេខ៤ មកសវនករដើមខ្មែរ ថ្នាក់លេខ៣
២៦- លោក ដួង កណ្ណារ៉ា ពីសវនករដើមខ្មែរ ថ្នាក់លេខ៤ មកសវនករដើមខ្មែរ ថ្នាក់លេខ៣
២៧- លោក ស ពិសិដ្ឋ ពីសវនករដើមខ្មែរ ថ្នាក់លេខ៤ មកសវនករដើមខ្មែរ ថ្នាក់លេខ៣
២៨- លោក រុន វីរៈ ពីសវនករដើមខ្មែរ ថ្នាក់លេខ៤ មកសវនករដើមខ្មែរ ថ្នាក់លេខ៣
២៩- លោក ហុក សុភក្តិ ពីសវនករដើមខ្មែរ ថ្នាក់លេខ៤ មកសវនករដើមខ្មែរ ថ្នាក់លេខ៣
៣០- លោក រ៉ា បូរីទ្ធ ពីសវនករដើមខ្មែរ ថ្នាក់លេខ៤ មកសវនករដើមខ្មែរ ថ្នាក់លេខ៣
៣១- លោក ជិន ហេមវិចិត្រ ពីសវនករដើមខ្មែរ ថ្នាក់លេខ៤ មកសវនករដើមខ្មែរ ថ្នាក់លេខ៣
៣២- លោក ឡាយ សិរីពង្ស ពីសវនករដើមខ្មែរ ថ្នាក់លេខ៤ មកសវនករដើមខ្មែរ ថ្នាក់លេខ៣
៣៣- លោក ឯម សុភាសមេសា ពីសវនករដើមខ្មែរ ថ្នាក់លេខ៤ មកសវនករដើមខ្មែរ ថ្នាក់លេខ៣
៣៤- លោក អ៊ា សុវណ្ណារី ពីសវនករដើមខ្មែរ ថ្នាក់លេខ៤ មកសវនករដើមខ្មែរ ថ្នាក់លេខ៣
៣៥- លោក ស៊ឹម សុផាន់ណា ពីសវនករដើមខ្មែរ ថ្នាក់លេខ៤ មកសវនករដើមខ្មែរ ថ្នាក់លេខ៣
៣៦- លោកស្រី គឹម រ៉ាន់ធី ពីសវនករដើមខ្មែរ ថ្នាក់លេខ៤ មកសវនករដើមខ្មែរ ថ្នាក់លេខ៣

**មាត្រា ២** : ដំឡើងឋានន្តរស័ក្តិ ជូនមន្ត្រីរាជការចំនួន ៧០ (ចិតសិប) រូប ពីឋានន្តរស័ក្តិសវនករ មកឋានន្តរស័ក្តិសវនករដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម របស់អាជ្ញាធរសវនកម្មជាតិ ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១- លោកស្រី អ៊ុំ សាម៉ាដែត | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ២- លោកស្រី ហេង បូធីតា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៣- លោក ជី វណ្ណឌី | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៤- លោក សិទ្ធី បញ្ញាឫទ្ធិ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៥- លោក ឡោក ជំនាញ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៦- លោកស្រី នង សុភា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៧- លោក ហេង ចាន់ថន | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៨- លោក សាន វិសាល | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៩- លោកស្រី អៀន សាអ៊ីម | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ១០-លោក ប៉ាន់ ពិសី | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ១១-លោក ជ័យ ប៊ុនធឿន | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ១២-លោកស្រី ពៅ ស្រីសោភា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ១៣-លោក លឹម ប៊ុនសុភ័ក្រ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ១៤- លោក ធម្ម ប៊ុណ្ណារីនេ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ១៥- លោក សេង ធីរិទ្ធ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ១៦- លោក វេង វិសាល | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ១៧- លោក វង្ស វិចិត្រ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ១៨- លោក សុខ ធារ៉ា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ១៩- លោកស្រី អាយ កុសមា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ២០- លោក លុយ សុភារី | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ២១- លោក ហេង ស៊ុនតារា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ២២- លោក ហាស់ វិចិត្រ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ២៣-លោក ឆាយ វណ្ណវិសិទ្ធិ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ២៤- លោក អៀច សុវណ្ណច័ន្ទត្រា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ២៥- លោក ឯន តុងហ៊ាង | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ២៦- លោកស្រី ប៉ុល សុផល | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |

| | | |
|---|---|---|
| ២៧- លោក ប៉ែន ច័ន្ទរិទ្ធី | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ២៨- លោក ជួង សុធារតន៍ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ២៩- លោកស្រី យុន ពិដោរ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៣០- លោក ឈូក សុខសាន្ត | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៣១- លោក ណុប ស៊ីណា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៣២- លោក ទៃ ចំរើន | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៣៣- លោក ថាម សុខគង់ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៣៤- លោកស្រី អ៊ុំ រស្មី | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៣៥- លោក នាក់ រចនា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៣៦- លោកស្រី ប៊ុន ស៊ីណែត | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៣៧- លោកស្រី កូវ សុភា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៣៨- លោក ឌឹម បូរ៉ា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៣៩- លោកស្រី ឈីវ រដ្ឋា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៤០- លោកស្រី ថេត ថារី | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៤១- លោក ប៉ា សុផារី | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៤២- លោកជំទាវ ម៉ម រមនា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៤៣- លោក ហ វ៉ាន់ដា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៤៤- លោក អ៊ឹង សំបូរ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៤៥- កញ្ញា នុត ធារី | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៤៦- លោក ថូយ សុភ័ក្ត្រ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៤៧- លោក ម៉ាន់ ទីវ័ន្ត | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៤៨- លោក យ៉ែម ភូរិន្ទ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៤៩- លោក លឹម ឡងឌី | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៥០- លោក លី សុងហ្សួរ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៥១- លោក លឹម សេង | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៥២- លោក វ៉ែន វីរៈ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៥៣- លោក អ៊ុក ស៊ីឌីន | ពីសវនករ ថ្នាក់លេខ១ | មកសវនក៍រដើមខ្សែ ថ្នាក់លេខ៤ |
| ៥៤- លោក ហែម វិមល | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៥៥- លោក ប្រាជ្ញ ឈៀងលី | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |

| | | |
|---|---|---|
| ៥៦- លោក មាន ច័ន្ទណារិទ្ធ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៥៧- លោកស្រី ប៉ុម ឌីម៉ានិត | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៥៨- លោក កៅ ទិវា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៥៩- លោក អ៊ឹង សំអាន | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៦០- លោកស្រី វ៉ាន់ ធានី | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៦១- លោក សូណា សាន់ដេ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៦២- លោក ខន ដានេត | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៦៣- លោក សេង កុសល | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៦៤- លោក សុខ វីរៈ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៦៥- លោកស្រី យ៉េត ម៉ូលិះ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៦៦- លោក កុយ មករា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៦៧- លោក ហ៊ឹម សុគន្ធា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៦៨- លោកស្រី ហ៊ាង សុជាតា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៦៩- លោក អ៊ុក វីរៈ | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |
| ៧០- លោក ប៉ែន ដាណា | ពីសវនករ ថ្នាក់លេខ១ | មកសវនករដើមខ្សែ ថ្នាក់លេខ៤ |

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចចែងក្នុងមាត្រា១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ....៥៤៩...អនក្រ-បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិ នាយទាហាន

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិថ្នាក់ វរសេនីយ៍ឯក នាយទាហាននៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមៈ

១-វរសេនីយ៍ទោ **ពៅ ចាន់រិទ្ធ** អត្តលេខ ០២៣៣៨៧ ជំនួយការ ឯកឧត្តម មេបញ្ជាការ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

២-វរសេនីយ៍ទោ **តូច សារឿន** អត្តលេខ ០០៥០២៦ ជំនួយការ ឯកឧត្តម មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៣-វរសេនីយ៍ទោ **ខួន ម៉ា** អត្តលេខ ០៤៥៣២២ ជំនួយការ ឯកឧត្តម មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤-វរសេនីយ៍ទោ **ហ៊ឹម តារុណា** អត្តលេខ ០២៣៣២៣ នាយរងការិយាល័យសុខាភិបាល បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៥-វរសេនីយ៍ទោ **គឹម សុខាល័យ** អត្តលេខ ០១២៧៤១ មេបញ្ជាការរង បញ្ជាការដ្ឋានរដ្ឋបាល បញ្ជាការដ្ឋាន កងរាជអាវុធហត្ថលើផ្ទៃប្រទេស

៦-វរសេនីយ៍ទោ **ម៉ូ ផុន** អត្តលេខ ០១២៧៤៣ មេបញ្ជាការរង បញ្ជាការដ្ឋានរដ្ឋបាល បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៧-វរសេនីយ៍ទោ **ស្រ៊ុន ពៅ** អត្តលេខ ០២៣៥២២ នាយរង ការិយាល័យហិរញ្ញវត្ថុ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៨-វរសេនីយ៍ទោ **កៅ ជីឡេខ** អត្តលេខ ២៣១៦៨៦ នាយរងការិយាល័យព័ត៌មានទូទៅ ស្នងការដ្ឋានព័ត៌មាននិងសន្តិសុខ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៩-វរសេនីយ៍ទោ **ស៊ិន សារ៉េន** អត្តលេខ ០១២៤១៥ នាយរងការិយាល័យបញ្ជូនសារ ស្នងការដ្ឋានផែនការប្រតិបត្តិការ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១០-វរសេនីយ៍ទោ **ហាំខ ឈាវ** អត្តលេខ ០១២៤១៦ នាយរងការិយាល័យបញ្ជូនសារ ស្នងការដ្ឋានផែនការប្រតិបត្តិការ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១១-វរសេនីយ៍ទោ **សៅ សោភា** អត្តលេខ ០២៩៩៧១ នាយរងការិយាល័យបញ្ជូនសារ ស្នងការដ្ឋានផែនការប្រតិបត្តិការបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១២-វរសេនីយ៍ទោ **សេន សឿន** អត្តលេខ ០២៣៣៦៨ នាយរងការិយាល័យផែនការប្រតិបត្តិការ ស្នងការដ្ឋាន ផែនការប្រតិបត្តិការ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៣-វរសេនីយ៍ទោ **ដួខ សំអាន** អត្តលេខ ០១៩៣៥៥ នាយរងការិយាល័យផែនការប្រតិបត្តិការ ស្នងការដ្ឋានផែនការប្រតិបត្តិការបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៤-វរសេនីយ៍ទោ **ទី ណារ៉ាន់** អត្តលេខ ០១១០៨៧ នាយរងការិយាល័យបុគ្គលិក ស្នងការដ្ឋាន ប្រភពកម្លាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៥-វរសេនីយ៍ទោ **ស្រី ផាត់** អត្តលេខ ០១២៣៨៤ នាយរងការិយាល័យបុគ្គលិក ស្នងការដ្ឋាន ប្រភពកម្លាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៦-វរសេនីយ៍ទោ **ពេជ្រស អូនផៃទរ៉ា** អត្តលេខ ០២៣២៩៥ នាយរងការិយាល័យបុគ្គលិក ស្នងការដ្ឋាន ប្រភពកម្លាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៧-វរសេនីយ៍ទោ **គឹម ពៅ** អត្តលេខ ០៤៦៦៥០ នាយរងការិយាល័យអប់រំផ្សព្វផ្សាយ ស្នងការដ្ឋានប្រភពកម្លាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៨-វរសេនីយ៍ទោ **នេត ស៊ាន** អត្តលេខ ០១២៤០៧ នាយរងការិយាល័យអប់រំផ្សព្វផ្សាយ ស្នងការដ្ឋានប្រភពកម្លាំង បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៩-វរសេនីយ៍ទោ **ព្រាប យុទ្ធី** អត្តលេខ០១២៤២៦ នាយរងការិយាល័យអធិការកិច្ច ស្នងការដ្ឋានប្រភពកម្លាំង បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

២០-វរសេនីយ៍ទោ **ស អេខ** អត្តលេខ០២៣៤៣០ នាយរងការិយាល័យអធិការកិច្ច ស្នងការដ្ឋានប្រភពកម្លាំង បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

២១-វរសេនីយ៍ទោ **យស សុវណ្ណា** អត្តលេខ ០៣៦៥០៦ នាយរងការិយាល័យអធិការកិច្ច ស្នងការដ្ឋានប្រភពកម្លាំង បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

២២-វរសេនីយ៍ទោ **ឆាយ សុផាំ** អត្តលេខ ០១១២៣២ នាយរងការិយាល័យស្រាវជ្រាវប្រឆាំងការជួញដូរ មនុស្ស និងការពារអនីតិជន ស្នងការដ្ឋានស្រាវជ្រាវ និងយុត្តិធម៌ កងរាជអាវុធហត្ថលើផ្ទៃប្រទេស

២៣-វរសេនីយ៍ទោ **ឯម សុវណ្ណា** អត្តលេខ ០០២៨២២ នាយរងការិយាល័យស្រាវជ្រាវប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ស្នងការដ្ឋានស្រាវជ្រាវ និងយុត្តិធម៌ កងរាជអាវុធហត្ថលើផ្ទៃប្រទេស

២៤-វរសេនីយ៍ទោ **ថាច់ ចាន់បូរ៉ុម** អត្តលេខ ០០៨៩៩៣ នាយរងការិយាល័យស្រាវជ្រាវប្រឆាំងគ្រឿងញៀន ស្នងការដ្ឋានស្រាវជ្រាវ និងយុត្តិធម៌បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

២៥-វរសេនីយ៍ទោ **ឌី សារ៉ា** អត្តលេខ ០៣៥៨១៨ នាយរងការិយាល័យគ្រប់គ្រងទិន្នន័យបទល្មើសឧក្រិដ្ឋ និងបច្ចេកទេសវិទ្យាសាស្ត្រ ស្នងការដ្ឋានស្រាវជ្រាវ និងយុត្តិធម៌ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

២៦-វរសេនីយ៍ទោ **ម៉ុក សាម៉ុន** អត្តលេខ ០៣៥៨៦៥ ជំនួយការ ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

២៧-វរសេនីយ៍ទោ **ទុន ម៉ិនធឿន** អត្តលេខ ០១២៤០២ នាយរងការិយាល័យភស្តុភារ ស្នងការដ្ឋានភស្តុភារ បច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

២៨-វរសេនីយ៍ទោ **ផាត់ សាមុធ** អត្តលេខ ០២៣៣៦៧ នាយរងការិយាល័យសម្ភារៈបច្ចេកទេស ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

២៩-វរសេនីយ៍ទោ **ទេព ឡឿន** អត្តលេខ០២៣៤៤៥ នាយរងការិយាល័យសម្ភារៈបច្ចេកទេស ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៣០-វរសេនីយ៍ទោ **ស៊ី វណ្ណា** អត្តលេខ ០០១៥៨៨ នាយការិយាល័យបច្ចេកទេស ស្នងការដ្ឋានសម្ភារៈបច្ចេកទេស កងរាជអាវុធហត្ថលើផ្ទៃប្រទេស

៣១-វរសេនីយ៍ទោ **ចៅ សារិន** អត្តលេខ ០២៣៤៤០ នាយរងការិយាល័យសម្ភារៈបច្ចេកទេស ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៣២-វរសេនីយ៍ទោ **រឿខ រិន** អត្តលេខ០២៣៤៣៥ នាយរងការិយាល័យសម្ភារៈបច្ចេកទេស ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៣៣-វរសេនីយ៍ទោ **គួច ហាក់ស្រ៊ន** អត្តលេខ ០១២៤០១ នាយរងការិយាល័យសម្ភារៈបច្ចេកទេស ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៣៤-វរសេនីយ៍ទោ **ម៉ិន សំអាត** អត្តលេខ ០២៣៣០០ នាយរងការិយាល័យអភិវឌ្ឍន៍ ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៣៥-វរសេនីយ៍ទោ **ប្រាក់ ម៉ិណ្ណា** អត្តលេខ ០១៧២០៨ នាយរងការិយាល័យអភិវឌ្ឍន៍ ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៣៦-វរសេនីយ៍ទោ **ខាន់ សារ៉េត** អត្តលេខ ០២៣៥៣៥ នាយរងការិយាល័យអភិវឌ្ឍន៍ ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៣៧-វរសេនីយ៍ទោ **ឡុង ស៊ីណារ៉េ** អត្តលេខ ១៥១៨៤៦ នាយរងការិយាល័យអភិវឌ្ឍន៍ ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៣៨-វរសេនីយ៍ទោ **ឈួ គា** អត្តលេខ ០២៣៥៤៥ នាយរងការិយាល័យអភិវឌ្ឍន៍ ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៣៩-វរសេនីយ៍ទោ **ប៉ោ សុវណ្ណា** អត្តលេខ ០០១៧៧២ នាយរងការិយាល័យអភិវឌ្ឍន៍ ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤០-វរសេនីយ៍ទោ **សេខ ថុន្នី** អត្តលេខ ០១៥៥៥០ នាយរងការិយាល័យវិស្វកម្ម ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤១-វរសេនីយ៍ទោ **ឃៀម ឃុន** អត្តលេខ ០០២៥៤៧ នាយរងការិយាល័យវិស្វកម្ម ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤២-វរសេនីយ៍ទោ **ឈុត សុភាព** អត្តលេខ ០១២៤៤៤ នាយរងការិយាល័យសន្តិសុខ ស្នងការដ្ឋានព័ត៌មាននិងសន្តិសុខ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤៣-វរសេនីយ៍ទោ **សៅ សុកុមារ** អត្តលេខ ០៣១៧៧៦ នាយរងការិយាល័យសុខាភិបាល ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤៤-វរសេនីយ៍ទោ **ទូច ឧត្តម** អត្តលេខ ០៤៣២៤៦ នាយរងការិយាល័យសុខាភិបាល ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤៥-វរសេនីយ៍ទោ **ហ៊ីរ ចាន់ពៅ** អត្តលេខ ០១២៤៣២ នាយរងការិយាល័យសុខាភិបាល ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤៦-វរសេនីយ៍ទោ **មាស និត្យ** អត្តលេខ ០១២២៤៩ នាយរងការិយាល័យសម្ភារៈបច្ចេកទេស ស្នងការដ្ឋានភស្តុភារបច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤៧-វរសេនីយ៍ទោ **ខួន សុវណ្ណារ័ត្នន៍** អត្តលេខ ១៩៦៦៥៨ នាយករង មជ្ឈមណ្ឌលហ្វឹកហ្វឺននាយទាហានរងកងរាជអាវុធហត្ថ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤៨-វរសេនីយ៍ទោ **ច័ន្ទ វាសនា** អត្តលេខ ០១២៤៦៥ នាយសេនាធិការរង កងរាជអាវុធហត្ថរាជធានីភ្នំពេញ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ:....០៧ សរ...

# សារាចរ
## ស្តីពី
## ការចាត់តាំងខួបលើកទី៦៧ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៥ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៦

ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជាតែងប្រារព្ធទិវា**កុមារអន្តរជាតិ ១ មិថុនា ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា** ដើម្បីរំឮកដល់ការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់កុមារ និងបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះកុមារស្របតាមរដ្ឋធម្មនុញ្ញ អនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ អនុសញ្ញាស្តីពីការហាមប្រាមរបស់អង្គការពលកម្មអន្តរជាតិ និងសកម្មភាពបន្ទាន់សម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងបទដ្ឋានជាតិ អន្តរជាតិស្តីពីសិទ្ធិកុមារផ្សេងៗទៀត។

ការប្រារព្ធទិវាកុមារអន្តរជាតិ ១ មិថុនា គឺដើម្បីរំឮកនូវព្រឹត្តិការណ៍វិនាសកម្មរបស់ពួកហ្វាសស៊ីសអ៊ីត្លែរ ដែលបានកាប់សម្លាប់ស្ត្រី និងកុមារនៅភូមិលីឌីសែ ប្រទេសឆេក និងនៅភូមិអូរាឌូ ប្រទេសបារាំង ក្នុងអំឡុងឆ្នាំ ១៩៤២-១៩៤៤ នៃសង្គ្រាមលោកលើកទី២ និងដើម្បីរួមគ្នាទប់ស្កាត់អំពើហិង្សា ថែរក្សាសន្តិភាពពិភពលោក និងជំរុញការអនុវត្តសិទ្ធិកុមារនៅគ្រប់ប្រទេស។

ការប្រារព្ធទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា គឺបង្កើនចលនាពិភពលោកប្រឆាំងពលកម្មកុមារ ដែលបានស្តែងឱ្យឃើញ តាមរយៈការផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងអនុសញ្ញាស្តីពីអាយុអប្បបរមាសម្រាប់ចូលធ្វើការដោយប្រទេសជាច្រើនលើពិភពលោក សំដៅទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរដូចជា ទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារ និងការប្រើប្រាស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងក្នុងស្ថានភាពងាយរងគ្រោះ។ ទិវានេះក៏បំផុសឱ្យមានការគាំទ្របន្ថែមពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀត។

ព្រះរាជាណាចក្រកម្ពុជាធ្លាប់បានទទួលរងនូវមហាវិនាសកម្មដ៏ធ្ងន់ធ្ងរ ដែលបង្កឡើងដោយរបបប្រល័យពូជសាសន៍ **ប៉ុល ពត** ដែលបានកាប់សម្លាប់ប្រជាជនរាប់លាននាក់ និងបំផ្លាញសង្គមជាតិខ្ទេចខ្ទីដល់ឫសគល់ ក្នុងនោះកុមារក៏ត្រូវទទួលនូវការកាប់សម្លាប់ធ្វើទារុណកម្ម បង្ខំឱ្យធ្វើការជាទម្ងន់ បង្អត់អាហារ រស់នៅយ៉ាងលំបាកវេទនាដោយអយុត្តិធម៌។ ក្រោយថ្ងៃរំដោះ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ សិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងនោះរួមមានសិទ្ធិកុមារផង ត្រូវបានការពារ និងលើកតម្កើងដោយមានចែងយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ កម្មវិធីនយោបាយ ផែនការ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

ដើម្បីប្រយុទ្ធប្រឆាំងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ការទប់ស្កាត់ការជួញដូរកុមារ ការកេងប្រវ័ញ្ច អំពើពេស្យាចារលើកុមារ អំពើហិង្សាលើកុមារ និងការប្រើប្រាស់គ្រឿងញៀន រាជរដ្ឋាភិបាលបានបង្កើតច្បាប់

គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ ជាច្រើន ដូចជា៖ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីការត្រួតពិនិត្យថ្នាំជក់ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ស្តីពីការងារ គោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច គោលនយោបាយថែទាំជំនួសចំពោះកុមារ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ពលកម្មកុមារឆ្នាំ២០១៦-២០២៥ និងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ព្រមទាំងច្បាប់ និងផែនការជាច្រើនផ្សេងទៀត។ ម្យ៉ាងវិញទៀត ដើម្បីឱ្យការអនុវត្តការងាររឹតតែមានប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលក៏បានបង្កើតមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន បង្កើតយន្តការទប់ស្កាត់ថ្នាក់ជាតិដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ និងបទដ្ឋានថែទាំនិងការការពារកុមារកំព្រា និងកុមារងាយរងគ្រោះ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលក៏បានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិជាច្រើន ដូចជា អនុសញ្ញាស្តីពីសិទ្ធិកុមារ ពិធីសារបន្ថែមស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងពិធីសារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ អនុសញ្ញាស្តីពីការងារដោយបង្ខំ ឬជាកាតព្វកិច្ច អនុសញ្ញាស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការ អនុសញ្ញាស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារនិងសហប្រតិបត្តិការសុំកូនអន្តរប្រទេស។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានបង្កើតយន្តការជាច្រើននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អនុគណៈកម្មការជាតិពលកម្មកុមារនិងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ ក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័ន គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គណៈកម្មការការពារកុមារថ្នាក់ជាតិ គណៈកម្មការដឹកនាំកិច្ចការអំពើហិង្សាលើស្ត្រីនិងអំពើហិង្សាលើកុមារ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់រាជធានី-ខេត្ត ក្នុងទិសដៅជំរុញការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព។

រាជរដ្ឋាភិបាលបានបង្កើនថវិកាលើវិស័យសង្គមកិច្ច អប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ កសិកម្ម និងវិស័យមួយចំនួនទៀត ក្នុងគោលដៅធ្វើឱ្យសុខុមាលភាពប្រជាជនកាន់តែប្រសើរឡើង ជាពិសេស ចំពោះកុមារ និងសម្រេចបានគោលដៅជាច្រើននៃគោលដៅអភិវឌ្ឍសហស្សវត្សរ៍។

ទោះបីយ៉ាងនេះក្តី កុមារកម្ពុជានៅប្រឈមមុខជាមួយនឹងបញ្ហាមួយចំនួននៅឡើយ ដូចជា អំពើហិង្សា ការប្រើប្រាស់គ្រឿងញៀន អនីតិជនទំនាស់នឹងច្បាប់ អំពើជួញដូរកុមារ ពលកម្មកុមារ កុមារកង្វះអាហារូបត្ថម្ភ កុមារបោះបង់ចោលការសិក្សា និងកុមារចំណាកស្រុក ដែលតម្រូវឱ្យយើងទាំងអស់គ្នា រួមគ្នាដោះស្រាយឱ្យបានទាន់ពេលវេលានិងចំគោលដៅ។ ដើម្បីជំរុញការអនុវត្តសិទ្ធិកុមារឱ្យកាន់តែល្អប្រសើរឡើងថែមទៀត រាជរដ្ឋាភិបាលសូមធ្វើការណែនាំចាត់តាំងខួបលើកទី៦៧ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី១៥ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៦នេះ ដូចតទៅ៖

១-ប្រធានបទនៃការប្រារព្ធខួបលើកទី៦៧ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៥ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៦ គឺ *«រួមគ្នាការពារកុមារពីអំពើហិង្សា និងការប្រើប្រាស់គ្រឿងញៀន»* និង *«រួមគ្នាបញ្ចប់ពលកម្មកុមារនៅក្នុងចង្វាក់ផលិតកម្ម»*។

២-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ សាលារាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំមីទ្ទិញថ្នាក់ជាតិ និងរៀបចំកម្មវិធីកម្សាន្តផ្សេងៗ សម្រាប់កុមារនៅរាជធានីភ្នំពេញ។

៣-ក្រសួងព័ត៌មានត្រូវសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ណែនាំប្រព័ន្ធឃោសនារដ្ឋ និងឯកជនឱ្យធ្វើការផ្សព្វផ្សាយដល់សង្គមជាតិទាំងមូល ឱ្យបានជ្រួតជ្រាបពីប្រវត្តិនៃ**ទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាកុមារកម្ពុជា រួមទាំងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា** ផងដែរ។

៤-គ្រប់ក្រសួងស្ថាប័ន រាជធានីខេត្ត ត្រូវរៀបចំពិធីមីទ្ទិញ ពិធីជួបសំណេះសំណាលជាមួយកុមារ កម្មវិធីកម្សាន្តសប្បាយរបស់កុមារ នៅតាមក្រសួងស្ថាប័ន រាជធានីខេត្ត គ្រឹះស្ថានសិក្សារដ្ឋ ឯកជន អង្គការមិនមែនរដ្ឋាភិបាល និងគ្រប់មណ្ឌលកុមារកំព្រានៅក្នុងមូលដ្ឋានរៀងៗខ្លួន។

៥-គ្រប់ក្រសួងស្ថាប័ន រាជធានីខេត្ត គ្រឹះស្ថានសាធារណៈឯកជន ត្រូវរៀបចំចងបដាពាក្យស្លោក ដើម្បីអបអរសាទរខួបលើកទី៦៧ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៥ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៦ នេះដូចតទៅ៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរខួបលើកទី៦៧ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៥ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៦
- រួមគ្នាការពារកុមារពីអំពើហិង្សា និងការប្រើប្រាស់គ្រឿងញៀន
- រួមគ្នាបញ្ចប់ពលកម្មកុមារនៅក្នុងចង្វាក់ផលិតកម្ម
- គ្មានអំពើហិង្សាធ្វើឱ្យកុមារមានការអភិវឌ្ឍផ្នែករាងកាយបញ្ញានិងស្មារតី
- អភិវឌ្ឍកុមារជាគ្រឹះនៃការអភិវឌ្ឍប្រទេសជាតិ
- រួមគ្នាលុបបំបាត់ពលកម្មកុមារដើម្បីសិទ្ធិមនុស្ស និងយុត្តិធម៌សង្គម
- កុមារជាទំពាំងស្នងឫស្សី ជាអនាគតរបស់ប្រទេសជាតិ
- កុមារបីល្អ កូនល្អ សិស្សល្អ មិត្តល្អ ជាអនាគតពលរដ្ឋល្អ

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ សាលារាជធានី ខេត្ត ត្រូវផ្សព្វផ្សាយអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែឧសភា ឆ្នាំ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការមេឆ្ពោះទៅការធ្វើជាម្ចាស់ផ្ទះ
# ការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)លើកទី៣២
# ឆ្នាំ២០២៣
# (២០១៦–២០២៣)

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ**

**នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦**

## អារម្ភកថា

ចលនាកីឡាសកលនិងចលនាកីឡាអូឡាំពិកកំពុងតែដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ កីឡាបានជះឥទ្ធិពលនិងជ្រួតជ្រាបគ្រប់ទីកន្លែងជុំវិញពិភពលោកមិនថាប្រទេសអភិវឌ្ឍ ប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសក្រោមការអភិវឌ្ឍនោះឡើយ តែងតែទទួលបានភាពសប្បាយរីករាយ មោទនភាពជាតិ សាមគ្គីភាព មិត្តភាព សន្តិភាព និងឧត្តមភាពជាតិលើឆាកអន្តរជាតិពីសកម្មភាពនិងព្រឹត្តិការណ៍កីឡានានា។

ទន្ទឹមនឹងនោះកម្ពុជាឆ្លងកាត់សោកនាដកម្មនៃសង្គ្រាមធ្វើឱ្យវិស័យកីឡា ក៏ដូចវិស័យដទៃទៀតធ្លាក់ចុះក្រោមសូន្យ។ ក្រោមពន្លឺនៃសន្តិភាព ស្ថិរភាពនយោបាយ កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម ៧,៧% ក្នុងរយៈពេលពីរទសវត្សចុងក្រោយ ធ្វើឱ្យវិស័យកីឡាកម្ពុជាស្ទុះផុសផុល រីកចម្រើន និងទទួលបានការគាំទ្រពីយុវជននិងប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ហើយថែមទាំងដណ្តើមបានជ័យលាភីជាបន្តបន្ទាប់ ធ្វើឱ្យកេរ្តិ៍ឈ្មោះនិងកិត្យានុភាពជាតិល្បីសុះសាយលើឆាកអន្តរជាតិ។

ទាំងអស់នេះកើតឡើងពីការដាក់ចេញនូវគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ពិសេស យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ អាណត្តិទី៥នៃរដ្ឋសភានិងផែនការកំណែទម្រង់យុទ្ធសាស្ត្រស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ទើបធ្វើឱ្យវិស័យកីឡាជាតិប្រែមុខមាត់ថ្មីលើឆាកជាតិនិងអន្តរជាតិ។

ក្នុងបរិការណ៍ប្រជាសាស្ត្រសម្បូរដោយប្រជាពលរដ្ឋវ័យក្មេង ជាក្តីសង្ឃឹមនៃកម្លាំងការងារ ជាអនាគតដ៏រឹងមាំនៃប្រទេសជាតិ ជាក្តីសុបិននៃថាមពលកីឡាជាតិទៅថ្ងៃអនាគត ដែលពួកគេបាននិងកំពុងចូលរួមនិងគាំទ្រដល់សកម្មភាពនិងព្រឹត្តិការណ៍ប្រកួតកីឡាយ៉ាងគគ្រឹកគគ្រេង។ ការប្រកួតកីឡាថ្នាក់ជាតិ អន្តរជាតិ បាននិងកំពុងស្រូបយកយុវជនវ័យក្មេងឱ្យចូលរួមលេងកីឡានិងគាំទ្រកីឡាដើម្បីទទួលបាននូវស្មារតីស្នេហាជាតិ សាមគ្គីភាព មិត្តភាព និងសុខភាពល្អ ដែលជាកម្លាំងពលកម្មមិនអាចខ្វះបានក្នុងការបំប៉នក្បាលម៉ាស៊ីនសេដ្ឋកិច្ចជាតិ។

កីឡាគឺជាមោទនភាពជាតិ ជាឧត្តមភាពជាតិ និងជាចំណីអាហារបំប៉នថាមពលរាងកាយ និងចំណីអារម្មណ៍រំភើបញាប់ញ័រ ដែលមិនអាចខ្វះបានក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ។

បច្ចុប្បន្ន កីឡាក្លាយជាចលករអភិវឌ្ឍសង្គម ក្លាយជាឧស្សាហកម្មកីឡា ធុរកិច្ចកីឡា និងជានយោបាយទ្រទ្រង់សង្គមទាំងក្នុងទាំងក្រៅប្រទេស ពិសេស កីឡាក្លាយជាចលនាទ្រទ្រង់សេវាសុខភាពសាធារណៈដ៏មានប្រសិទ្ធភាព ដែលរាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ខ្ពស់ក្នុងការរៀបចំនិងដាក់ចេញនូវគោលនយោបាយជាតិស្តីពីការអភិវឌ្ឍអប់រំកាយនិងកីឡានាឆ្នាំ២០១៥ ដែលជាចក្ខុវិស័យតម្រង់ទិសគោលនយោបាយកីឡាជាតិឆ្ពោះទៅបង្កើតឡើងនូវផែនការមេឆ្ពោះទៅធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍ឆ្នាំ២០២៣ ពិតជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ជាមុខមាត់ កេរ្តិ៍ឈ្មោះ និងជាកម្លាំងថាមពល ដែលត្រូវដាក់បង្ហាញពិភពលោកឱ្យ[illegible]

ពីវប្បធម៌ អរិយធម៌ ទេសចរណ៍ សេដ្ឋកិច្ច សង្គមខ្មែរដ៏រុងរឿងថ្កុំថ្កើងបន្ថែមទៀត។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមអំពាវនាវដល់ប្រជាពលរដ្ឋ ស្ថាប័ន អង្គភាពរដ្ឋ វិស័យឯកជនពិសេស យុវជនឲ្យចូលរួមលេងនិងគាំទ្រកីឡា និងនាំគ្នាចាប់ដៃកសាងអភិវឌ្ឍវិស័យកីឡាជាតិឱ្យទទួលបានជោគជ័យជាបណ្តើរៗ **ឆ្ពោះទៅមហាជោគជ័យកីឡាអាស៊ីអាគ្នេយ៍ (SEA Games)លើកទី៣២ ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។**

ខ្ញុំសូមសំដែងការកោតសរសើរចំពោះគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា សហព័ន្ធកីឡាជាតិ និងអង្គការកីឡាពាក់ព័ន្ធ ដែលរៀបចំបានសម្រេចនូវផែនការមេឆ្ពោះទៅធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួត**កីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣** នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីជាកត្តាកំណត់ចក្ខុវិស័យជាតិប្រកបដោយសក្តានុពលនិងឧត្តមភាពកីឡាជាតិនៅក្នុងតំបន់និងពិភពលោក។

**គ្មានអ្វីប្រសើរជាងកីឡា គ្មានអ្វីថ្លៃថ្លាជាងកិត្តិយស គ្មានអ្វីខ្ពង់ខ្ពស់ជាងជាតិរុងរឿងថ្កុំថ្កើងនោះឡើយ!**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា

**អារម្ភកថា**


I. **សេចក្តីផ្តើម**......១
II. **ប្រវត្តិនៃការចូលរួមកីឡាអាស៊ីអាគ្នេយ៍(SEA Games)របស់កម្ពុជា**......២
III. **លក្ខណៈទូទៅនៃព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍(SEA Games)**......៤
៣.១- ចក្ខុវិស័យ គោលបំណង កម្មវត្ថុ......៤
៣.២- លក្ខណៈទូទៅនៃព្រឹត្តិការណ៍......៤
៣.៣- អត្ថប្រយោជន៍នៃការរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)ឆ្នាំ២០២៣......៥
IV. **ផែនការមុនព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)នៅកម្ពុជា**......៧
៤.១- ការកំណត់ប្រភេទកីឡា......៧
៤.២- ហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈ ឧបករណ៍ហ្វឹកហាត់......៨
៤.២.១- ហេដ្ឋារចនាសម្ព័ន្ធ......៨
៤.២.២- សម្ភារៈ ឧបករណ៍ហ្វឹកហាត់......១០
៤.៣- ការបណ្តុះបណ្តាលធនធានមនុស្ស......១០
៤.៣.១- ការបណ្តុះបណ្តាលកីឡាករ......១០
៤.៣.២- ការបណ្តុះបណ្តាលគ្រូបង្វឹក......១១
៤.៣.៣- ការបណ្តុះបណ្តាលមន្ត្រីកីឡា (មន្ត្រីជំនាញ មន្ត្រីរដ្ឋបាល អាជ្ញាកណ្តាល ចៅក្រម)......១២
៤.៣.៤- សហព័ន្ធកីឡាជាតិ......១២
៤.៣.៥- មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា......១៣
៤.៤- ជំនាញនិងបទពិសោធរៀបចំការប្រកួតពហុកីឡា "Games"......១៤
៤.៥- ដំណើរការនៃការរៀបចំព្រឹត្តិការណ៍ប្រកួត......១៤
៤.៦- ផែនការយុទ្ធសាស្ត្រផ្សព្វផ្សាយនិងទីផ្សារកីឡាអាស៊ីអាគ្នេយ៍(SEA Games)......១៥
៤.៧- យុទ្ធសាស្ត្រយកប្រៀប......១៦
V. **ផែនការយុទ្ធសាស្ត្រក្នុងអំឡុងពេលព្រឹត្តិការណ៍ប្រកួត**......១៦
VI. **យុទ្ធសាស្ត្រក្រោយពេលព្រឹត្តិការណ៍ប្រកួត**......១៨
VII. **យុទ្ធសាស្ត្រគាំទ្រផែនការមេ កីឡាអាស៊ីអាគ្នេយ៍(SEA Games)ឆ្នាំ២០២៣**......១៩
៧.១- ចំពោះសាលារាជធានីភ្នំពេញ......១៩
៧.២- ចំពោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ......១៩
៧.៣- ចំពោះគ្រឹះស្ថានសិក្សា......១៩

៧.៤- ចំពោះរដ្ឋអំណាចថ្នាក់ក្រោមជាតិ........................................................................................២០
៧.៥- ចំពោះស្ថាប័នជាតិ........................................................................................................២០
៧.៦- ចំពោះក្រសួងអប់រំ យុវជន និងកីឡា និងអង្គភាពជំនាញអប់រំកាយនិងកីឡា និងកីឡាជំនាញកម្រិតខ្ពស់....២០
៧.៧- ចំពោះអង្គការកីឡាសង្គម.................................................................................................២២
VIII. **សេចក្តីសន្និដ្ឋាន**...........................................................................................................២៣
**ឧបសម្ព័ន្ធ**.............................................................................................................................២៤
**សទ្ទានុក្រម**..........................................................................................................................២៥

## I. សេចក្តីផ្តើម

ដោយមើលឃើញពីការរីកចម្រើននៃវិស័យកីឡាកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានឯកភាពនិងយល់ព្រមអនុញ្ញាតជាគោលការណ៍ឱ្យគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាទទួលធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games) នៅឆ្នាំ២០២៣។

តបតាមលិខិតរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី លេខ២១ L.I ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ ផ្ញើជូនប្រធានក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ ដែលក្នុងនោះក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍នៅក្នុងកិច្ចប្រជុំកាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៥ បានប្រគល់លិខិតចាត់តាំងគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំកីឡាអាស៊ីអាគ្នេយ៍ (SEA Games) លើកទី៣២ ឆ្នាំ២០២៣។

យោងតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លិខិតលេខ៣៤៤ សជណ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ និងលិខិតចាត់តាំងពីក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ ឱ្យកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)លើកទី៣២ ឆ្នាំ២០២៣ នៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា សហព័ន្ធកីឡាជាតិ និងស្ថាប័នពាក់ព័ន្ធរួមគ្នារៀបចំផែនការយុទ្ធសាស្ត្រកម្ពុជាឆ្ពោះទៅធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួត កីឡាអាស៊ីអាគ្នេយ៍(SEA Games)លើកទី៣២ ឆ្នាំ២០២៣។

ដើម្បីរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)លើកទី៣២ ឆ្នាំ២០២៣ ឱ្យទទួលបានជោគជ័យសំដៅធានាឱ្យសមិទ្ធកម្មកីឡាជាតិផ្តល់លទ្ធផលជាវិជ្ជមាន គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា (គ.ជ.អ.ក.) បានរៀបចំសេចក្តីព្រាងផែនទីបង្ហាញផ្លូវនិងផែនការយុទ្ធសាស្ត្រ ប្រកបដោយចក្ខុវិស័យមួយច្បាស់លាស់និងគ្រប់ជ្រុងជ្រោយដូចជា៖

- ត្រូវកំណត់និងជ្រើសរើសចំនួនប្រភេទកីឡាសម្រាប់បញ្ចូលក្នុងកម្មវិធីប្រកួត កីឡាអាស៊ីអាគ្នេយ៍(SEA Games) ជាមុន
- ត្រួតពិនិត្យសម្បទានកីឡា "Sport facility" ដែលមានស្រាប់ដើម្បីជួសជុល កែលម្អ ឬត្រូវសាងសង់ថ្មីបន្ថែមទៅតាមទំហំនៃតម្រូវការប្រភេទកីឡាដែលត្រូវបានកំណត់ក្នុងកម្មវិធីប្រកួត
- កត្តាសំខាន់បំផុតនៃការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)ឱ្យទទួលបានជោគជ័យ គឺការលើកកម្ពស់សមត្ថភាព គុណភាពកីឡាករនៅពេលប្រកួត និងការរំពឹងទុកថាកីឡាករកម្ពុជាអាចដណ្តើមបានច្រើននូវមេដាយមាស ប្រាក់ សំរឹទ្ធ។

**ផែនការយុទ្ធសាស្ត្រនេះផ្តោតលើក្ខណសម្បត្តិសំខាន់១៣គឺ៖**

១- ការរៀបចំផែនការមុនព្រឹត្តិការណ៍ប្រកួត ផែនការក្នុងពេលដំណើរការព្រឹត្តិការណ៍ និងផែនការក្រោយព្រឹត្តិការណ៍ប្រកួត។

២- រៀបចំហេដ្ឋារចនាសម្ព័ន្ធកីឡានិងហេដ្ឋារចនាសម្ព័ន្ធសាធារណៈគាំទ្រដទៃទៀត

៣- ការបណ្តុះបណ្តាលធនធាន កីឡាករ មន្ត្រីជំនាញនិងបទពិសោធក្នុងការរៀបចំពហុកីឡា (Games)។

តម្រូវការផែនការទាំង៣ខាងលើនេះ គឺមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ប្រសិនបើមានផែនការយុទ្ធសាស្ត្រ ផែនការបង្ហាញផ្លូវតាមដំណាក់កាលច្បាស់លាស់ មានហេដ្ឋារចនាសម្ព័ន្ធកីឡាត្រឹមត្រូវ តាមស្តង់ដារបច្ចេកទេស គឺធ្វើឱ្យកីឡាករ និងគ្រូបង្វឹកស្វែងរកគុណផល (Performance) បាន។ ព្រមជាមួយនោះ [illegible]សាធរៀបចំពហុកីឡា ក៏ជាកត្តាសំខាន់ឆ្ពោះទៅរកជោគជ័យនៃការធ្វើជាម្ចាស់ផ្ទះផងដែរ។ រីឯ[illegible]ហេដ្ឋារចនាសម្ព័ន្ធកីឡា គឺជាមូលដ្ឋានបឋម និងចាំបាច់បំផុតក្នុងការអភិវឌ្ឍវិស័យកីឡា។

ធនធានមនុស្សក្នុងវិស័យកីឡា គឺជាធនធានមនុស្សដែលមានជំនាញកីឡា ដែលត្រូវការបណ្តុះបណ្តាលទាំងមន្ត្រីបច្ចេកទេស អាជ្ញាកណ្តាល ចៅក្រម ពិសេសគ្រូបង្វឹក និងកីឡាករដែលតម្រូវឱ្យមានគុណភាពជំនាញកីឡាច្បាស់លាស់ត្រៀមរៀបចំការបណ្តុះបណ្តាលទាំងក្នុងប្រទេសនិងក្រៅប្រទេសឆ្ពោះទៅសម្រេចគុណផលខ្ពស់ (Peak Performance) ដើម្បីឱ្យប្រាកដថាកម្ពុជានឹងអាចដណ្តើមបានមេដាយច្រើនជាងការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)មុនៗនាកំលុងពេលធ្វើជាម្ចាស់ផ្ទះនៅ ឆ្នាំ២០២៣។

សារៈសំខាន់នៃផែនការចុងក្រោយ គឺការរៀបចំប្រសិទ្ធភាពនៃការគ្រប់គ្រង និងការដឹកនាំព្រឹត្តិការណ៍ប្រកួតដែលទាមទារឱ្យមានការសិក្សានិងដកស្រង់បទពិសោធពីការរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)លើកមុនៗ និងការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)ខាងមុខបន្តបន្ទាប់រហូតដល់ឆ្នាំ២០២៣។ ការដឹកនាំនិងការគ្រប់គ្រងព្រឹត្តិការណ៍នេះ ក៏ត្រូវមានការបណ្តុះបណ្តាលតាមប្រព័ន្ធស្តង់ដានៃការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាធំៗ ផ្សេងៗទៀតផងដែរ។

សូមជនរួមជាតិ ក្រុមហ៊ុន សហគ្រាស ធុរជន អង្គការជាតិអន្តរជាតិ បណ្តាប្រទេសជាមិត្ត និងប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស សូមចូលរួមយុទ្ធនាការ "ទាំងអស់គ្នាឆ្ពោះទៅកីឡាអាស៊ីអាគ្នេយ៍ (SEA Games)ឆ្នាំ២០២៣ នៅព្រះរាជាណាចក្រកម្ពុជា"។

## II. ប្រវត្តនៃការចូលរួមកឡាអាស៊ីអាគ្នេយ៍(SEA Games)របស់កម្ពុជា

ព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games)បានក្លាយជាទិវាបុណ្យកីឡាសម្រាប់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលប្រព្រឹត្តធ្វើឡើងរៀងរាល់២ឆ្នាំម្តង។ គណៈកម្មាធិការអូឡាំពិកជាតិជាម្ចាស់ផ្ទះត្រូវបានផ្តល់សិទ្ធិតាមលំដាប់អក្ខរក្រមឡាតាំង (Alphabetical order) នៃប្រទេសជាសមាជិកសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ (SEAGF)។ ដោយឡែក គណៈកម្មាធិការអូឡាំពិកជាតិនៃប្រទេសដែលមិនធ្លាប់ធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួត អាចស្នើសុំធ្វើការរៀបចំដោយមិនតម្រូវតាមលំដាប់អក្ខរក្រមឡាតាំងបាន។ ទីក្រុងនៃប្រទេសម្ចាស់ផ្ទះមានសិទ្ធិសម្រេចជាអាទិភាពក្នុងការរៀបចំនិងការគ្រប់គ្រងហិរញ្ញវត្ថុដោយខ្លួនឯងយោងតាមធម្មនុញ្ញសហពន្ធ័កីឡាអាស៊ីអាគ្នេយ៍(SEAGF Charter)។

កម្ពុជាគឺជាប្រទេសស្ថាបនិកនៃកីឡាជ្រោយអាស៊ីអាគ្នេយ៍ Southeast Asia Peninsular Games (SEAP Games) ជាមួយនឹងប្រទេសវៀតណាម ថៃ ឡាវ និងភូមា នាឆ្នាំ១៩៥៨។ ព្រឹត្តិការណ៍ប្រកួតកីឡាជ្រោយអាស៊ីអាគ្នេយ៍ (SEAP Games) លើកទី១ ត្រូវបានធ្វើឡើងក្នុងឆ្នាំ១៩៥៩ នៅទីក្រុងបាងកករហូតដល់ឆ្នាំ១៩៧៧ កីឡាជ្រោយអាស៊ីអាគ្នេយ៍ (SEAP Games) ត្រូវបានប្តូរឈ្មោះមកជាកីឡាអាស៊ីអាគ្នេយ៍(SEA Games)វិញ។ បច្ចុប្បន្ន ការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)ត្រូវបានគ្រប់គ្រងដោយសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ SoutheastAsianGamesFederation (SEAGF) ដែលមានគណៈកម្មាធិការអូឡាំពិកជាតិនៃបណ្តាប្រទេសអាស៊ីអាគ្នេយ៍ទាំង១១ជាសមាជិក ដោយគោរពតាមធម្មនុញ្ញនៃសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ (SEAGF Charter)។ កម្ពុជាជាស្ថាបនិកនៃកីឡាអាស៊ីអាគ្នេយ៍ក៏ពិតមែន ប៉ុន្តែ កម្ពុជាពុំធ្លាប់ធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡានេះម្តងណាឡើយ។

ប្រវត្តិនៃការចូលរួមរបស់កម្ពុជាមានដូចខាងក្រោម៖

- កម្ពុជាមិនបានចូលរួមប្រកួតកីឡាជ្រោយអាស៊ីអាគ្នេយ៍ (SEAP Games) លើកទី១ នៅទីក្រុងបាងកក ឆ្នាំ១៩៥៩ទេ។
- កម្ពុជាបានបញ្ជូនប្រតិភូកីឡាទៅចូលរួមប្រកួតកីឡាជ្រោយអាស៊ីអាគ្នេយ៍ (SEAP Games) លើកទី២ឆ្នាំ១៩៦១ នៅទីក្រុង រ៉ង់ហ្គូនប្រទេសមីយ៉ាន់ម៉ាដោយមានកីឡាករចូលរួមចំនួន៨៧នាក់ ... បានមេដាយមាស១ មេដាយប្រាក់៧ និងសំរឹទ្ធ៤ ក្នុង១១ប្រភេទកីឡា។

- នៅឆ្នាំ១៩៦៣ កម្ពុជាដល់វេនត្រូវធ្វើជាម្ចាស់ផ្ទះកីឡាជ្រោយអាស៊ីអាគ្នេយ៍ (SEAP Games) លើកទី៣ ប៉ុន្តែដោយសារស្ថានភាពមិនអំណោយផល(បញ្ហាប្រាសាទព្រះវិហារ) កម្ពុជាពុំបានធ្វើជាម្ចាស់ផ្ទះពេលនោះទេ។ នៅឆ្នាំ១៩៦៥ ប្រទេសម៉ាឡេស៊ី បានធ្វើជាម្ចាស់ផ្ទះកីឡាជ្រោយអាស៊ីអាគ្នេយ៍ (SEAP Games) លើកទី៣ នៅទីក្រុងកូឡាឡាំពូជំនួសកម្ពុជាវិញ ដែលពេលនោះ កម្ពុជាបានចូលរួមដោយបញ្ជូនប្រតិភូកីឡាចំនួន៨៤នាក់ លទ្ធផលទទួលបានមេដាយមាស១៥ មេដាយប្រាក់១៩ និងសំរឹទ្ធ១៧ ក្នុង៨ប្រភេទកីឡា។ ប្រភេទកីឡាដណ្តើមបានមេដាយមាន អត្តពលកម្ម មេដាយមាស២ ប្រដាល់សកល មេដាយមាស៣ ជិះកង់ មេដាយមាស២ ហែលទឹក មេដាយមាស៤ វាយកូនឃ្លីលើតុ មេដាយមាស៣ និងបាល់ទះ មេដាយមាស១។ កីឡាជ្រោយអាស៊ីអាគ្នេយ៍ (SEAP Games) លើកទី៣នេះ បានបង្ហាញពីការរីកចម្រើនរបស់កីឡាករកម្ពុជាមួយកម្រិត។
- ចំពោះកីឡាជ្រោយអាស៊ីអាគ្នេយ៍ (SEAP Games) លើកទី៤និងទី៥ កម្ពុជាមិនបានចូលរួមប្រកួតទេ។
- កម្ពុជាបានចូលរួមប្រកួតកីឡា SEAP Games លើកទី៦នៅប្រទេសមីយ៉ាន់ម៉ានៅឆ្នាំ១៩៧១ ដោយកីឡាករកីឡាការិនី កម្ពុជាបានបង្ហាញនូវកម្រិតគុណផល (Performance) ដ៏លេចធ្លោរបស់ខ្លួនដោយដណ្តើមបានមេដាយមាស១៧ មេដាយប្រាក់១៨ និងមេដាយសំរឹទ្ធ១៧ ដោយក្នុងនោះកីឡាអត្តពលកម្មដណ្តើមបានមេដាយមាស៧ ហែលទឹក មេដាយមាស៥ វាយកូនឃ្លីលើតុបានមេដាយមាស៣ និងបាល់ទះបានមេដាយមាស២។
- កីឡាជ្រោយអាស៊ីអាគ្នេយ៍ (SEAP Games) លើកទី៧ នៅប្រទេសសិង្ហបុរី ឆ្នាំ១៩៧៣ កម្ពុជាបានចូលរួមដោយទទួលបានមេដាយមាស៩ មេដាយប្រាក់១២ និងមេដាយសំរឹទ្ធ២០។
- ឆ្នាំ១៩៧៥ ការប្រកួតកីឡាជ្រោយអាស៊ីអាគ្នេយ៍ (SEAP Games) លើកទី៨កម្ពុជាពុំបានចូលរួមទេ។
- ម៉ាឡេស៊ីបានធ្វើជាម្ចាស់ផ្ទះកីឡាអាស៊ីអាគ្នេយ៍ (SEA Games) ម្តងទៀតនៅឆ្នាំ១៩៧៧ ដោយក្រុមប្រឹក្សាអូឡាំពិកម៉ាឡេស៊ីបានសម្រេចស្នើសុំឱ្យមានគណៈកម្មាធិការជាតិអូឡាំពិកផ្សេងទៀតនៃប្រទេសអាស៊ីអាគ្នេយ៍ចូលរួមប្រកួតផងដែរ។ ដូចនេះ ក្រុមប្រឹក្សាអូឡាំពិកម៉ាឡេស៊ីបានស្នើឱ្យពង្រីកចំនួនសមាជិកភាពរបស់សហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ ពី៨គណៈកម្មាធិការជាតិអូឡាំពិកទៅ១០គណៈកម្មាធិការជាតិអូឡាំពិក ដោយបានអញ្ជើញប្រទេសប្រ៊ុយណេ ឥណ្ឌូនេស៊ីឱ្យចូលរួមក្នុងសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ផងដែរ។ សំណើនេះត្រូវបានគេទទួលយក ហើយកីឡាជ្រោយអាស៊ីអាគ្នេយ៍ (SEAP Games) លើកទី៩ ក៏បានក្លាយទៅជា SEA Games ដោយមាន១០ ប្រទេសចូលរួម។
- ចាប់ពីឆ្នាំ១៩៧៧ដល់១៩៨១ ដោយសារតែសង្គ្រាម កម្ពុជា ឡាវ និងវៀតណាម មិនបានចូលរួមកីឡាអាស៊ីអាគ្នេយ៍ទេ។
- ឆ្នាំ១៩៨៣ ប្រទេសសិង្ហបុរីបានធ្វើជាម្ចាស់ផ្ទះកីឡាអាស៊ីអាគ្នេយ៍ SEA Games ហើយសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍មិនបានអញ្ជើញកម្ពុជាឱ្យចូលរួមប្រកួតទេ ដោយហេតុថាគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាពុំទាន់បានទទួលស្គាល់ជាសមាជិកពេញសិទ្ធិពីគណៈកម្មាធិការអូឡាំពិកអន្តរជាតិ(IOC)ឡើងវិញនៅឡើយ។
- នៅឆ្នាំ១៩៨៩ ម៉ាឡេស៊ីបានរៀបចំធ្វើជាម្ចាស់ផ្ទះកីឡាអាស៊ីអាគ្នេយ៍(SEA Games) លើកទី១៥។ ក្រុមប្រឹក្សាអូឡាំពិកម៉ាឡេស៊ីបានសម្រេចគោរពជំហររបស់គណៈកម្មាធិការអូឡាំពិកអន្តរជាតិនិងសម្រេចចិត្តមិនអញ្ជើញកម្ពុជាឱ្យចូលរួម ប៉ុន្តែបានអញ្ជើញឡាវនិងវៀតណាម ដោយមានការធានាពីក្រុមប្រឹក្សាអូឡាំពិកម៉ាឡេស៊ី។
- កម្ពុជាមិនបានអញ្ជើញឱ្យចូលរួមកីឡាអាស៊ីអាគ្នេយ៍ លើកទី១៦និង១៧ ក្នុងឆ្នាំ១៩៩១និង១៩៩៣ទេ។
- ចាប់ពីឆ្នាំ១៩៩៥ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាត្រូវបានអញ្ជើញឱ្យចូលរួមប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games) លើកទី១៨ នៅទីក្រុងឈៀងម៉ៃប្រទេសថៃឡើងវិញ ដោយសារគណៈកម្មាធិការអូឡាំពិកអន្តរជាតិ/

(IOC) បានទទួលស្គាល់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ជាសមាជិកពេញសិទ្ធិរួចហើយ នាឆ្នាំ១៩៩៤ ហើយកម្ពុជា មានវត្តមានចូលរួមប្រកួតគ្រប់កីឡាអាស៊ីអាគ្នេយ៍(SEA Games)ឡើងវិញ រហូតដល់ពេលបច្ចុប្បន្ន។

III. **លក្ខណៈទូទៅនៃព្រឹត្តការណ៍កីឡាអាស៊ីអាគ្នេយ៍**(SEA Games)

៣.១- ចក្ខុវិស័យ គោលបំណង កម្មវត្ថុ

- ចក្ខុវិស័យ
  - បង្ហាញមុខមាត់កម្ពុជាថ្មីពី GDP ចំណូលមធ្យមកម្រិតទាប ទៅ GDP ចំណូលកម្រិតមធ្យម
  - លើកតម្កើងកេរ្តិ៍ឈ្មោះព្រះរាជាណាចក្រកម្ពុជា និង
  - ដណ្តើមឧត្តមភាពកីឡាអាស៊ីអាគ្នេយ៍(SEA Games) ឆ្នាំ២០២៣ នៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
- **គោលបំណង**
  - រៀបចំកសាងវប្បធម៌សាមគ្គីផ្ទៃក្នុងជាតិ ផ្តុំកម្លាំងជាតិ ដើម្បីបង្ហាញឥទ្ធិពលកីឡាជាតិ។
  - កសាងសក្តានុពលជាតិ តាមរយៈថាមពលនៃព្រឹត្តិការណ៍ប្រកួតពហុកីឡា "Power of SEA Games"។
  - អប់រំអត្ថប្រយោជន៍នៃកីឡាសម្រាប់សង្គមជាតិ និងការអប់រំឧត្តមគតិអូឡាំពិក។
- កម្មវត្ថុ
  - ក្លាយជាព្រឹត្តិការណ៍មួយដ៏រស្មារឿងនិងចងចាំជានិច្ចក្នុងប្រវត្តិសាស្ត្រកីឡាជាតិនិងអន្តរជាតិ។
  - ឱកាសនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡាទុកជាមរតកមនុស្សជាតិនិងយុវជនគ្រប់ជំនាន់
  - កសាងសមត្ថភាព គុណភាពជីវិតប្រជាពលរដ្ឋ។
  - ក្លាយជាប្រទេសមានសក្តានុពលកីឡាក្នុងតំបន់និងលើពិភពលោក។
  - ក្លាយជាប្រទេសមានសក្តានុពលទេសចរណ៍វប្បធម៌ នយោបាយ និងសេដ្ឋកិច្ចក្នុងតំបន់និងពិភពលោក។
  - សូចនាករ : កីឡាអាស៊ីអាគ្នេយ៍(SEA Games) លើកទី៣២ ឆ្នាំ២០២៣ កម្ពុជាត្រូវដណ្តើមយកមេដាយមាសយ៉ាងតិច៣០%នៃចំនួនវិញ្ញាសាទាំងអស់ដែលមានក្នុងកម្មវិធីប្រកួត។

៣.២- លក្ខណៈទូទៅនៃព្រឹត្តិការណ៍

កីឡាអាស៊ីអាគ្នេយ៍(SEA Games)លើកទី៣២នៅព្រះរាជាណាចក្រកម្ពុជា នឹងប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញ និងបណ្តាខេត្តមួយចំនួន(កំពត កែប តាកែវ សៀមរាប បាត់ដំបង និងកំពង់ចាម) ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ ដែលរំពឹងថានឹងមានអ្នកចូលរួមសរុប ប្រមាណ១០ ០០០នាក់ ក្នុងនោះ មានកីឡាករ ប្រមាណ៧ ០០០នាក់ រួមជាមួយមន្ត្រី ប្រតិភូអម ភ្ញៀវអង្គការកីឡា និងភ្ញៀវឥស្សរជនជាន់ខ្ពស់ ដូចជា ក្រុមគ្រួសារចលនាអូឡាំពិក ប្រតិភូគណៈកម្មាធិការអូឡាំពិកអន្តរជាតិ (IOC) ក្រុមប្រឹក្សាអូឡាំពិកអាស៊ី(OCA) សហព័ន្ធកីឡាអន្តរជាតិ (IFs) ក្រុមប្រឹក្សាស៊ីហ្គេម (SEAGF Council) និងអង្គការកីឡាអន្តរជាតិដទៃទៀត ប្រមាណ៣ ០០០នាក់។

ប្រតិភូកីឡាទាំងអស់ត្រូវបានរៀបចំឲ្យស្នាក់នៅក្នុងសណ្ឋាគារឬភូមិកីឡា (Athlete Village) ក្នុងរាជធានីនិងបណ្តាខេត្តមួយចំនួន។

មធ្យោបាយធ្វើដំណើរបម្រើការប្រកួត រួមមានរថយន្តតូចប្រមាណ១០០គ្រឿង(សម្រាប់... ) ឡាន Vans ប្រមាណ១៥០គ្រឿង(សម្រាប់ប្រតិភូបច្ចេកទេសនិងមន្ត្រីជំនាញ) រថយន្តBus១... គ្រឿង...

ក្នុងការរៀបចំការប្រកួតគ្រោងនឹងចំណាយថវិកាប្រមាណ៤០លានដុល្លារអាមេរិក (Operation Cost during the Games) (សម្ភារៈបច្ចេកទេស ឧបករណ៍បច្ចេកទេស និងប្រាក់ឧបត្ថម្ភកម្លាំងពលកម្ម) ដោយមិនរួមបញ្ចូលការរៀបចំពិធីបើកបិទ និងការកសាងហេដ្ឋារចនាសម្ព័ន្ធកីឡា។

**៣.៣- អត្ថប្រយោជន៍នៃការរៀបចំការប្រកួត**កីឡាអាស៊ីអាគ្នេយ៍(SEA Games)**ឆ្នាំ២០២៣**

ព្រឹត្តិការណ៍កីឡាធំៗដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យកីឡាក៏ដូចជាវប្បធម៌ ទេសចរណ៍ នយោបាយ ការទូត និងសេដ្ឋកិច្ចសង្គម។ ព្រឹត្តិការណ៍កីឡាមួយផ្តល់ឱកាសជាច្រើនសម្រាប់ការអភិវឌ្ឍ ដូចជា៖

- ការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គម
- កេរ្តិ៍ឈ្មោះ (Legacy) សម្រាប់ប្រទេសជាតិជាប្រវត្តិសាស្ត្រ
- ជំរុញទឹកចិត្តស្នេហាជាតិ សាមគ្គីភាព និងការគោរពគ្នាទៅវិញទៅមក
- អាចពង្រឹងស្ពានទំនាក់ទំនងការទូត នយោបាយ សេដ្ឋកិច្ចជាមួយប្រទេសក្នុងតំបន់និងពិភពលោក
- ជាឱកាសដ៏កម្រដែលអាចលាងសម្អាតភាពអវិជ្ជមាន អសកម្ម និងបរិស្ថានសង្គម
- ជាការតាំងបង្ហាញមួយសម្រាប់បង្ហាញពីការប្រតិបត្តិសមត្ថភាព គុណភាពរបស់កីឡាករកម្រិតខ្ពស់
- បង្កើនការចូលរួមក្នុងវិស័យកីឡាដែលនាំមកនូវឱកាសក្នុងការដណ្តើមឧត្តមភាពកីឡា
- ផ្តល់ការយកចិត្តទុកដាក់ដល់អត្តពលិក គ្រូបង្វឹក មន្ត្រី និងអ្នកស្ម័គ្រចិត្ត
- ផ្សព្វផ្សាយប្រទេសជាម្ចាស់ផ្ទះនូវឥទ្ធិពលនិងសក្តានុពលជាតិនៅលើឆាកអន្តរជាតិ។

ព្រឹត្តិការណ៍កីឡាធំៗ គួរតែជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍប្រទេសជាតិទាំងមូលរបស់ថ្នាក់ដឹកនាំប្រទេសផងដែរ។ ការកែលម្អគ្រឿងបរិក្ខារ ការរៀបចំកម្មវិធី សុក្រឹតការរដ្ឋបាលកីឡា បច្ចេកទេស ទ្រឹស្តីកីឡាសម្រាប់គ្រូបង្វឹក មន្ត្រី និងអ្នកស្ម័គ្រចិត្ត ពិសេស រៀបចំផែនការរយៈពេលវែងក្នុងការអភិវឌ្ឍកីឡាករគឺជាមុខងារសំខាន់របស់ព្រឹត្តិការណ៍កីឡា។ យុទ្ធសាស្ត្រអភិវឌ្ឍន៍មួយដែលពេញលក្ខណៈនិងលើកទឹកចិត្តដល់ការចូលរួម និងរួមចំណែកពង្រឹងការប្រតិបត្តិសមត្ថភាព គុណភាពគ្រប់កម្រិតដល់វិស័យកីឡា និងគាំទ្រដល់អ្នកឈ្នះមេដាយដែលមានសក្តានុពល ដើម្បីជំរុញដល់ការអភិវឌ្ឍយុវជនក្នុងសង្គម និងក្នុងការចូលរួមក្នុងវិស័យកីឡា។

**លើកកម្ពស់មុខមាត់ក្នុងទីផ្សារពាណិជ្ជកម្មសាកលលោក**

ការធ្វើជាម្ចាស់ផ្ទះព្រឹត្តិការណ៍កីឡាធំៗ អាចជួយលើកកម្ពស់មុខមាត់ក្នុងទីផ្សារសាកលលោក។ ការបង្ហាញខ្លួនលើឆាកអន្តរជាតិ ជួយម្ចាស់ផ្ទះទាក់ទាញវិនិយោគដល់ប្រទេស ក៏ដូចជាការបង្កើនទំហំជំនួញនិងពាណិជ្ជកម្ម ដើម្បីជំរុញក្បាលម៉ាស៊ីនសេដ្ឋកិច្ច។

**បង្កើនការទាក់ទាញទេសចរឲ្យមកទស្សនា**

វាអាចដាក់បញ្ចូលគោលដៅទេសចរណ៍ដែលមិនមានគេស្គាល់ទៅក្នុងផែនទី អាចជួយពង្រឹងឬកែលម្អមុខមាត់ថ្មីរបស់ប្រទេសដើម្បីទាក់ទាញទេសចរ។ ព្រឹត្តិការណ៍កីឡាក៏បាននាំមកនូវភាពសប្បាយរីករាយ រំភើបអស្ចារ្យ និងបានទទួលនូវអារម្មណ៍ប្លែកជាមួយវប្បធម៌ ទំនៀមទម្លាប់ប្រពៃណី និងភ្លក់ម្ហូបអាហារម្ចាស់ផ្ទះជាដើម។

**កែលម្អហេដ្ឋារចនាសម្ព័ន្ធ (ការអភិវឌ្ឍសេដ្ឋកិច្ច)**

ព្រឹត្តិការណ៍កីឡាធំៗ តម្រូវឲ្យមានការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ហើយប្រសិន[illegible]គ្រប់គ្រងត្រឹមត្រូវវាអាចនឹងមានលទ្ធផលវិជ្ជមាននិងយូរអង្វែងដល់សហគមន៍និងប្រទេសជាតិ។ ដើម្បីជ[illegible]អ្នកទស្សនា [illegible]ការ

មន្ត្រី និងអ្នកសារព័ត៌មានទៅទីកន្លែងប្រកួត តម្រូវឲ្យមានការតភ្ជាប់ប្រព័ន្ធគមនាគមន៍ដឹកជញ្ជូន ប្រព័ន្ធព័ត៌មានវិទ្យាសម្បូរបែប។

**លើកកម្ពស់សេដ្ឋកិច្ចរយៈពេលវែង**

ព្រឹត្តិការណ៍កីឡាធំៗអាចជះឥទ្ធិពលយ៉ាងឆាប់រហ័សនិងមានរយៈពេលវែងដល់សេដ្ឋកិច្ច។ សកម្មភាពនិងការវិនិយោគតម្រូវឲ្យមាន ទាំងមុនពេល ក្នុងកំលុងពេល និងពេលបន្ទាប់ពីព្រឹត្តិការណ៍ដែលផ្តល់ឱកាសនិងបង្កើនការងារបានយ៉ាងច្រើនពិសេស បង្កើតឱកាសជំនួញថ្មីៗដល់ក្រុមហ៊ុនឯកជន។

ហេដ្ឋារចនាសម្ព័ន្ធដែលបានកែលម្អរួចក៏អាចទាក់ទាញក្រុមហ៊ុនថ្មីៗនិងអាចឲ្យប្រជាជននិងពាណិជ្ជករធ្វើអាជីវកម្មកាន់តែមានប្រសិទ្ធភាពផងដែរ។ គម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗជាច្រើន(គមនាគមន៍និងទូរគមនាគមន៍) និងការកែលម្អទីក្រុងទាំងមូល គឺជាការជំរុញដល់ទីក្រុងក្នុងការទាក់ទាញពាណិជ្ជកម្មនិងទេសចរណ៍។

**លើកកម្ពស់កេរ្តិ៍ឈ្មោះរបស់រាជរដ្ឋាភិបាលនិងការដឹកនាំ(រាជរដ្ឋាភិបាលនិងនយោបាយ)**

ព្រឹត្តិការណ៍កីឡាធំៗមិនត្រឹមតែជួយលើកមុខមាត់ទីក្រុងឬប្រទេសជាម្ចាស់ផ្ទះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកមុខមាត់របស់រដ្ឋាភិបាលនិងអ្នកដឹកនាំ ដែលជួយគាំទ្រឲ្យព្រឹត្តិការណ៍កីឡាអន្តរជាតិកើតឡើងផងដែរ។ ដូចជាករណីប្រទេសឡាវ ប្រទេសប្រេស៊ីល ដែលលោកប្រធានាធិបតី Luiz Inácio Lula da Silva បានទទួលប្រជាប្រិយភាព និងកិត្យានុភាពយ៉ាងខ្លាំង ក្នុងនយោបាយដោយសារប្រេស៊ីលត្រូវទទួលធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាបាល់ទាត់ពិភពលោក (FIFA World Cup) ឆ្នាំ២០១៤ និងកីឡាអូឡាំពិករដូវក្តៅ ឆ្នាំ២០១៦ ដោយជោគជ័យ។ សេដ្ឋកិច្ចវិទូបានទស្សន៍ទាយថាប្រេស៊ីលនឹងក្លាយជាមហាអំណាចសេដ្ឋកិច្ចមួយនៅលើពិភពលោកក្រោយឆ្នាំ២០១៦ ក្នុងឋានៈជាប្រទេស "BRICS" ។

**ការស្រុះស្រួលមតិនិងកិច្ចសហការកាន់តែប្រសើរ**

ព្រឹត្តិការណ៍កីឡាធំៗ បង្កើតបានជាវេទិកាមួយសម្រាប់ការបង្រួបបង្រួមនិងកិច្ចសហប្រតិបត្តិការក្នុងនយោបាយរបស់រាជរដ្ឋាភិបាល និងផ្តល់ឱកាសមួយសម្រាប់កិច្ចសហការរវាងវិស័យឯកជននិងវិស័យសាធារណៈ។

**រាជរដ្ឋាភិបាលកាន់តែមានប្រសិទ្ធភាព**

តម្រូវការនិងការកំណត់ពេលវេលាដ៏ម៉ឺងម៉ាត់ក្នុងព្រឹត្តិការណ៍ធំៗ ជំរុញឲ្យរាជរដ្ឋាភិបាលទទួលយកការសម្រេចចិត្តនិងប្រតិបត្តិការកាន់តែមានប្រសិទ្ធភាព។ មេរៀននិងឥរិយាបថដែលបានរៀនសូត្រអាចជួយឲ្យរាជរដ្ឋាភិបាលពង្រឹងវិធីសាស្ត្រប្រតិបត្តិនាពេលអនាគត។

**បង្កើនមោទនភាពមូលដ្ឋាននិងមុខមាត់ខ្លួនឯង (សង្គម និងឥរិយាបថ)**

ព្រឹត្តិការណ៍កីឡាធំៗអាចកែប្រែទស្សនៈរបស់ប្រជាជននៅក្នុងទីក្រុងឬប្រទេសម្ចាស់ផ្ទះ ចំពោះពួកគេផ្ទាល់ និងសហគមន៍របស់ពួកគេ។ ឧទាហរណ៍ ទីក្រុង Barcelona មានកេរ្តិ៍ឈ្មោះមិនល្អក្នុងទស្សនៈរបស់អ្នករស់នៅទីក្រុង Madrid ជាច្រើនសតវត្សមកហើយ។ ប៉ុន្តែ បន្ទាប់ពីការធ្វើជាម្ចាស់ផ្ទះកីឡាអូឡាំពិក ឆ្នាំ១៩៩២ ទីក្រុងនិងប្រជាជនបានទទួលកេរ្តិ៍ឈ្មោះយ៉ាងធំធេង ដែលអាចជួយឲ្យពួកគេទទួលបាននូវភាពស្មើគ្នាជាមួយនឹងទីក្រុងល្បីល្បាញផ្សេងៗទៀតនៅអឺរ៉ុប។

រីឯទីក្រុងប៉េកាំង ធ្លាប់ជាទីក្រុងកខ្វក់បំពុល ទឹកមាត់ ហាលខោអាវ គ្មានសណ្តាប់ធ្នាប់ ក្លាយជាទីក្រុងស្អាត បរិស្ថានល្អប្រសើរ ក្រោយកីឡាអូឡាំពិកឆ្នាំ២០០៨។

**គុណភាពជីវិតកាន់តែប្រសើរ**

ដើម្បីទទួលការចាប់អារម្មណ៍ ទីក្រុងឬប្រទេសជាម្ចាស់ផ្ទះ ត្រូវមានការលើកទឹកចិត្តយ៉ាងខ្លាំងក្លាក្នុងការដោះស្រាយបញ្ហាដូចជា បទឧក្រិដ្ឋ ភាពក្រីក្រ និងភាពទន់ខ្សោយរបស់ទីក្រុង។ ទីក្រុងមួយចំនួនតែងតែព្យាយាមបិទបាំងបញ្ហាទាំងនោះពីទស្សនីយភាព។ ប៉ុន្តែទីក្រុងផ្សេងទៀតប្រើប្រាស់ព្រឹត្តិការណ៍នេះ ឲ្យទៅជាកាតាលីករមួយ ដើម្បីកែលម្អឲ្យកាន់តែប្រសើរជាងមុន ។

**ជាគំរូសម្រាប់ឥរិយាបថថ្មី**

ព្រឹត្តិការណ៍កីឡាធំៗនាំមកនូវឱកាសល្អៗក្នុងការផ្លាស់ប្តូរការគិតនិងឥរិយាបថរបស់ប្រជាជន។ ឧទាហរណ៍ បរិស្ថាន និងតំបន់បៃតង។ ដូច្នេះការកំណត់“ឥរិយាបថថ្មី”បន្តទៀត គឺជាកត្តាសំខាន់។ កីឡាស្អាតស្អំនិងបៃតង “Clean and Green Sport” គឺជាប្រធានបទដ៏សំខាន់ដែលត្រូវបានសង្កត់ធ្ងន់ក្នុងពេលដេញថ្លៃធ្វើជាម្ចាស់ផ្ទះកីឡាអូឡាំពិកឆ្នាំ២០១៦ និងឆ្នាំ២០២០។ បន្ទាប់មក ព្រឹត្តិការណ៍កីឡាធំៗភាគច្រើនបានផ្តោតសំខាន់លើការអភិវឌ្ឍដែលមានចីរភាពនិងការអប់រំបរិស្ថាន។

## IV. ផែនការមុនព្រឹត្តការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)នៅកម្ពុជា

### ៤.១- ការកំណត់ប្រភេទកីឡា

យោងតាមធម្មនុញ្ញសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ “SEAGF Charter” ប្រភេទកីឡាដែលត្រូវដាក់បញ្ចូលក្នុងកម្មវិធីប្រកួតកីឡាស៊ីហ្គេម ត្រូវបានបែងចែកជា៣ចំណាត់ថ្នាក់ (Three Categories) និងបានកំណត់ថា គណៈកម្មាធិការអូឡាំពិកជាតិជាម្ចាស់ផ្ទះត្រូវរៀបចំការប្រកួតយ៉ាងតិច២២ប្រភេទកីឡា និងត្រូវគោរពតាមគោលការណ៍ចំណាត់ថ្នាក់ប្រភេទកីឡាដូចខាងក្រោម៖

- ចំណាត់ថ្នាក់ទី១ មាន ២ប្រភេទកីឡា ត្រូវមានជាចាំបាច់
- ចំណាត់ថ្នាក់ទី២ មាន ៣៧ប្រភេទកីឡា ត្រូវមានយ៉ាងតិច១៤ប្រភេទកីឡា
- ចំណាត់ថ្នាក់ទី៣ មាន ១៦ប្រភេទកីឡា ត្រូវមានយ៉ាងតិច ២ប្រភេទកីឡា យ៉ាងច្រើន ៨ប្រភេទកីឡា ។

កម្មវិធីកីឡានៅក្នុងកីឡាអាស៊ីអាគ្នេយ៍(SEA Games) ត្រូវផ្តល់អាទិភាពទៅលើប្រភេទកីឡាអូឡាំពិក កីឡាអាស៊ីដែលបានបញ្ចូលក្នុងកម្មវិធីរបស់គណៈកម្មាធិការអូឡាំពិកអន្តរជាតិ (IOC) និងក្រុមប្រឹក្សាអូឡាំពិកអាស៊ី (OCA)។

ក្នុងស្ថានភាពសេដ្ឋកិច្ចសង្គម ហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និងបទពិសោធរហូតដល់ឆ្នាំ២០២៣ កម្ពុជាអាចទទួលយកត្រឹមតែ៣០ទៅ៣៥ប្រភេទកីឡា ដែលកម្ពុជាមានសក្តានុពល ដើម្បីដាក់ក្នុងកម្មវិធីប្រកួត ពីព្រោះគណៈកម្មាធិការអូឡាំពិកជាតិជាម្ចាស់ផ្ទះមានសិទ្ធិ កំណត់ចំនួនប្រភេទកីឡានិងវិញ្ញាសាកីឡាដោយឯកតោភាគីតាម “SEAGF Charter”។ ការកំណត់ប្រភេទកីឡានេះ ពាក់ព័ន្ធទៅនឹងការរៀបចំហេដ្ឋារចនាសម្ព័ន្ធកីឡា សម្ភារៈឧបករណ៍កីឡា ការរៀបចំគម្រោងចំណាយថវិកា និងការបណ្តុះបណ្តាលធនធានមនុស្សជំនាញកីឡា។ល។

ចំពោះប្រភេទកីឡាដែលត្រៀមលក្ខណៈបញ្ចូលក្នុងកម្មវិធីប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games) ឆ្នាំ២០២៣ ចំនួនពី៣០ទៅ៣៥ ប្រភេទមានដូចខាងក្រោម៖

**ក- ចំណាត់ថ្នាក់ទី១ : កីឡាចាំបាច់** “Compulsory Sport”

១. អត្តពលកម្ម (Athletics)

២. កីឡាលើទឹក “ក្នុងអាង” (Swimming, Diving, Water Polo...etc.)

**ខ- ចំណាត់ថ្នាក់ទី២**: កីឡាមានក្នុងកីឡាអូឡាំពិកនិងកីឡាអាស៊ី(យ៉ាងតិច១៤ប្រភេទកីឡា) (Sports in the Olympic Games and the Asian Games)

១. តេក្វាន់ដូ (Taekwondo)
២. ចំបាប់ (Wrestling)
៣. បាល់ទាត់ (Football)
៤. បាល់ទះ (Volleyball)
៥. វាយកូនបាល់ (Tennis)
៦. វាយកូនឃ្លីលើតុ (Table Tennis)
៧. បាញ់កាំភ្លើង (Shooting)
៨. ការ៉ាតេដូ (Karate-do)
៩. កាយសម្ព័ន្ធ (Gymnastics)
១០. ហុកគី (Hockey)
១១. បាញ់ធ្នូ (Archery)
១២. ប្រដាល់សកល (Boxing)
១៣. ប្រណាំងទោចក្រយាន (Cycling)
១៤. យូដូ (Judo)
១៥. Ice Skating
១៦. ស៊ីប៉ាក់តាក្រ-ឈីនឡូន (Sepak Takraw-Chinlone)
១៧. Soft Tennis
១៨. គុនដាវ (Fencing)
១៩. វាយកូនគោល (Golf)
២០. វ៉ូស៊ូ (Wushu)
២១. ទ្រីយ៉ាត្លុង (Triathlon)
២២. វាយសី (Badminton)
២៣. បាល់បោះ (Basketball)
២៤. ទូកកានូ (Canoeing)
២៥. កីឡាជិះសេះ (Equestrian)។

**គ- ចំណាត់ថ្នាក់ទី៣**: ប្រភេទកីឡាផ្សេងៗ (យ៉ាងតិច២ប្រភេទ និងយ៉ាងច្រើន៨ប្រភេទកីឡា)

១. ក្បាច់គុន (Fighting + Demo)
២. ប៉េតង់ (Petanque)
៣. ប្រណាំងទូកប្រពៃណី (Traditional Boat Race)
៤. វ៉ូវីណាម (Vovinam)

- ❖ ប្រភេទកីឡាទាំង៣០ប្រភេទនេះគឺជាការគ្រោងទុក ហើយអាចមានការប្រែប្រួលក្នុងដំណាក់កាលសម្រេចចុងក្រោយ ហើយទុកលទ្ធភាព ៥ប្រភេទកីឡាទៀតឱ្យប្រទេសជាសមាជិកស្នើសុំ "Lobby"។
- ❖ កម្ពុជាក្នុងនាមម្ចាស់ផ្ទះនឹងរៀបចំឱ្យមានការសម្តែងកីឡា(Demonstration Sport) ចំនួន១ (អុកចត្រង្គ) តាមការកំណត់របស់ធម្មនុញ្ញ SEAGF។

## ៤.២- ហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈ ឧបករណ៍ហ្វឹកហាត់

### ៤.២.១- ហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធកីឡាគឺជាផ្នែកដ៏សំខាន់បំផុត ពីព្រោះវាត្រូវការចំណាយថវិកាយ៉ាងសន្ធឹកសន្ធាប់និងត្រូវការពេលវេលាយូរដើម្បីធ្វើផែនការនិងស្ថាបនាឡើង។ ហេដ្ឋារចនាសម្ព័ន្ធចែកជា៣ផ្នែកសំខាន់គឺ ហេដ្ឋារចនាសម្ព័ន្ធលើប្រភេទកីឡាឯកទេស(ត្រូវការទីលានកីឡាពិសេស) ហេដ្ឋារចនាសម្ព័ន្ធពហុកីឡា ហេដ្ឋារចនាសម្ព័ន្ធកីឡាសាធារណៈ (ឧ.កោះពេជ្រ ទីធ្លាសាធារណៈដទៃទៀត)។

- ក្នុងកម្មវិធីប្រកួតជាអន្តរជាតិ កីឡាលើទឹក "ក្នុងអាង" "Aquatics" និងអត្តពលកម្ម "Athletics" គឺមានតម្រូវការហេដ្ឋារចនាសម្ព័ន្ធមុនគេ និងពិសេសជាងគេដោយអាងទឹកសាងសង់តាមខ្នាតនិងមាត្រដ្ឋានបច្ចេកទេសអន្តរជាតិក្នុងសាល រីឯអត្តពលកម្ម ត្រូវការកីឡដ្ឋានមានផ្លូវរត់ជុំវិញ និងទីលានវិញ្ញាសាផ្សេងៗស្តង់ដារតាមស្តង់ដារបច្ចេកទេសអន្តរជាតិ "IAAF"។

- ហេដ្ឋារចនាសម្ព័ន្ធដែលសំខាន់មួយទៀត គឺទីលានបាញ់កាំភ្លើងដែលមានទីលានក្នុងសាលនិងក្រៅសាល។ ទីលានក្នុងសាល កសាងតាមលក្ខណៈបច្ចេកទេសពិសេស ដាច់ដោយឡែកប្រើសម្រាប់តែកីឡាបាញ់កាំភ្លើង និងក្រៅសាល ក៏ត្រូវការទីលានធំ មានរបាំងកូនភ្នំឬលើកដីទួលខ្ពស់ជាមួយនឹងទីលានបាញ់ពិសេស។
- ប្រភេទកីឡាដែលតម្រូវឲ្យមានហេដ្ឋារចនាសម្ព័ន្ធពិសេសបន្ថែមទៀតគឺ កីឡាវាយកូនគោល កីឡាហុកគី កីឡាវាយកូនបាល់ និងកីឡាប្រណាំងកង់ផ្លូវវង្វង់ "Velodrom" ។
- កីឡាប្រណាំងកង់ "Road Bike"៖ លើដងផ្លូវ មិនត្រូវការហេដ្ឋារចនាសម្ព័ន្ធពិសេសទេ(ចេញពីកំពង់ចាមឆ្ពោះមកពហុកីឡដ្ឋានជាតិមរតកតេជោ (ចម្ងាយពី១០០គ.ម. ទៅ ១៦០គ.ម.)។
- កីឡាប្រណាំងទោចក្រយានឡើងភ្នំ "MTB" ៖ ត្រូវការទីលានរៀបចំនៅតំបន់ភ្នំដោយរៀបចំតាមបែបធម្មជាតិនូវរាល់ឧបសគ្គទាំងឡាយ(កីឡាជិះកង់លើភ្នំ នៅរមណីយដ្ឋានគិរីរម្យ) ។
- កីឡាលើទឹកដូចជា កីឡាទូកកានូ កាយ៉ាក កីឡា Rowing កីឡាទូកក្ដោង "Sailing" កីឡាទូកប្រពៃណីត្រូវការបឹង អាងស្តុកទឹក ទន្លេធំ និងសមុទ្រ ជាទីលានប្រណាំងតែត្រូវការតុបតែងបំពាក់ឧបករណ៍សម្ភារៈបច្ចេកទេសចាំបាច់មួយចំនួន(អាចធ្វើនៅកំពត កែប ទន្លេបាទី។ ដោយឡែក ទូកក្ដោងគ្រប់ប្រភេទធ្វើនៅសមុទ្រក្នុងពេលអាកាសធាតុមានខ្យល់គ្រប់គ្រាន់(កែប)។(នៅកំពត នៅព្រែកសមុទ្រទីរួមខេត្ត ឬទន្លេបាទីខេត្តតាកែវ (អ្នកបច្ចេកទេសបានពិនិត្យថា ជាទីតាំងល្អ) Set up តង់បណ្តោះអាសន្ន។
- កីឡាទ្រីយ៉ាត្លុង មិនត្រូវការកសាងហេដ្ឋារចនាសម្ព័ន្ធពិសេសទេ ប៉ុន្តែត្រូវការរៀបចំទីតាំងពិសេស ដូចជាទីចេញដំណើរ និងបញ្ចប់ (បឹងឬសមុទ្រសម្រាប់ហែលទឹក ផ្លូវប្រណាំងកង់ និងផ្លូវរត់ប្រណាំង)។
- កីឡាបាញ់ធ្នូ ត្រូវការទីធ្លាសមស្របតាមទំហំបទដ្ឋានបច្ចេកទេសមួយតែប៉ុណ្ណោះ (បំពាក់សម្ភារៈឧបករណ៍បច្ចេកទេស និងតុបតែងបិទបាំងទីលានតាមទំហំបច្ចេកទេស ជាការស្រេច)។
- កីឡាបាល់ឱប អាចកែច្នៃនិងប្រើប្រាស់ទីលានកីឡាបាល់ទាត់បាន។
- កីឡាបាល់ទាត់ អាចប្រើប្រាស់ទីលានបាល់ទាត់ក្នុងកីឡដ្ឋាននិងក្រៅកីឡដ្ឋាន ដែលមានស្តង់ដាបច្ចេកទេសត្រឹមត្រូវ។
- កីឡាស្គីទឹកកក "Ice-Skating" ត្រូវការទីលានពិសេស មានកម្រាលទឹកកកពិសេស។

សម្រាប់កីឡាផ្សេងៗទៀត ភាគច្រើនតម្រូវឲ្យមានសាល "Hall សាធារណៈ" ឬ កីឡដ្ឋានក្នុងសាល "Indoor Stadium" ហើយសាលនេះអាចសាងសង់ ដែលអាចប្រើប្រាស់បានច្រើនប្រភេទកីឡា និងអាចមានសារៈសំខាន់សម្រាប់កីឡានីមួយៗ។ កីឡាដែលត្រូវការសាល មានដូចជា កីឡាវាយសី កីឡាបាល់បោះ កីឡាប្រដាល់ កីឡាគុនដាវ កីឡាកាយសម្ព័ន្ធ កីឡាយូដូ កីឡាការ៉ាតេដូ កីឡាប្រដាល់ក្បាច់គុន ល្បុក្កតោ កីឡាប្រដាល់សកល កីឡាបញ្ចសិលា កីឡាស៊ីប៉ាក់តាក្រ-ឈីនឡូន កីឡាតេក្វាន់ដូ កីឡាវាយកូនឃ្លីលើតុ កីឡាបាល់ទះ កីឡាលើកទម្ងន់ កីឡាកាយវប្បកម្ម កីឡាចំបាប់ និងកីឡាវូស៊ូ។ល។ ប្រភេទកីឡាខ្លះអាចបង្កើតទីលានបណ្តោះអាសន្នលើទីធ្លាសាធារណៈ ដូចជា បាល់ទះ ឆ្នេរខ្សាច់ ប៉េតង់ ម៉ារ៉ាតុង ទ្រីយ៉ាត្លុង ប្រណាំងកង់ ជាដើម។

អាចប្រើប្រាស់មជ្ឈមណ្ឌលអនុសញ្ញាថ្នាក់ខ្ពស់ (Excel Convention Centre) ដែលមានបំពាក់គ្រឿងបរិក្ខារព័ត៌មានវិទ្យា គ្រឿងបំពងសំឡេងស្រាប់សម្រាប់កីឡាប្រយុទ្ធ កីឡាវាយកូនឃ្លីលើតុ។ល។ កម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games) ឆ្នាំ២០២៣ ដូច្នេះហេដ្ឋារចនាសម្ព័ន្ធកីឡាទាំងអស់ ត្រូវអាចឆ្លើយតប[illegible]

ប្រាស់បាននាឆ្នាំ២០១៩ ឬ២០២០ មានន័យថា ការប្រើប្រាស់សាកល្បង និងការរៀបចំបន្សាំកសាងគុណភាពបច្ចេកទេសកីឡាត្រូវការរយៈពេល៤ឆ្នាំ ក៏ដូចជាការធ្វើសុក្រឹតការគុណផលកីឡា (Performance) ត្រូវការរយៈពេល៤ឆ្នាំផងដែរ។

**៤.២.២- សម្ភារៈ ឧបករណ៍ហ្វឹកហាត់**

| | |
|---|---|
| **ការហ្វឹកហាត់កម្រិតជំនាញ** | តម្រូវឱ្យមានសម្ភារៈឧបករណ៍ស្តង់ដាកម្រិតមធ្យមនិងសមស្របតាមបច្ចេកទេសប្រភេទកីឡានិងវិញ្ញាសានីមួយៗ។ |
| **កីឡាជំនាញកម្រិតខ្ពស់** | ត្រូវការសម្ភារៈ និងទីលានហ្វឹកហាត់ ស្តង់ដា និងតាមនិយាម បច្ចេកទេសសហព័ន្ធកីឡាអន្តរជាតិ។ |
| **សម្រាប់ការប្រកួត** | ត្រូវការសម្ភារៈឧបករណ៍ដែលមានលក្ខណៈស្តង់ដាអន្តរជាតិ ដែលមានការធ្វើទំនើបកម្មតាមបទប្បញ្ញត្តិរបស់សហព័ន្ធអន្តរជាតិ“IFs” ។ ឧបករណ៍ សម្ភារៈ និងសម្លៀកបំពាក់កីឡាទំនើប គុណភាពខ្ពស់ អាចជួយដល់គុណផល(Performance)និងលើកកម្ពស់ចិត្តសាស្ត្រកីឡាករ។ ឧបករណ៍ សម្ភារៈ និងសម្លៀកបំពាក់មានពីរប្រភេទ គឺសម្រាប់បម្រើបច្ចេកទេសក្នុងពេលប្រកួតតាមប្រភេទកីឡានិងវិញ្ញាសាកីឡានីមួយៗ និងឧបករណ៍ សម្ភារៈ សម្លៀកបំពាក់ទូទៅ ប្រើប្រាស់រួមគ្នា (បម្រើ ក្នុង Gym - អាវសម្រកទម្ងន់ ជញ្ជីងថ្លឹងទម្ងន់ ...)។ |

**៤.៣- ការបណ្តុះបណ្តាលធនធានមនុស្ស**

**៤.៣.១- ការបណ្តុះបណ្តាលកីឡាករ**

កីឡាករជាតួអង្គសំខាន់ក្នុងវិស័យកីឡាដែលត្រូវយកចិត្តទុកដាក់មុនគេ អាទិភាពជាងគេ និងបណ្តាក់ទុនច្រើនជាងគេ។ ការបណ្តុះបណ្តាលតម្រង់ទិសអាចធ្វើបានគ្រប់ប្រភេទកីឡានិងប្រភេទវិញ្ញាសាទាំងអស់សម្រាប់កីឡាករចាប់ពី **អាយុ៦ឆ្នាំឡើងទៅ(៦-១២ឆ្នាំ)** ហើយកីឡាករចាប់ពី**អាយុ១៣-១៥ឆ្នាំឡើងទៅ** អាចត្រៀមលក្ខណៈចូលរួមក្នុងការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games) ឆ្នាំ២០២៣។

- ដើម្បីស្វែងរកបរិមាណកីឡាករវ័យក្មេងត្រូវ៖
  - យកមូលដ្ឋានគ្រឹះស្ថានសិក្សាគឺ សិស្ស និស្សិតពីបឋមដល់ឧត្តមសិក្សា ដោយបញ្ចូលកម្មវិធីកីឡាតម្រង់ទិសកីឡាជំនាញក្រៅម៉ោងសិក្សា “Out Curriculum”។
  - ក្លឹបកីឡាគ្រប់ប្រភេទរបស់សហព័ន្ធកីឡាជាតិត្រូវបង្កើតកម្មវិធី “កីឡាដើម្បីទាំងអស់គ្នា - Sport for All” ប្រមូលកុមារ និងយុវវ័យក្រៅប្រព័ន្ធសិក្សា ឱ្យចូលរួមធ្វើការហ្វឹកហាត់តម្រង់ទិសជំនាញកីឡារបស់ខ្លួន។
  - បង្កើត “សាលាកីឡាឧបនិស្ស័យ” “Talent Sport School” ។
- ដើម្បីស្វែងរកគុណភាពកីឡាករវ័យក្មេងត្រូវ៖
  - ជ្រើសរើសសិស្ស និស្សិតមានទេពកោសល្យកីឡាតាមរយៈលក្ខខណ្ឌវិទ្យាសាស្ត្រកីឡា ដើម្បីធ្វើការប្រមូលផ្តុំ និងបញ្ចូលកម្មវិធីជំនាញកម្រិតខ្ពស់ដល់ពួកគេ។

- ជ្រើសរើសកីឡាករវ័យក្មេងមានទេពកោសល្យ ពីក្លឹបកីឡានីមួយៗរបស់សហព័ន្ធដាក់ក្នុងការដឹកនាំគ្រប់គ្រងដោយឡែក ដើម្បីជំរុញកម្រិតជំនាញឲ្យកាន់តែខ្ពស់បន្ថែមទៀត។
- បង្កើតការប្រកួតតាមកម្រិតអាយុនិងកម្រិតបច្ចេកទេសឲ្យបានច្រើន និងបញ្ជូនចូលរួមការប្រកួតជាអន្តរជាតិតាមកម្រិត ដើម្បីទទួលបានបទពិសោធប្រកួត។
- បញ្ជូនទៅធ្វើការហ្វឹកហាត់កីឡាជំនាញក្រៅប្រទេស សម្រាប់រយៈពេលខ្លី មធ្យម និងវែង។
- រៀបចំប្រមូលផ្តុំក្រុមជម្រើសជាតិជាពីរក្រុមគឺ ក្រុមអាយុក្រោម១៨ឆ្នាំ និងអាយុ១៨ឆ្នាំឡើង ចាប់ពីឆ្នាំ២០១៦ ជារៀងរាល់ឆ្នាំ។
- ស្វែងរកកីឡាករវ័យក្មេងនៅក្រៅប្រព័ន្ធគ្រឹះស្ថានសិក្សា ដើម្បីផ្តល់ឱកាស និងជ្រើសរើសអ្នកមានទេពកោសល្យឲ្យចូលក្នុងក្លឹបហ្វឹកហាត់កីឡាជំនាញផ្ទាល់ ក្រោមការគ្រប់គ្រងរបស់សហព័ន្ធកីឡាជាតិ។

**៤.៣.២- ការបណ្តុះបណ្តាលគ្រូបង្វឹក**

គ្រូអប់រំកាយនិងកីឡា គឺជាគ្រូបណ្តុះបណ្តាលសកម្មភាពអប់រំកាយនិងកីឡា និងបង្ហាត់កីឡាតម្រង់ទិសនៅក្នុងគ្រឹះស្ថានសិក្សាទាមទារឲ្យមានគរុកោសល្យអប់រំកាយ និងកីឡាច្បាស់លាស់។ ចាប់ពីឆ្នាំ២០១៦ទៅ គ្រូក្រុមខណ្ឌអប់រំកាយ និងកីឡា ត្រូវសហការជាមួយសហព័ន្ធកីឡាជាតិ ដើម្បីជ្រើសរើសប្រភេទកីឡាជំនាញមួយមុខ និងរៀបចំកម្មវិធីហ្វឹកហាត់កីឡាតម្រង់ទិស កីឡាជំនាញ នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួន (បែងចែកទៅសាលា Sport talent school និងគ្រឹះស្ថានសិក្សា)។ រៀបចំឲ្យមានវគ្គវិក្រឹតការ ឬសិក្ខាសាលាអប់រំកាយ និងកីឡា នៅតាមភូមិភាគ(៥មណ្ឌល) ឲ្យបានយ៉ាងតិច២ដងក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១៦តទៅ។

គ្រូបង្វឹកកីឡាជំនាញកម្រិតខ្ពស់ស្ថិតក្រោមការគ្រប់គ្រងរបស់សហព័ន្ធត្រូវឆ្លងកាត់វគ្គឬមានសញ្ញាបត្រគ្រូជំនាញប្រចាំប្រភេទកីឡារបស់ខ្លួនពីសហព័ន្ធកីឡាជាតិឬសហព័ន្ធកីឡាអន្តរជាតិ។ បច្ចុប្បន្ន សហព័ន្ធកីឡាជាតិភាគច្រើនមិនមានគ្រូកម្រិតអន្តរជាតិទេ។

គ្រូជំនាញថ្នាក់ជាតិភាគច្រើន ចំណេះដឹងខាងផ្នែកជំនាញបច្ចេកទេសនៅមានកម្រិត (ពិសេសភាសាបរទេសជាឧបសគ្គក្នុងការធ្វើបច្ចុប្បន្នកម្មជំនាញបច្ចេកទេសរបស់ខ្លួន)។ ដូច្នេះ ត្រូវការវគ្គបណ្តុះបណ្តាលគ្រូជំនាញនិងបង្កើនបទពិសោធ ទ្រឹស្តីកីឡាជំនាញ ពិសេស បណ្តុះបណ្តាលផ្នែកភាសា។ រៀបចំឲ្យមានគ្រូបរទេសដែលមានលក្ខណសម្បត្តិ និងកម្រិតបទពិសោធបច្ចេកទេសខ្ពស់ក្នុងប្រភេទកីឡា ដែលមានសក្តានុពលមួយចំនួន ចាប់ពីឆ្នាំ២០១៦តទៅ។ បច្ចុប្បន្នមានតែគ្រូបរទេសពីរបីនាក់ប៉ុណ្ណោះ(បាល់ទាត់ តេក្វាន់ដូ ចំបាប់)។ សហព័ន្ធកីឡាជាតិ ត្រូវរៀបចំបណ្តុះបណ្តាលគ្រូតាមកម្រិតនិងតាមវ័យ។

ជំនួយការគ្រូបង្វឹក រួមមានគ្រូជំនួយផ្នែកបច្ចេកទេស គុណភាពកម្លាំងកាយ ចិត្តសាស្ត្រកីឡា វេជ្ជបណ្ឌិតកីឡា (ពេទ្យកីឡា) អ្នកម៉ាស្សា និងអ្នកព្យាបាលដោយចលនា “Physiotherapist”។ ជំនួយការទាំងអស់នេះ ត្រូវមានជំនាញច្បាស់លាស់ក្នុងផ្នែកកីឡា។

គ្រូបង្វឹកត្រូវតាមដាននិងអនុវត្តតាមការប្រែប្រួលនិងផ្លាស់ប្តូរបច្ចេកទេស បទបញ្ញាការប្រកួត និងច្បាប់ល្បែងរបស់សហព័ន្ធកីឡាអន្តរជាតិ។ សហព័ន្ធជាតិ ត្រូវសហការជាមួយគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ដើម្បីស្នើសុំការជួយគាំទ្រលក្ខណៈបច្ចេកទេស (Technical Assistance Program) ពីសហព័ន្ធអន្តរជាតិក្នុងការស្វែងរកគ្រូបរទេស និងវគ្គបណ្តុះបណ្តាល ពិសេស សម្រាប់គ្រូបង្វឹកកីឡាជំនាញកម្រិតខ្ពស់។/ស

**៤.៣.៣- ការបណ្តុះបណ្តាលមន្ត្រីកីឡា** (មន្ត្រីជំនាញ មន្ត្រីរដ្ឋបាល អាជ្ញាកណ្តាល ចៅក្រម)

មន្ត្រីជំនាញទទួលបន្ទុករៀបចំបច្ចេកទេសប្រកួត រៀបចំរូបមន្តប្រកួត រៀបចំទីលានប្រកួត រៀបចំឯកសារ ដាក់ពិន្ទុ រៀបចំរបាយការណ៍បច្ចេកទេស(បច្ចុប្បន្ន នៅមានការខ្វះខាតមន្ត្រីកីឡាជំនាញមួយចំនួន បម្រើការក្នុងប្រភេទកីឡាច្រើនមុខ) ត្រៀមបណ្តុះបណ្តាលមន្ត្រីសហព័ន្ធកីឡាជាតិ ឲ្យបានគ្រប់ប្រភេទកីឡាទៅតាមតម្រូវការនិយាមបច្ចេកទេស និងតម្រូវការចាំបាច់ជាក់ស្តែង។ (ខ្វះប្រមាណ៦០%) សហព័ន្ធត្រូវរៀបចំមន្ត្រីរបស់ខ្លួន ដើម្បីបណ្តុះបណ្តាលឲ្យក្លាយជាមន្ត្រីជំនាញកីឡាយ៉ាងតិច២០នាក់ រហូតដល់ឆ្នាំ២០២៣ (១ឆ្នាំ ត្រូវបណ្តុះបណ្តាលយ៉ាងតិច២នាក់ឬ៣នាក់)។

មន្ត្រីរដ្ឋបាលទទួលបន្ទុករៀបចំឯកសារច្បាប់ល្បែង (Rule of the Games) បទបញ្ជាការប្រកួត (Regulation) ក្រមសីលធម៌កីឡា និងគោលការណ៍លេងដោយយុត្តិធម៌ Fair-Play គួរបែងចែកមន្ត្រីជំនាញនិងមន្ត្រីគាំទ្រឲ្យបានច្បាស់លាស់។

អាជ្ញាកណ្តាល ចៅក្រម ជាអ្នកវិនិច្ឆ័យការប្រកួត ការពារបទបញ្ជាការប្រកួត ក្រមសីលធម៌កីឡា និងគោលការណ៍លេងដោយយុត្តិធម៌ (Fair-Play)។ អាជ្ញាកណ្តាលថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ដែលសហព័ន្ធត្រូវរៀបចំឲ្យមានចំនួនណាមួយដែលបច្ចេកទេសត្រូវការ ដើម្បីបម្រើឲ្យការប្រកួត។ អាជ្ញាកណ្តាលថ្នាក់អន្តរជាតិ(ថ្នាក់របស់អាជ្ញាកណ្តាលប្រែប្រួលទៅតាមសហព័ន្ធអន្តរជាតិរបស់ខ្លួន)ថ្នាក់តំបន់ ថ្នាក់ទ្វីប ថ្នាក់ពិភពលោក។

ត្រូវបង្កើនអាជ្ញាកណ្តាលថ្នាក់ជាតិឲ្យទៅជាថ្នាក់អន្តរជាតិ ឲ្យបាន៥០%ក្នុងឆ្នាំ២០២៣។ អាជ្ញាកណ្តាលអន្តរជាតិមានតិចតួចប្រមាណ១០%(៤-៥នាក់) នាពេលបច្ចុប្បន្ន។

**៤.៣.៤- សហព័ន្ធកីឡាជាតិ**

សហព័ន្ធកីឡាជាតិជាអង្គការកីឡាជំនាញ និងជាតួអង្គសំខាន់បំផុតក្នុងកិច្ចប្រតិបត្តិ និងអនុវត្តផ្ទាល់ដោយទទួលខុសត្រូវលើ៖

- រៀបចំកម្មវិធីបណ្តុះបណ្តាលកីឡាករជំនាញវ័យក្មេង "Sport Academy" ប្រចាំសហព័ន្ធ។
- រៀបចំដំណើរការប្រកួតទាំងស្រុង។
- រៀបចំឧបករណ៍ សម្ភារៈបម្រើការប្រកួត និងទីលានប្រកួត។
- រៀបចំឯកសារបទបញ្ជាការប្រកួត បែបបទចូលរួមប្រកួត និងកិច្ចប្រជុំបច្ចេកទេស កិច្ចប្រជុំអាជ្ញាកណ្តាល ចៅក្រមមុនពេលប្រកួត។
- រៀបចំមន្ត្រីបម្រើការបច្ចេកទេស និងមន្ត្រីគាំទ្របច្ចេកទេស។
- រៀបចំអាជ្ញាកណ្តាល ចៅក្រម និងជំនាញការបច្ចេកទេស របស់សហព័ន្ធកីឡាអាស៊ី ឬសហព័ន្ធកីឡាអន្តរជាតិ។
- រៀបចំផែនការអភិវឌ្ឍនិងផែនការសកម្មភាពជំនាញសម្រាប់កីឡាករនិងគ្រូបង្វឹក។
- រៀបចំផែនការយុទ្ធសាស្ត្រឆ្ពោះទៅឆ្នាំ២០២៣ ក្នុងការកសាងសមត្ថភាព គុណភាពកីឡាករឲ្យមានគុណវុឌ្ឍិពិតប្រាកដ និងកសាងគ្រូបង្វឹកប្រកបដោយបទពិសោធ និងជំនាញបច្ចេកទេសកីឡាខ្ពស់។

បច្ចុប្បន្ន សហព័ន្ធកីឡាជាតិភាគច្រើនមានភាពទន់ខ្សោយក្នុងការគ្រប់គ្រងដឹកនាំ និងខ្វះមន្ត្រីស្ម័គ្រចិត្ត "Volunteer Willing" ប្រចាំការងារ ពិសេស ខ្វះទំនាក់ទំនងទៅសហព័ន្ធកីឡាអន្តរជាតិរបស់ខ្លួន។ មានន័យថា ធនធានមនុស្សក៏ខ្វះខាត និងលទ្ធភាពក៏ខ្សោយក្នុងដំណើរការប្រតិបត្តិសកម្មភាពសហព័ន្ធកីឡាជាតិរបស់ខ្លួន។/

**៤.៣.៥- មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា**

មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា ជាក្របខណ្ឌប្រមូលផ្តុំគ្រប់គ្រងដឹកនាំកីឡាករជាតិ ដើម្បីស្វែងរកគុណភាពហាត់ហ្វឹកហ្វឺន និងសមត្ថភាពកីឡាជំនាញឆ្ពោះទៅរកឧត្តមភាពកម្រិតបច្ចេកទេសលើការប្រកួតជាលក្ខណៈអន្តរជាតិ។

យន្តការប្រតិបត្តិការងារជំនាញ ត្រូវសហការជាមួយសហព័ន្ធកីឡាជាតិរៀបចំផែនការហ្វឹកហាត់ប្រកបដោយទ្រឹស្តីបច្ចេកទេស វិទ្យាសាស្ត្រកីឡាត្រឹមត្រូវ។

**ទន្ទឹមនឹងកម្មវិធីហ្វឹកហាត់ត្រូវរៀបចំៈ**

- ការស្នាក់នៅប្រកបដោយផាសុកភាព។
- របបអាហារមានស្តង់ដា កាឡូរីតាមនិយាមរបបអាហារកីឡាកររកម្រិតខ្ពស់។
- ទទួលបានការលើកទឹកចិត្តជាប្រាក់ឧបត្ថម្ភប្រចាំខែ។
- ទទួលបាននូវសេវាថែទាំសុខភាពជាប្រចាំ។
- ទទួលបានការបង្ហាត់ពីគ្រូបង្វឹកជំនាញ មានបទពិសោធពិតប្រាកដ។
- ទទួលបានឧបករណ៍ សម្ភារៈហ្វឹកហាត់ស្តង់ដាអន្តរជាតិ។
- កីឡាករជាសិស្ស និស្សិតត្រូវរៀបចំសម្រួលកម្មវិធីសិក្សា។
- រៀបចំឱ្យមានការបញ្ជូនទៅហ្វឹកហាត់ក្រៅប្រទេស និងចូលរួមការប្រកួតកីឡាជាលក្ខណៈជាតិនិងអន្តរជាតិ។

**គោលដៅយុទ្ធសាស្ត្រត្រៀមៈ**

- ចាប់ពីឆ្នាំ២០១៦តទៅ រៀងរាល់ពីរឆ្នាំម្តង ត្រូវរៀបចំការប្រកួតពហុកីឡាថ្នាក់ជាតិ "National Games" ពិសេសឆ្នាំ២០២២ ត្រូវរៀបចំពិសេសលំនាំកម្មវិធីប្រកួតកីឡា SEA Games ដើម្បីពិនិត្យការខ្វះខាតនិងចំណុចខ្លាំងខ្សោយ នៃការរៀបចំគ្រប់គ្រងព្រឹត្តិការណ៍កីឡា SEA Games។

- ឆ្នាំ២០១៦-២០១៩ ត្រូវមានក្របខណ្ឌប្រមូលផ្តុំក្រុមជម្រើសជាតិកីឡាករក្រោមអាយុ១៨ឆ្នាំ (១៦-១៨ឆ្នាំ) ប្រមាណ២០០នាក់ក្នុងមួយឆ្នាំ និងអាយុ១៨ឡើង (១៨-៤០ឆ្នាំ) ប្រមាណ៣០០នាក់ក្នុងមួយឆ្នាំ។ រយៈពេលប្រមូលផ្តុំអាចពី៨ទៅ១០ខែក្នុងមួយឆ្នាំ។
- ឆ្នាំ២០២០រហូតដល់២០២៣ ត្រូវមានកីឡាករជម្រើសជាតិក្រោមអាយុ១៨ឆ្នាំ ប្រមាណ២០០នាក់ និងកីឡាករអាយុ១៨ឆ្នាំឡើង ប្រមាណ៧០០នាក់ក្នុងមួយឆ្នាំ។ រយៈពេលប្រមូលផ្តុំឆ្នាំ២០២០-២០២១ រយៈពេល១០ខែក្នុងមួយឆ្នាំ និងពីឆ្នាំ២០២២ដល់ឆ្នាំ២០២៣ រយៈពេល១១ខែក្នុងមួយឆ្នាំ។

* ឆ្នាំ២០២២-២០២៣ ត្រូវបញ្ជូនកីឡាករជម្រើសជាតិទៅហ្វឹកហាត់ក្រៅប្រទេសយ៉ាងតិច៣០%នៃកីឡាករជម្រើសជាតិទាំងអស់ និងត្រូវមានជំនាញការ គ្រូបង្វឹកអន្តរជាតិបង្ហាត់ក្នុងប្រទេសយ៉ាងតិច៨០%នៃប្រភេទកីឡា ត្រៀមដាក់បញ្ចូលក្នុងកម្មវិធីកីឡាអាស៊ីអាគ្នេយ៍(SEA Games) ឆ្នាំ២០២៣។

* ឆ្នាំ២០២២-២០២៣ ត្រូវរៀបចំធ្វើម្ចាស់ផ្ទះប្រកួតជើងឯកអាស៊ីអាគ្នេយ៍លើប្រភេទកីឡាយុទ្ធសាស្ត្រមួយចំនួនដើម្បីវាយតម្លៃលទ្ធផលកីឡាអាស៊ីអាគ្នេយ៍(SEA Games) ២០២៣ បាន។

* ចាប់ពីឆ្នាំ២០១៦ដល់ឆ្នាំ២០២៣ ចាប់ផ្តើមដាក់ចេញនូវកម្មវិធីការពារបរិស្ថាន ការបង្រួមបរិយាកាសធាតុក្នុងទីក្រុងភ្នំពេញក្នុងកិច្ចគាំទ្រព្រឹត្តិការណ៍កីឡាប្រកបដោយនិរន្តរភាព(កាត់បន្ថយការប្រើប្រាស់អគ្គិសនី ទឹក ធម្មជាតិ ដី ចរាចរណ៍ច្រើន សំរាម សំឡេងខ្លាំង និងការប្រើប្រាស់ថាមពលក្នុងសម្ភារកីឡា មុន ក្រោយព្រឹត្តិការណ៍)។/.

**៤.៤- ជំនាញនិងបទពិសោធរៀបចំការប្រកួតពហុកីឡា "Games"**

- រៀបចំគណៈកម្មាធិការរៀបចំការប្រកួត CAMBODIA SEA Games Organizing Committee – "CAMGOC" – ត្រូវបង្កើតឡើងនៅដើមឆ្នាំ២០១៦ ត្រៀមធ្វើរបាយការណ៍រៀងរាល់ការប្រជុំសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ជារៀងរាល់ឆ្នាំ "Progress Report" ចាប់ពីឆ្នាំ២០១៦តទៅ។
- រៀបចំអនុគណៈកម្មការជំនាញ
  - ១. ពិធីបើកបិទ (Opening and Closing Ceremony)
  - ២. មជ្ឈមណ្ឌលសារព័ត៌មាន "IBC" (International Broadcasting Center)
  - ៣. ទីផ្សារកីឡានិងចលនូបត្ថម្ភ (Marketing and Sponsorship)
  - ៤. Games-IT + AD Card
  - ៥. សន្តិសុខនិងសណ្តាប់ធ្នាប់ (Safety and Security)
  - ៦. ស្នាក់នៅនិងហូបចុក ( Accommodation and Food)
  - ៧. ទំនាក់ទំនង NOCs និងសេវាកម្មកីឡា (NOCs Relations and Services)
  - ៨. ពិធីការ (Protocol)
  - ៩. កីឡានិងបទប្បញ្ញត្តិ ( Sport and Rule)
  - ១០. ការដឹកជញ្ជូន ភស្តុភារ (Transportation + Logistics)
  - ១១. ទីលានប្រកួត (Sport Venue)
  - ១២. វប្បធម៌ បរិស្ថាន និងអប់រំកីឡា (Culture Environment and Sport Education)
  - ១៣. ហិរញ្ញវត្ថុនិងការផ្គត់ផ្គង់ (Finance)
  - ១៤. អ្នកស្ម័គ្រចិត្ត (Volunteer)
  - ១៥. វេជ្ជសាស្ត្រកីឡា(Doping)

**៤.៥- ដំណើរការរៀបចំព្រឹត្តិការណ៍ប្រកួត**

- ត្រួតពិនិត្យនិងកែសម្រួលកម្មវិធីលម្អិត **Sport Program Opening and Closing**
- ការរៀបចំគណៈប្រតិភូ ទទួលទង់ កីឡាអាស៊ីអាគ្នេយ៍(SEA Games) ពីប្រទេសធ្វើម្ចាស់ផ្ទះ ឆ្នាំ២០២១។
- ត្រៀមបញ្ជូលប្រតិភូកីឡាកម្ពុជាទទួលសិទ្ធិនិងទង់ធ្វើម្ចាស់ផ្ទះបន្តនៅឆ្នាំ២០២១ ដោយមានក្រុមសិល្បៈសម្តែងទស្សនីយភាពវប្បធម៌ជាតិផង នៅក្នុងពិធីបិទការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games) លើកទី៣១ ឆ្នាំ២០២១។

**ចំពោះការរៀបចំកម្មវិធីប្រកួតកីឡា**

គណៈកម្មាធិការរៀបចំការប្រកួត **"CAMGOC"** និងគណៈកម្មាធិការកីឡានិងបទប្បញ្ញត្តិ "Sport and Rule Committee" ត្រូវសហការជាមួយសហព័ន្ធអន្តរជាតិប្រចាំតំបន់និងទ្វីប ដើម្បីរៀបចំកម្មវិធីប្រកួតកីឡាជំនាញនីមួយៗ (រយៈពេល១ឆ្នាំមុនការប្រកួត)។

**ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់សហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ចំនួនពីរបីដង** (ចំនួនពី៣ទៅ៥លើក) នៅរាជធានីភ្នំពេញ ធ្វើនៅដើមឆ្នាំ២០២២ ដោយមានកិច្ចប្រជុំគណៈកម្មាធិការកីឡានិងបទប្បញ្ញត្តិ គណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ (Sport and Rule Committee-Executive Committee និង [illegible] Council)។

**ទីលាននិងទីតាំងប្រកួត "Sport Venues" ត្រូវ៖**

- ជួសជុលកែលម្អ បំពាក់ឧបករណ៍ សម្ភារៈកីឡា គ្រឿងបំពងសំឡេង ប្រព័ន្ធព័ត៌មានវិទ្យានិងតុបតែងក្នុងនិងក្រៅទីលានប្រកួត។

**- ចំពោះកិច្ចប្រជុំ៖**

- រៀបចំប្រជុំលើកទី១ ស្តីពីកីឡានិងបទប្បញ្ញត្តិ ( Sport and Rule Committee) នៅដើមឆ្នាំ២០២១។
- រៀបចំសិក្ខាសាលាថ្នាក់នាយបេសកកម្ម CDM Seminar មុន ៦ខែនៃការប្រកួត។
- រៀបចំប្រជុំគណៈកម្មាធិការកីឡានិងបទប្បញ្ញត្តិ គណៈកម្មាធិការប្រតិបត្តិ (Sport and Rule Committee និង Executive Committee) ព្រមទាំងក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍( SEAGF Council) ដើមឆ្នាំ២០២៣។

**- ចំពោះសកម្មភាពផ្សេងៗក្នុងប្រទេស**

- ឆ្នាំ២០២២ :
  - ធ្វើពិធីរាប់ថយក្រោយ(Countdown) ព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍(SEA Games) ចាប់ពីឆ្នាំ២០១៦ រហូតដល់ឆ្នាំ២០២៣។
  - ពិធីផ្សព្វផ្សាយលើកទង់កីឡាអាស៊ីអាគ្នេយ៍(SEA Games) បន្ទាប់ពីទទួលបានពីប្រទេសម្ចាស់ផ្ទះ កីឡាអាស៊ីអាគ្នេយ៍(SEA Games) ឆ្នាំ២០២១។
  - ពិធីផ្សព្វផ្សាយ ផ្សេងៗទៀត។
- ឆ្នាំ២០២៣ :
  - ពិធីរត់ភ្លើងគប់កីឡាអាស៊ីអាគ្នេយ៍(SEA Games) ឆ្នាំ២០២៣ ជុំវិញបឹងទន្លេសាប។
  - ពិធីរាប់ថយក្រោយ១០០ថ្ងៃកីឡាអាស៊ីអាគ្នេយ៍(SEA Games) លើកទី៣២ ឆ្នាំ២០២៣។
  - រៀបចំសាកល្បងពិធីបើកបិទ (Rehearsal Opening-Closing Ceremony)។
  - ពិធីផ្សេងៗ។

**៤.៦- ផែនការយុទ្ធសាស្ត្រផ្សព្វផ្សាយនិងទីផ្សារ**កីឡាអាស៊ីអាគ្នេយ៍(SEA Games)

- ចាប់ពីឆ្នាំ២០១៦ ផ្សព្វផ្សាយដំណើរឆ្ពោះទៅកីឡាអាស៊ីអាគ្នេយ៍(SEA Games) ឆ្នាំ២០២៣ នៅកម្ពុជាតាមគ្រប់រូបភាពសារព័ត៌មាន។ គ្រប់ការផ្សព្វផ្សាយរបស់ជាតិ ត្រូវរួមចំណែកបញ្ចូលព័ត៌មាន កីឡាអាស៊ីអាគ្នេយ៍(SEA Games) ឆ្នាំ២០២៣។
- ផលិត Spot អប់រំកីឡា ផលិតចម្រៀងកីឡា និងចម្រៀងកីឡាអាស៊ីអាគ្នេយ៍(SEA Games) ។
- ការប្រើប្រាស់រូបសញ្ញារបស់អ្នកឧបត្ថម្ភលើសម្ភារៈឬការស្លៀកពាក់របស់ប្រតិភូកីឡាគ្រប់ប្រទេសចូលរួម ត្រូវគោរពបទប្បញ្ញត្តិទីផ្សារកីឡារបស់ CAMGOC និងគោលការណ៍បញ្ជាក់ពីសិទ្ធិទទួលបានការឧបត្ថម្ភទីផ្សាររបស់អ្នកឧបត្ថម្ភ តាមនិយាមកីឡាអូឡាំពិក (Olympic Games)។
- រាល់ការធ្វើអាជីវកម្មឬផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗដែលយករូបភាពឬទ្រព្យសម្បត្តិរបស់ កីឡាអាស៊ីអាគ្នេយ៍ (SEA Games) ទៅប្រើប្រាស់ ត្រូវបានផ្តន្ទាទោសតាមច្បាប់។
- ផ្តល់ភាពអនុគ្រោះពិសេសដល់ក្រុមហ៊ុនដៃគូ ក្រុមហ៊ុនឧបត្ថម្ភគាំទ្រអ្នកឧបត្ថម្ភកីឡា (Sponsor Games) តាមរយៈការបន្ធូរបន្ថយពន្ធអាករផ្សេងៗ។
- ស្វែងរកដៃគូឧបត្ថម្ភ (Partnership) ក្រុមហ៊ុនឧបត្ថម្ភ (Sponsorship) និងសប្បុរសជន។
- ឧស្សាហកម្មកីឡា ស្វែងរកក្រុមហ៊ុនដៃគូផលិតឧបករណ៍ សម្ភារៈ ការស្លៀកពាក់ ដែលប្រើប្រាស់[illegible] (Logo Mascot) ឬGames themes។ល។/ស

- ការផ្តល់សិទ្ធិ (Licensing) ឱ្យផលិតឧបករណ៍ សម្ភារៈ ការស្លៀកពាក់ ក្នុងព្រឹត្តិការណ៍ប្រកួត ដោយប្រើ Logo Mascot Games។
- ការផ្តល់សិទ្ធិរូបភាព (Image Right) ដល់ស្ថានីយទូរទស្សន៍ឬក្រុមហ៊ុន Broadcasting។
- ការលក់សំបុត្រចូលទស្សនា "Ticketing" ដោយផ្តល់សិទ្ធិឱ្យក្រុមហ៊ុនណាមួយ ប្រតិបត្តិក្នុងកម្មវិធីបើកបិទ និងការប្រកួតកីឡាមួយចំនួន ដែលមានការទាក់ទាញ និងមានប្រជាប្រិយភាព។

### ៤.៧- យុទ្ធសាស្ត្រយកប្រៀប

ក្នុងនាមជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍ពហុកីឡាត្រូវបំពេញចិត្ត ផ្គាប់ចិត្តប្រជាជនរបស់ខ្លួនជាអាទិភាព (If you host the games, you have to satisfy your people, not others) ផ្តើមចេញពីគោលដៅនេះ CAMGOC ត្រូវគិតគូរលើយុទ្ធសាស្ត្រយកប្រៀបតាមមធ្យោបាយ ដូចខាងក្រោម៖

១. កីឡាហែលទឹកនិងកីឡាអត្តពលកម្ម ជាកីឡាដែលមានប្រភេទវិញ្ញាសាច្រើន និងមេដាយច្រើនជាងគេ ដូចនេះត្រូវផ្តោតការយកចិត្តទុកដាក់រៀបចំផែនការយុទ្ធសាស្ត្រពិសេស ដើម្បីរៀបចំអត្តពលិកឱ្យមានកម្រិតបច្ចេកទេស "Record" ខ្ពស់ជាងគេ (ប្រើគ្រប់មធ្យោបាយដែលស្របតាមលក្ខខណ្ឌកីឡាអន្តរជាតិ)។

២. ត្រូវផ្តល់អាទិភាពនិងលើកទឹកចិត្តឱ្យមានកីឡាការិនីកាន់តែច្រើនចូលក្នុងការប្រកួត ពីព្រោះប្រភេទកីឡាមួយចំនួន កីឡាការិនីមានលទ្ធភាពច្រើនក្នុងការដណ្តើមមេដាយ។

៣. ប្រភេទកីឡាប្រយុទ្ធ ត្រូវមានកីឡាករប្រភេទទម្ងន់ធ្ងន់ឱ្យបានច្រើន។

៤. ដាក់យុទ្ធសាស្ត្រច្បាស់លាស់ចំពោះកីឡាបាល់ទាត់ ពីព្រោះជាប្រភេទកីឡាមានប្រជាប្រិយ និងឥទ្ធិពលជាងគេ និងជាក្តីសង្ឃឹមនៃប្រទេសជាតិទាំងមូល។ ជាគោលដៅយុទ្ធសាស្ត្រ គឺកីឡាបាល់ទាត់ត្រូវឈានឱ្យដល់វគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ (Semi-final) ឬ វគ្គផ្តាច់ព្រ័ត្រ (Final)។

៥. យុទ្ធសាស្ត្រយកប្រៀបក្នុងការផ្គូផ្គង និងរៀបចំនីតិវិធីបច្ចេកទេសយកប្រៀប។

៦. រៀបចំកីឡាករខ្មែរនៅក្រៅប្រទេសដែលមានកម្រិតបច្ចេកទេសខ្ពស់លើប្រទេសនានាក្នុងតំបន់ឱ្យចូលរួមប្រកួត។

## V. ផែនការយុទ្ធសាស្ត្រក្នុងអំឡុងពេលព្រឹត្តការណ៍ប្រកួត

រយៈពេលនៃការប្រកួតមិនឱ្យលើសពី២សប្តាហ៍ដែលភាគច្រើនរយៈពេលកីឡាអាស៊ីអាគ្នេយ៍(SEA Games) គឺពី១០ទៅ១៥ថ្ងៃ បើតាមអាកាសធាតុនៃព្រះរាជាណាចក្រកម្ពុជា គួររៀបចំកីឡាអាស៊ីអាគ្នេយ៍(SEA Games) ក្នុងខែវិច្ឆិកាឬខែធ្នូ ជាការប្រសើរ។

- បើកមជ្ឈមណ្ឌលពិនិត្យនិងព្យាបាលសុខភាពអ្នកចូលរួម ពិសេស កីឡាករ កីឡាការិនី។
- ដំណើរការធ្វើតេស្ត Doping តាមដានត្រួតពិនិត្យករណី Doping។
- រៀបចំពង្រាយកម្លាំងការងារ "Workforce" ទាំងមន្ត្រីជំនាញ ទាំងអ្នកស្ម័គ្រចិត្តឱ្យចូលកាន់ទីកន្លែង។
- ពិនិត្យការដឹកជញ្ជូនពីព្រលានយន្តហោះមកទីកន្លែងស្នាក់នៅ ពីកន្លែងស្នាក់នៅទៅទីលានហ្វឹកហាត់ និងទីលានប្រកួត និងពីកន្លែងស្នាក់នៅទៅព្រលានយន្តហោះវិញ។
- ពិនិត្យលម្អិតកម្មវិធីបើកបិទ។
- រៀបចំបន្ទប់ការិយាល័យនិងបំពាក់ឧបករណ៍សម្ភារះរដ្ឋបាលសម្រាប់ NOCs ចូលរួម។

- ពិនិត្យលម្អិតកម្មវិធីមកដល់របស់ប្រតិភូកីឡា។
- ពិនិត្យលម្អិតកម្មវិធីបដិសណ្ឋារកិច្ច ។
- ពិនិត្យលម្អិតកម្មវិធីកីឡាប្រកួតនីមួយៗ ពិសេស ទីលានប្រកួត (Sport Venue)។
- ពិនិត្យលម្អិតប្រព័ន្ធសន្តិសុខ សណ្តាប់ធ្នាប់។
- ពិនិត្យលម្អិតប្រព័ន្ធព័ត៌មានវិទ្យា"សារព័ត៌មានជាកាសែតនិងព័ត៌មាន Online, Website..." ។
- ផ្តល់វិញ្ញាបនបត្រនិងមេដាយអនុស្សាវរីយ៍ចូលរួម SEA Games ដល់គ្រប់សមាជិកប្រតិភូកីឡាទាំងអស់។
- NOCC ត្រៀមដោះស្រាយបញ្ហាជាមួយ CDM គ្រប់ប្រទេស។
- ពិនិត្យកម្មវិធីកម្សាន្ត អប់រំផ្សេងៗ។
- រៀបចំប្រជុំកីឡាអាស៊ីអាគ្នេយ៍ គណៈកម្មាធិការវេជ្ជសាស្ត្រកីឡា គណៈកម្មាធិការកីឡានិងបទប្បញ្ញត្តិ គណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ (SEA Games, Medical Committee, Sport and Rule Committee, Executive Committee and SEAGF Council) មុនថ្ងៃបើកការប្រកួតជាផ្លូវការពី២ទៅ៣ថ្ងៃ។
- រៀបចំអ្នកគាំទ្រ ដើម្បីលើកទឹកចិត្តកីឡាសក្តានុពលរបស់កម្ពុជា។
- នាយបេសកកម្ម មកធ្វើ Pre-DRM មុនការប្រកួត១ខែឬកន្លះខែ។
- រៀបចំអញ្ជើញសមាជិកក្រុមប្រឹក្សា SEAGF សមាជិកកិត្តិយស ប្រធានសហព័ន្ធកីឡាជាតិប្រទេសចូលរួម ឬតំណាងសហព័ន្ធអន្តរជាតិ ភ្ញៀវកិត្តិយសចូលរួមបំពាក់មេដាយជូនជ័យលាភី។

**សេចក្តីព្រាងកម្មវិធីទូទៅ**

- ទទួលការមកដល់របស់ប្រតិភូ តាមបញ្ជរពិសេសនៅព្រលានយន្តហោះឬផ្លូវគោកតាមច្រកអន្តរជាតិនានាដោយបង្ហាញអត្តសញ្ញាណវប្បធម៌ខ្មែរ(ផ្កា របាំ ...)។
- ជូនប្រតិភូទៅកាន់កន្លែងស្នាក់នៅ។
- ពិធីចុះឈ្មោះប្រតិភូនិងរៀបចំបញ្ចូលបណ្ណសម្គាល់ (Activate ID Card) ក្នុងប្រព័ន្ធព័ត៌មានវិទ្យា (នាយបេសកកម្មនៃប្រទេសនីមួយៗធ្វើ DRM ចុងក្រោយ។
- រៀបចំពិធីស្វាគមន៍ប្រតិភូនិងបង្ហូតទង់ជាតិ (អភិបាលរាជធានី ប្រធានភូមិកីឡាឬតំណាង)។
- ប្រភេទកីឡាមួយចំនួន ត្រូវចាប់ផ្តើមប្រកួតមុនពិធីបើកកីឡាអាស៊ីអាគ្នេយ៍(SEA Games)ជាផ្លូវការ។
- ពិធីបើក (ថ្ងៃទី១ឬទី៥ ខែធ្នូ ឆ្នាំ២០២៣)។
- កីឡាទាំងអស់ចាប់ផ្តើមប្រកួតតាមលំដាប់លំដោយនៃកម្មវិធីប្រកួត។
- ពិធីបិទ(ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣)។

**សេចក្តីព្រាងកម្មវិធីបើក**

- សកម្មភាពកម្សាន្តឬចូលរួមធ្វើសកម្មភាពកម្សាន្តជាមួយទស្សនិកជន
- ចាប់ផ្តើម ៧:០០-៩:០០PM "MC ប្រកាសបើកកម្មវិធីបាញ់កាំជ្រួច"
- ពិធីដង្ហែទង់ជាតិនិងទង់កីឡាអាស៊ីអាគ្នេយ៍(SEA Games)
- ទស្សនីយភាព:
  - បង្ហាញពីវប្បធម៌ជាតិ

• បង្ហាញទស្សនីយភាព បច្ចុប្បន្នភាព
- ពិធីដង្ហែប្រតិភូកីឡានៃប្រទេសនីមួយៗ
- សុន្ទរកថា អនុប្រធានគណៈកម្មាធិការរៀបចំ ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា
- សុន្ទរកថាបើករបស់ប្រមុខរដ្ឋ/ប្រមុខរាជរដ្ឋាភិបាល "បាញ់កាំជ្រួច"
- ពិធីរត់ភ្លើងគប់និងដុតភ្លើងគប់ ដោយ (វីរអត្តពលិក) "បាញ់កាំជ្រួច"
- តន្ត្រីសម័យតារាល្បីៗ

**សេចក្តីព្រាងកម្មវិធីបិទ**

- សកម្មភាពសប្បាយៗឬតន្ត្រីចម្រៀងកំដរ
- ចាប់ផ្តើមកម្មវិធី ៧:00-៩:00PM
- បញ្ចាំងសកម្មភាព កីឡាអាស៊ីអាគ្នេយ៍(SEA Games) លើកទី៣២ ឆ្នាំ២០២៣
- ដង្ហែក្បួនកីឡាករ កីឡាការិនី
- បង្ហាញទស្សនីយភាពសិល្បៈ
- ពិធីគោរពទង់ជាតិប្រទេសម្ចាស់ផ្ទះបន្ទាប់
- ពិធីផ្ទេរតំណែងឬសិទ្ធិម្ចាស់ផ្ទះបន្ទាប់
- បង្ហាញទស្សនីយភាពម្ចាស់ផ្ទះបន្ទាប់
- សុន្ទរកថាបិទ
    - អនុប្រធាន CAMGOC និងជាប្រធាន SEAGF Council
    - ប្រកាសបិទ ប្រមុខរដ្ឋឬប្រមុខរាជរដ្ឋាភិបាល(បាញ់កាំជ្រួច)
- ចម្រៀងតន្ត្រីកម្សាន្ត

VI. **យុទ្ធសាស្ត្រក្រោយពេលព្រឹត្តការណ៍ប្រកួត**

ក្រោយការប្រកួតត្រូវដោះស្រាយរាល់បញ្ហាកើតឡើង គឺការតវ៉ា ការទាមទារផ្សេងៗ ពិសេស បន្តការងាររៀបចំរបាយការណ៍លទ្ធផលបច្ចេកទេស ពិនិត្យករណី Doping និងរៀបចំជប់លៀងក្រុមការងារ និងអ្នកឧបត្ថម្ភផ្តល់លិខិតថ្លែងអំណរគុណដល់ Sponsor និង NOCs ប្រទេសទាំង១១ ដែលបានចូលរួមប្រកបដោយជោគជ័យ។

- ធ្វើសន្និសីទកាសែតបញ្ចប់លទ្ធផលនិងកម្មវិធីប្រកួត
- ធ្វើរបាយការណ៍បឋមជូនដល់ CAMGOC និងរាជរដ្ឋាភិបាល
- សរសេរលិខិតថ្លែងអំណរគុណដល់ការចូលរួមចំណែកធ្វើឲ្យកីឡាអាស៊ីអាគ្នេយ៍(SEA Games) ឆ្នាំ២០២៣ ទទួលបានជោគជ័យ
- ត្រូវដោះស្រាយការចំណាយ
- រៀបចំទុកដាក់ឧបករណ៍ សម្ភារៈកីឡា ធ្វើបញ្ជីសារពើភណ្ឌឡើងវិញ (Inventory)
- បោះពុម្ពសៀវភៅឯកសារលទ្ធផលបច្ចេកទេសនិងសៀវភៅប្រវត្តិសាស្ត្រកីឡាអាស៊ីអាគ្នេយ៍(SEA Games) លើកទី៣២ ឆ្នាំ២០២៣
- រៀបចំផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តអត្តពលិកជ័យលាភីកម្ពុជា និងពិធីជប់លៀងអបអរ...

- រៀបចំផែនការយុទ្ធសាស្ត្រកីឡាជាតិឡើងវិញ ដោយប្រមើលមើលពីលទ្ធភាពធ្វើម្ចាស់ផ្ទះការប្រកួតកីឡាជា Games ឬ World Championship ណាមួយ។

## VII. យុទ្ធសាស្ត្រគាំទ្រផែនការមេកីឡាអាស៊ីអាគ្នេយ៍(SEA Games) ឆ្នាំ២០២៣

ដើម្បីអនុវត្តផែនការមេកីឡាអាស៊ីអាគ្នេយ៍(SEA Games) ឆ្នាំ២០២៣ ឲ្យមានប្រសិទ្ធភាពនិងទទួលបានជោគជ័យ សូមភាគីពាក់ព័ន្ធ(Stakeholders)ទាំងអស់ចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រគាំទ្រនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់និងប្រកាន់ភ្ជាប់នូវគោលការណ៍សន្តិសហវិជ្ជមាន ភាពជាដៃគូសម្របសម្រួល និងបង្រួញបញ្ហានៅគ្រប់កាលៈទេសៈ ដើម្បីសម្រេចគោលបំណងរួមគឺ“ឧត្តមភាព សក្តានុពលភាពកីឡាជាតិ”។

### ៧.១- ចំពោះសាលារាជធានីភ្នំពេញ

- ចូលរួមផ្សព្វផ្សាយព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games)។ មានការកសាងឬតុបតែងរូបសំណាកនិមិត្តរូប (Mascot) ឬរូបសញ្ញា (Logo) កីឡាអាស៊ីអាគ្នេយ៍ (SEA Games) លើកទី៣២ ឆ្នាំ២០២៣ នៅទីសាធារណៈក្នុងរាជធានីភ្នំពេញ។
- ដាក់បញ្ញត្តិឬការណែនាំពីបញ្ហាបរិស្ថានទីក្រុងលើបញ្ហាសំឡេង ផ្សែង អនាម័យ ការប្រើប្រាស់ថាមពលអគ្គិសនីដោយសន្សំសំចៃ ការប្រើប្រាស់ទឹកដោយសន្សំសំចៃ និងការតុបតែងលម្អផ្ទះ ទីប្រជុំជន។ល។
- បញ្ចូលការតភ្ជាប់គមនាគមន៍ពីតំបន់កណ្តាលក្រុងទៅពហុកីឡដ្ឋានមរតកតេជោ ដូចជាខ្សែរថយន្តក្រុង រថភ្លើងលើអាកាស (Sky Train) ក្នុងប្លង់មេសាលារាជធានីភ្នំពេញ។
- ត្រៀមផ្សព្វផ្សាយប្រធានបទលុបបំបាត់ភាពអសកម្មនិងឥរិយាបថផ្គាំផ្គងរបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញដូចជាបញ្ហាក្មេងទំនើង ជនអនាថាតាមផ្លូវ ការហាលខោអាវក្រៅផ្ទះ។

### ៧.២- ចំពោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ផ្តល់ការគាំទ្រនិងរៀបចំកញ្ចប់ថវិកាពិសេសមួយសម្រាប់ទ្រទ្រង់ផែនការសកម្មភាពការងាររបស់គណៈកម្មាធិការរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ (CAMGOC) ចាប់ពីផែនការមេនេះត្រូវបានអនុម័តជាផ្លូវការរហូតដល់ឆ្នាំ២០២៣។
- ផ្តល់ភាពអនុគ្រោះពន្ធ ឬថ្លៃសេវាផ្សេងៗដល់ការធ្វើឧស្សាហកម្មកីឡា(Sport Industry) ឬចលនូបត្ថម្ភ (Sponsorship)នៃវិស័យឯកជន ឬបន្ថែមតម្លៃពន្ធលើអាជីវកម្មណាមួយសម្រាប់ទ្រទ្រង់ដំណើរការសកម្មភាពផែនការមេនេះដើម្បីទាក់ទាញការវិនិយោគនិងឧបត្ថម្ភគាំទ្រដល់ផែនការមេនេះ។
- បន្តអនុគ្រោះលើកលែងពន្ធលើជំនួយសម្ភារៈ ឧបករណ៍កីឡាពីបណ្តាប្រទេសនានាសម្រាប់វិស័យកីឡាជាតិ។
- ផ្តល់គោលនយោបាយជួយទ្រទ្រង់ចំណាយលើការថែទាំឧបករណ៍ សម្ភារៈនិងហេដ្ឋារចនាសម្ព័ន្ធកីឡា។

### ៧.៣- ចំពោះគ្រឹះស្ថានសិក្សា

- គ្រប់គ្រឹះស្ថានសិក្សាចាប់ពីមត្តេយ្យសិក្សាដល់ឧត្តមសិក្សា ត្រូវយកចិត្តទុកដាក់រៀបចំ ថែរក្សាការពារ ជួសជុលកែលម្អ និងកសាងទីលានកម្សាន្ត ទីលានកីឡា ឬសាលកីឡា ដើម្បីបង្គ្រប់ស្តង់ដារអប់រំក្នុងសមាសភាគទាំង៥គឺ អប់រំចំណេះដឹង(ពុទ្ធិ) ចំណេះធ្វើ សីលធម៌ សោភ័ណ និងអប់រំកាយនិងកីឡា។
- គ្រឹះស្ថានសិក្សាទាំងអស់ត្រូវយកចិត្តទុកដាក់បញ្ចូលកម្មវិធីអប់រំកាយនិងកីឡាក្នុងម៉ោងសិក្សា (In Curriculum) និងបញ្ចូលកម្មវិធីហ្វឹកហាត់កីឡាជំនាញក្រៅម៉ោងសិក្សា (Out Curriculum) “កីឡានិស្ស័យ” ដើម្បីបណ្ដុះបណ្ដាលបញ្ញា ស្មារតី សុខភាព និងតម្រង់ទិសកីឡាជំនាញ។
- គ្រឹះស្ថានសិក្សាទាំងអស់ត្រូវលើកទឹកចិត្ត ឧបត្ថម្ភគាំទ្រ ដល់កីឡាករប្រចាំគ្រឹះស្ថានសិក្សារបស់ខ្លួន ដោយគោរពគោលការណ៍កីឡាករឆ្នើមប្រចាំគ្រឹះស្ថានសិក្សាទទួលបានភាពអនុគ្រោះ១ពិន្ទុ លើគ្រប់មុខវិជ្ជាសិក្សាពេលប្រឡង។

## ៧.៤- ចំពោះរដ្ឋអំណាចថ្នាក់ក្រោមជាតិ

- អាជ្ញាធររាជធានី ខេត្ត ត្រូវរៀបចំទីផ្លាសាធារណៈសម្រាប់ប្រជាពលរដ្ឋធ្វើលំហាត់ប្រាណ ដើម្បីសុខភាព និងថែរក្សាការពារជួសជុលកែលម្អ និងកសាងទីលានកីឡា សាលកីឡា កីឡដ្ឋាន ហើយរៀបចំចុះបញ្ជីសារពើភណ្ឌ “Inventory” ជាទ្រព្យសម្បត្តិរដ្ឋសម្រាប់បម្រើវិស័យ អប់រំកាយ និងកីឡាជាសាធារណៈ និង កីឡាជំនាញកម្រិតខ្ពស់ជាក្របខណ្ឌរាជធានី ខេត្ត របស់ខ្លួន។ ការកែលម្អជួសជុលអាចសហការជាមួយដៃគូវិស័យឯកជន ដើម្បីទទួលបានសមិទ្ធផលកីឡាល្អប្រសើរ។
- បំផុសមហាជន និងយុវជនឲ្យចូលរួមសកម្មភាពអប់រំកាយនិងកីឡា និងហ្វឹកហាត់កីឡាជំនាញ ដើម្បីសុខុមាលភាព មិត្តភាព សាមគ្គីភាព និងភាពសុខដុមរមនាក្នុងសង្គម។ បើប្រជាពលរដ្ឋក្នុងមូលដ្ឋាន យល់ដឹង និងហាត់កីឡាទាំងអស់គ្នានោះ នឹងអាចកាត់បន្ថយការចំណាយលើសេវាសុខាភិបាល និងអាចកាត់បន្ថយបញ្ហាសង្គម ភាពអសកម្មក្នុងសង្គមគ្រប់រូបភាព។
- ជំរុញយុទ្ធនាការ “ប្រជាពលរដ្ឋម្នាក់ លេងកីឡាមួយមុខ”។
- លើកទឹកចិត្ត បង្កលក្ខណៈងាយស្រួលឲ្យប្រជាពលរដ្ឋ ធុរជន ក្រុមហ៊ុនឯកជន គ្រឹះស្ថានសិក្សាសាធារណៈ ឯកជនសប្បុរសជនបង្កើតក្លឹបកីឡាជំនាញគ្រប់ប្រភេទនិងបង្កើតព្រឹត្តិការណ៍កីឡាមហាជន និងការប្រកួតកីឡាជំនាញក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីដណ្ដើមឧត្តមភាពកីឡានៅថ្នាក់ជាតិ និងលើកកម្ពស់កិត្តិយសរាជធានី ខេត្តរបស់ខ្លួន។

## ៧.៥- ចំពោះស្ថាប័នជាតិ

ស្ថាប័នជាតិកំពូលៗនិងក្រសួង មន្ទីរ អង្គភាពរដ្ឋត្រូវយកចិត្តទុកដាក់រួមចំណែកធ្វើលំហាត់អប់រំកាយនិងកីឡា និងបង្កើតក្លឹបកីឡាជំនាញ ដើម្បីសុខភាព និងសមត្ថភាពការងាររបស់បុគ្គលិកមន្ត្រីថ្នាក់ដឹកនាំជាមួយនឹងការបង្កើតមិត្តភាព សាមគ្គីភាពផ្ទៃក្នុង បង្កើនបរិយាកាសសុខដុមរមនាការងារ ហើយអាចជ្រើសរើសអ្នកមានទេពកោសល្យកីឡាធ្វើជាតំណាងស្ថាប័ន ក្រសួង មន្ទីរ អង្គភាពរបស់ខ្លួនចូលរួមប្រកួតកីឡាជំនាញគ្រប់ប្រភេទផងដែរ។

## ៧.៦- ចំពោះក្រសួងអប់រំ យុវជន និងកីឡា និងអង្គភាពជំនាញអប់រំកាយនិងកីឡា និងកីឡាជំនាញ កម្រិតខ្ពស់

- កសាងផែនការនិងរៀបចំគោលនយោបាយថវិកាកីឡាជាតិជាកញ្ចប់មួយដាច់ដោយឡែក ដើម្បីបម្រើសកម្មភាពអប់រំកាយនិងកីឡា និងកីឡាជំនាញកម្រិតខ្ពស់ ពិសេស ត្រូវបំពាក់ឧបករណ៍សម្ភារៈបច្ចេកទេសកីឡាស្របតាមស្តង់ដាកីឡាអន្តរជាតិ និងមានបរិមាណគ្រប់គ្រាន់តម្រូវតាមសេចក្ដីត្រូវការក្នុងកីឡាទីសំ[illegible]

- រៀបចំបទដ្ឋានគតិយុត្តិគ្រប់គ្រងដឹកនាំវិស័យអប់រំកាយនិងកីឡា និងកីឡាជំនាញកម្រិតខ្ពស់ ដោយបែងចែកតួនាទីភារកិច្ច របៀបរបបការងាររវាងរដ្ឋអំណាចកីឡា និងអង្គការកីឡាជាតិឱ្យមានប្រសិទ្ធភាពនិងច្បាស់លាស់។
- ពង្រឹងយន្តការគ្រប់គ្រងដឹកនាំលើគុណភាពកម្មវិធីអប់រំកាយនិងកីឡាក្នុងម៉ោងសិក្សា និងក្រៅម៉ោងសិក្សា គ្រប់គ្រឹះស្ថានសិក្សា ពីមត្តេយ្យសិក្សាដល់ឧត្តមសិក្សា។
- អភិវឌ្ឍធនធានគ្រូអប់រំកាយនិងកីឡា ប្រកបដោយគុណភាព សមត្ថភាពជំនាញអប់រំកាយនិងកីឡាច្បាស់លាស់។
- ពង្រឹងយន្តការគ្រប់គ្រង ថែរក្សា កែលម្អ កសាងបន្ថែមទីលានកីឡា កីឡដ្ឋាន និងពហុកីឡដ្ឋានជាតិ ដោយគោរពតាមបទដ្ឋានរចនាសម្ព័ន្ធស្តង់ដាកីឡាអន្តរជាតិ "ស្តង់ដា IFs" ។
- ដឹកនាំត្រួតពិនិត្យតម្រង់ទិសសហព័ន្ធកីឡាជាតិនិងផ្តល់ទីលានកីឡា និងឧបត្ថម្ភហិរញ្ញវត្ថុដល់សហព័ន្ធកីឡាជាតិក្នុងការអនុវត្តយន្តការរដ្ឋបាលកីឡា និងផែនការអភិវឌ្ឍកីឡាជំនាញ ដោយធ្វើប្រតិភូកម្មឱ្យសហព័ន្ធកីឡាជាតិមានលក្ខណសម្បត្តិគ្រប់គ្រាន់ទទួលខុសត្រូវលើជំនាញកីឡារបស់ខ្លួន។
- គ្រប់គ្រង ដឹកនាំ និងអភិវឌ្ឍកីឡាជម្រើសជាតិតាមមជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡាជាតិដោយសហការលើការអនុវត្ត និងកម្មវិធីផែនការហ្វឹកហាត់កីឡាករជម្រើសជាតិជាមួយសហព័ន្ធកីឡាជាតិ។ ពង្រឹងគុណភាព សមត្ថភាពកីឡាករជម្រើសជាតិ ឱ្យប្រកបដោយគុណវុឌ្ឍិ គុណផលខ្ពស់ ប្រកបដោយគុណធម៌ សេចក្តីថ្លៃថ្នូរ និងវិន័យម៉ឺងម៉ាត់។ បង្កើនការយកចិត្តទុកដាក់លើការឧបត្ថម្ភនិងអាហារូបត្ថម្ភឱ្យកីឡាករជម្រើសជាតិ ស្របតាមនិយាមបច្ចេកទេស និងគោរពតាមរបបអាហារលក្ខណៈវិទ្យាសាស្ត្រកីឡា។
- កីឡាករជម្រើសជាតិ ដែលបញ្ចប់អាជីពជាកីឡាករឬរបួសពិការក្នុងអំឡុងពេលហ្វឹកហាត់ក្នុងក្របខណ្ឌជម្រើសជាតិ ត្រូវបានលើកទឹកចិត្តស្វែងរកការងារក្របខណ្ឌមន្ត្រីរាជការឬក្រុមហ៊ុនឯកជន ដើម្បីទ្រទ្រង់ជីវភាពបន្ត។
- ឧបត្ថម្ភគាំទ្រផ្តល់រង្វាន់លើកទឹកចិត្តដល់កីឡាករឆ្នើម កីឡាករជ័យលាភីថ្នាក់ជាតិ អន្តរជាតិ និងកីឡាករបំបែកឯតទគ្គកម្មជាតិនិងអន្តរជាតិ។ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា សហការស្វែងរកការឧបត្ថម្ភសម្ភារៈថវិកាលើកទឹកចិត្តបន្ថែមដល់កីឡាករជ័យលាភីការប្រកួតពហុកីឡា "Games"។
- ផ្តល់ភាពអនុគ្រោះនិងសិទ្ធិដល់វិស័យឯកជន សប្បុរសជន អង្គការកីឡានានាក្នុងការចូលរួមឧបត្ថម្ភគាំទ្រសកម្មភាព និងព្រឹត្តិការណ៍ប្រកួតកីឡាគ្រប់កម្រិតថ្នាក់ជាតិ អន្តរជាតិ។
- ពង្រឹងយន្តការរដ្ឋបាលនិងបច្ចេកទេសកីឡាជាមួយកីឡាកងកម្លាំងប្រដាប់អាវុធទាំងនគរបាល កងរាជអាវុធហត្ថ និងកងយោធពលខេមរភូមិន្ទ ដើម្បីរួមចំណែកពង្រឹងគុណភាព សមត្ថភាពអត្តពលិកជាតិ តាមរយៈកម្មវិធីកីឡាត្រីភាគី (Triangle Sport Program) "មហាជន នគរបាលជាតិ កងយោធពលខេមរភូមិន្ទ" លើការបណ្តុះបណ្តាលជំនាញកីឡា ការហ្វឹកហាត់ផ្លាស់ប្តូរបទពិសោធរួមគ្នា និងការប្រកួតកីឡាត្រីភាគីថ្នាក់ជាតិ "Triangle National Games" ជាដើម។
- ធ្វើបច្ចុប្បន្នកម្មកែសម្រួលគ្រប់ការប្រកួតថ្នាក់ជាតិឡើងវិញ ចាប់ពីបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងមហាជន កីឡាជំនាញ។ល។ រៀបចំការប្រកួតពហុកីឡាជាតិ "National Games" ជារៀងរាល់ពីរឆ្នាំម្តង និងជ្រើសរើសជើងឯកជាតិគ្រប់ប្រភេទកីឡារៀងរាល់ពីរឆ្នាំម្តង(ឆ្នាំមិនធ្វើ National Games)។ ក្នុងនោះ សហព័ន្ធកីឡាជាតិ ត្រូវខិតខំប្រឹងប្រែងស្វែងរកការឧបត្ថម្ភគាំទ្រពីវិស័យឯកជន និងសប្បុរសជន។

កីឡាជាតិ ដើម្បីរៀបចំការប្រកួតកីឡា ជាលក្ខណៈពានរង្វាន់ថ្នាក់ជាតិឱ្យបានច្រើនដង និងរួមទាំងការរៀបចំប្រកួតជម្រើសជើងឯកឬពានរង្វាន់ថ្នាក់អន្តរជាតិឱ្យបានច្រើនដង ដើម្បីបំពេញបទពិសោធបច្ចេកទេស ពិសេស ពីការប្រកួត។

- ផ្តល់ហេដ្ឋារចនាសម្ព័ន្ធកីឡានិងឧបត្ថម្ភគាំទ្រលើកទឹកចិត្តដល់សកម្មភាពហ្វឹកហាត់ និងប្រកួតសម្រាប់កីឡាជនពិការ "Disable Sport–Paralympic" និងកីឡាជនបញ្ញាខ្សោយ "Mental Disability Sport –Special Olympic"។

## ៧.៧- ចំពោះអង្គការកីឡាសង្គម

ចាត់ទុកអង្គការកីឡាសង្គមទាំងអស់ ជាដៃគូយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍគុណភាពវិស័យអប់រំកាយនិងកីឡា និងកីឡាជំនាញកម្រិតខ្ពស់ ដែលអង្គការកីឡាទាំងនោះមានបេសកកម្មដោយឡែកពីគ្នា ដូចខាងក្រោម៖

- គណៈកម្មាធិការកីឡានិងអង្គការកីឡាជំនាញនានា គឺជាដៃគូអភិវឌ្ឍវិស័យកីឡាជំនាញកម្រិតខ្ពស់ និងបំផុសចលនា "កីឡាដើម្បីទាំងអស់គ្នា" ក្រោមគោលនយោបាយកីឡាជាតិ និងការដឹកនាំតម្រង់ទិសរបស់រដ្ឋអំណាចកីឡា។
- រដ្ឋទទួលស្គាល់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ជាអង្គការកីឡាជាតិស្វយ័ត ទទួលខុសត្រូវគ្រប់គ្រងអភិវឌ្ឍចលនាអូឡាំពិកនៅព្រះរាជាណាចក្រកម្ពុជា និងជាដៃគូជាមួយរដ្ឋអំណាចកីឡា "Sport Authority" លើការងារគ្រប់គ្រង ដឹកនាំវិន័យកីឡាជំនាញកម្រិតខ្ពស់។
- គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ជាតំណាងចលនាអូឡាំពិក ជាសមាជិកគណៈកម្មាធិការអូឡាំពិកអន្តរជាតិ "IOC" សមាជិកក្រុមប្រឹក្សាអូឡាំពិកអាស៊ី "OCA" និងសមាជិកសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ "SEAGF" មានបេសកកម្មចម្បងគឺថែរក្សា ការពារ អភិវឌ្ឍស្វ័យភាពចលនាអូឡាំពិក បណ្តុះបណ្តាលរដ្ឋបាលកីឡា គ្រូបង្វឹកជំនាញ ផ្សព្វផ្សាយអប់រំអូឡាំពិក បំផុសចលនាកីឡាដើម្បីទាំងអស់គ្នា "Sport For All" និងដឹកនាំប្រតិភូ អត្តពលិកចូលរួមប្រកួតពហុកីឡា "Games" ព្រមទាំងសហការដឹកនាំគ្រប់គ្រងរៀបចំការប្រកួតជាពហុកីឡា"Games" ក្នុងប្រទេសថ្នាក់ជាតិ អន្តរជាតិជាមួយរដ្ឋអំណាចកីឡានិងសហព័ន្ធកីឡាជាតិ។
- សហព័ន្ធកីឡា សាកលវិទ្យាល័យសិស្សនិស្សិតត្រូវពង្រឹងការគ្រប់គ្រងនិងពង្រីកសកម្មភាពកីឡាសិស្សនិស្សិត ឱ្យមានទាំងសកម្មភាពហ្វឹកហាត់កីឡាជំនាញ ការប្រកួតអន្តរគ្រឹះស្ថានសិក្សា កីឡាជំនាញ ចូលរួមការប្រកួតកីឡាសិស្សនិស្សិតអន្តរជាតិគ្រប់កម្រិត ព្រមទាំងធ្វើសកម្មភាព លំហាត់អប់រំកាយ និងកីឡាក្នុងកម្មវិធីសិក្សាជាប្រចាំផងដែរ។ គ្រប់ការប្រកួតទាំងអស់ត្រូវប្រើប្រាស់មន្ត្រីបច្ចេកទេសនិងមន្ត្រីវិនិច្ឆ័យបច្ចេកទេសរបស់សហព័ន្ធកីឡាជាតិ។
- សហព័ន្ធកីឡាជាតិ ដែលជាអង្គការសង្គមជំនាញកីឡា ត្រូវលើកកម្ពស់សមត្ថភាពមន្ត្រីជំនាញ ដូចជា គ្រូបង្វឹក អាជ្ញាកណ្តាល ចៅក្រម និងមន្ត្រីបច្ចេកទេសឱ្យមានស្តង់ដាគុណវុឌ្ឍិកីឡាអន្តរជាតិ។
- សហព័ន្ធកីឡាជាតិ ត្រូវមានផែនការអភិវឌ្ឍសមាគមកីឡា ក្លឹបកីឡា និងកីឡាករសម្រាប់ប្រភេទកីឡារបស់ខ្លួនឱ្យឈានទៅរកគុណវុឌ្ឍិបច្ចេកទេសកីឡានិងគុណផលកីឡាអន្តរជាតិថ្នាក់តំបន់ ទ្វីប និងពិភពលោក។
- សហព័ន្ធកីឡាជាតិ មានបេសកកម្មអភិវឌ្ឍកីឡាជំនាញរបស់ខ្លួន ដោយគោរពតាមគោលការណ៍ច្បាប់ល្បែងនិងបទបញ្ជាការប្រកួតរបស់សហព័ន្ធអន្តរជាតិប្រចាំប្រភេទកីឡារបស់ខ្លួន។ សហព័ន្ធកីឡាជាតិជាអ្នកសម្រេចវិនិច្ឆ័យលើលក្ខខណ្ឌបច្ចេកទេសគ្រប់កម្រិត ជ្រើសរើសកីឡាករ គ្រូបង្វឹក និងមន្ត្រីបច្ចេកទេសការប្រកួតថ្នាក់ជាតិ អន្តរជាតិនៅគ្រប់កម្រិត។

- សហព័ន្ធកីឡាជាតិត្រូវលើកទឹកចិត្តឲ្យមន្ត្រីជំនាញកីឡារបស់ខ្លួនដែលបានចូលនិវត្តន៍ជួយការងារប្រឹក្សាយោបល់លើជំនាញ ឬដឹកនាំការងារកីឡាមួយចំនួនទៅតាមលទ្ធភាព និងសមត្ថភាពដែលអាច ទទួលយកបាន។
- គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា (National Paralympic Committee of Cambodia) និងគណៈកម្មាធិការជាតិសេ្ប៉សា្យល់អូឡាំពិកកម្ពុជា (National Special Olympic Committee of Cambodia) ត្រូវធ្វើការពង្រឹងគ្រប់គ្រង និងធ្វើផែនការអភិវឌ្ឍ និងផែនការសកម្មភាព ដើម្បីអប់រំបណ្តុះបណ្តាលបង្កើនបញ្ញា ស្មារតីជនពិការរាងកាយ និងពិការស្មារតីតាមរយៈសកម្មភាពកីឡា។ បំផុសការចូលរួមរបស់ជនពិការរាងកាយ ដោយជំរុញទឹកចិត្តតាមស្មារតី “ខ្ញុំអាចធ្វើបាន - Yes, I can do” និងជនពិការបញ្ញា ស្មារតី “ខ្ញុំឃើញ ខ្ញុំអាចធ្វើបាន - I see I can do” ។ រាល់សកម្មភាពកីឡាត្រូវបានលើកទឹកចិត្ត និងផ្តល់ទីលានហ្វឹកហាត់ ដោយអាជ្ញាធរកីឡា និងត្រូវសហការជាមួយសហព័ន្ធកីឡាជាតិ ដើម្បីជួយបច្ចេកទេស ទាំងការហ្វឹកហាត់ ទាំងការប្រកួត។
- ក្នុងយុទ្ធសាស្ត្រគាំទ្រផែនការមេនេះផងដែរ សូមរាជរដ្ឋាភិបាលដាក់ចេញនូវគោលនយោបាយ “សាមគ្គីអូឡាំពិក ស្ថាប័ន អង្គការ ក្រុមហ៊ុនមួយទ្រទ្រង់កីឡាមួយប្រភេទ”។

## VIII. **សេចក្តីសន្និដ្ឋាន**

កត្តាជោគជ័យនៃការអនុវត្តផែនការមេឆ្ពោះទៅការធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games) លើកទី៣២ ឆ្នាំ២០២៣ គឺត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការអនុវត្តទាំងប្រជាពលរដ្ឋ សិស្សានុសិស្ស កម្លាំងប្រដាប់អាវុធ វិស័យឯកជន និងអង្គការកីឡាជំនាញ។ ត្រូវធានាឲ្យមានមូលដ្ឋានឧបករណ៍សម្ភារៈ ហេដ្ឋារចនាសម្ព័ន្ធកីឡាគ្រប់គ្រាន់តាមស្តង់ដារបច្ចេកទេស និងថវិកាទ្រទ្រង់សកម្មភាពគ្រប់គ្រាន់ប្រកបដោយចីរភាព តម្លាភាព គណនីយភាព និងសុចរិតភាព។ ត្រូវធ្វើឲ្យវិស័យកីឡា ក្លាយជាធុរកិច្ចកីឡា “Sport Business” ជាឧស្សាហកម្មកីឡា “Sport Industry” និងជាផលិតផលទេសចរណ៍ដ៏សំខាន់មួយតាមរយៈព្រឹត្តិការណ៍កីឡាទេសចរណ៍ ទើបអាចទាក់ទាញការគាំទ្រពីគ្រប់មជ្ឈដ្ឋាន និងអាចប្រមែប្រមូលមូលនិធិ ជួយសកម្មភាពអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា និងកីឡាជំនាញកម្រិតខ្ពស់បាន។

ពិសេស លើកគុណតម្លៃកីឡាឲ្យមានប្រជាប្រិយភាពក្នុងសង្គម និងអប់រំការយល់ដឹងពីប្រសិទ្ធភាព អត្ថប្រយោជន៍នៃកីឡា ដែលជាឱសថធម្មជាតិដ៏សក្តិសិទ្ធសម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋគ្រប់ៗរូប។ ផែនការមេឆ្ពោះទៅការធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games) លើកទី៣២ ឆ្នាំ២០២៣ ត្រូវស្ថិតក្រោមការគ្រប់គ្រង ត្រួតពិនិត្យ អនុវត្ត និងវាយតម្លៃ យ៉ាងម៉ត់ចត់ និងជាប្រចាំពីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឆ្ពោះទៅរកមហាកិត្តិយសជាតិក្នុងការរៀបចំធ្វើម្ចាស់ផ្ទះការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games) លើកទី៣២ ឆ្នាំ ២០២៣ នៅព្រះរាជាណាចក្រកម្ពុជា។

## ឧបសម្ព័ន្ធនៃផែនការមេឆ្ពោះទៅការធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)លើកទី៣២ ឆ្នាំ២០២៣(២០១៦–២០២៣)

## រចនាសម្ព័ន្ធគណៈកម្មាធិការរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)លើកទី៣២ ឆ្នាំ២០២៣ នៅកម្ពុជា

**ប្រធាន**
គណៈកម្មាធិការរៀបចំព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍(SEA Games)
(ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ)

- **អនុប្រធាន** (រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា)
- **អនុប្រធានអចិន្ត្រៃយ៍** (ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា)
- **អនុប្រធាន** (រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)
- **អនុប្រធាន** (អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ)

"CEO" នាយកប្រតិបត្តិ

គណៈកម្មាធិការទំនាក់ទំនងនិងសេវាកម្ម
NOCs Relations and Services

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| អនុគណៈពិធីបើក/បិទ | មជ្ឈមណ្ឌលសារព័ត៌មាន | អនុគណៈទីផ្សារ និងចលនូបត្ថម្ភ | អនុគណៈសន្តិសុខនិងសណ្តាប់ធ្នាប់ | អនុគណៈស្នាក់នៅ និង ម្ហូបចុក | អនុគណៈ Games IT | អនុគណៈពិធីការ | អនុគណៈកីឡា និង បទប្បញ្ញត្តិ | អនុគណៈដឹកជញ្ជូន និងផ្គត់ផ្គង់ | អនុគណៈទីលានប្រកួត | អនុគណៈវប្បធម៌ បរិស្ថាន និង អប់រំកីឡា | អនុគណៈហិរញ្ញវត្ថុ និងផ្គត់ផ្គង់ | អនុគណៈអ្នកស្ម័គ្រចិត្ត | អនុគណៈវេជ្ជសាស្ត្រកីឡា និង Doping |
| Sub-Com Opening/ Closing | Sub-Com International Broadcasting Center | Sub-Com Marketing & Sponsorship | Sub-Com Security and Safety | Sub-Com Accommodation and Food | Sub-Com Games IT | Sub-Com Protocol | Sub-Com Sport and Rule | Sub-Com Transportation and Logistics | Sub-Com Sport Venue | Sub-Com Culture, Environment & Education | Sub-Com Finance | Sub-Com Volunteer | Sub-Com Sport Medicine Doping |

# សទ្ទានុក្រម

១. Southeast Asia Peninsular Games (SEAP Games) : កីឡាជ្រោយអាស៊ីអាគ្នេយ៍។

២. Southeast Asia Games (SEA Games) : កីឡាអាស៊ីអាគ្នេយ៍។

៣. Southeast Asia Games Federation (SEAGF) : សហព័ន្ធកីឡាអាស៊ីអាគ្នេយ៍។

៤. International Olympic Committee (IOC) : គណៈកម្មាធិការអូឡាំពិកអន្តរជាតិ។

៥. Olympic Council of Asia (OCA) : ក្រុមប្រឹក្សាអូឡាំពិកអាស៊ី។

៦. Indoor Stadium : អាគារកីឡាក្នុងសាល។

៧. Aquatics : កីឡាទឹកក្នុងអាង។

៨. International Federations (IFs) : សហព័ន្ធកីឡាអន្តរជាតិ។

៩. Velodrome : ទីលានប្រណាំងកង់ជារង្វង់។

១០. Mountain Bike (MTB) : ប្រណាំងកង់លើភ្នំ។

១១. Sport for All : កីឡាដើម្បីទាំងអស់គ្នា ជាសកម្មភាពកីឡាមហាជនមិនសំដៅដល់កម្រិតបច្ចេកទេស។

១២. Fair Play: ជាគោលការណ៍លេងដោយយុត្តិធម៌ក្នុងការប្រកួតកីឡាគ្រប់កម្រិត។

១៣. Cambodia SEA Games Organizing Committee (CAMGOC) : គណៈកម្មាធិការរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍។

១៤. Brazil, Russia, India, China, South Africa (BRICS) : ជាក្រុមប្រទេសមានសេដ្ឋកិច្ចជឿនលឿនរីកលូតលាស់ទាំងប្រាំលើពិភពលោក។

១៥. Clean and Green Sport : កីឡាស្អាតនិងបៃតង សំដៅដល់ភាពស្អាតស្អំលើកីឡាគឺគោរពគោលការណ៍Fair Playលេងដោយយុត្តិធម៌និងបៃតងក្នុងកីឡា។

១៦. National Paralympic Committee of Cambodia: គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជាដឹកនាំគ្រប់គ្រងចលនាពិការរាងកាយ។

១៧. National Special Olympic Committee of Cambodia: គណៈកម្មាធិការជាតិស្ប៉េស្យាល់អូឡាំពិកកម្ពុជា ដឹកនាំគ្រប់គ្រងចលនាកីឡាជនខ្សោយសតិបញ្ញា ឬជនពិការបញ្ញាស្មារតី។

១៨. Games-IT សំដៅដល់ការប្រើប្រាស់បច្ចេកវិទ្យាក្នុងប្រព័ន្ធបច្ចេកទេសប្រកួត។

១៩. AD Card សំដៅដល់បណ្ណសម្គាល់ខ្លួនកីឡាករ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៧៣ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការប្រមូលពន្ធប្រថាប់ត្រា

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា
- បានឃើញព្រះរាជក្រមលេខ ១១.នស.៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សេចក្តីសម្រេចលេខ ០៤ សសរ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និងរវាងយាយ-តាបង្កើតនិងចៅបង្កើត
- សេចក្តីសម្រេចលេខ ២២ សសរ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ
- លិខិតលេខ ១៣៤ សជណ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីវិធានការដោះស្រាយក្នុងការអនុវត្តប្រមូលពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ចំពោះអចលនទ្រព្យដែលបានចុះបញ្ជី និងពុំបានចុះបញ្ជី
- លិខិតលេខ ១៩៧ សជណ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំគោលការណ៍បន្ថែមលើការអនុវត្តប្រមូលពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និងរវាងយាយ-តាបង្កើតនិងចៅបង្កើត
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធប្រថាប់ត្រា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92.Sangkat Wat Phnom . Khan Daun Penh. Phnom Penh. COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣ ៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងកំណត់បែបបទ និងនីតិវិធីប្រមូលពន្ធប្រថាប់ត្រារបស់រដ្ឋបាលសារពើពន្ធ ស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ សេចក្តីសម្រេចលេខ ០៤ សសរ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៦ និងសេចក្តីសម្រេចលេខ ២២ សសរ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងការគ្រប់គ្រងប្រមូលពន្ធ និងបង់ចូលក្នុងគណនីទោលនៃរតនាគារជាតិ ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការអភិវឌ្ឍមូលដ្ឋាន។

**ប្រការ ២.-**

ផ្អែកតាមជំពូកទី៣ ផ្នែកទី១ ដែលចែងពីបទប្បញ្ញត្តិមួយចំនួនស្តីពីពន្ធប្រថាប់ត្រា នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ពន្ធប្រថាប់ត្រាត្រូវបានប្រមូលចំពោះ ÷

- ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន និងការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ
- ការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន
- កិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ
- លិខិតមានលក្ខណៈគតិយុត្ត ជាអាទិ៍ លិខិតស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន។

**ប្រការ ៣.-**

ពន្ធប្រថាប់ត្រាត្រូវប្រមូលពី ÷

- អ្នកទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬមធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ
- អ្នកទទួលសិទ្ធិកាន់កាប់ភាគហ៊ុន
- អ្នកទទួលចុះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ
- អ្នកទទួលសិទ្ធិលើលិខិតមានលក្ខណៈគតិយុត្ត។

**ប្រការ ៤.-**

សម្រាប់គោលដៅនៃប្រកាសនេះ ÷

១. ពាក្យ "**ញាតិ**" សំដៅដល់ ÷
   - រវាងឪពុកម្តាយបង្កើត និងកូនបង្កើត
   - រវាងប្តី និងប្រពន្ធ
   - រវាងយាយតាបង្កើត និងចៅបង្កើត
   - រវាងបងប្អូនបង្កើត និងបងប្អូនបង្កើត
   - រវាងឪពុកម្តាយក្មេក និងកូនប្រសារ។

២. ពាក្យ "**តម្លៃចុះកិច្ចសន្យា**" សំដៅដល់តម្លៃលើកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ។

៣. ពាក្យ "**តម្លៃភាគហ៊ុន**" សំដៅដល់តម្លៃនៃការផ្ទេរភាគហ៊ុន ផ្អែកតាមតម្លៃទីផ្សារ។

៤. ពាក្យ "**ថវិការដ្ឋ**" សំដៅដល់ថវិកាជាតិ ឬថវិកាថ្នាក់ក្រោមជាតិ ដែលមានចែងនៅក្នុងមាតិកាថវិកាប្រចាំឆ្នាំនីមួយៗ។

៥. ពាក្យ "**ទំនិញ ឬសេវា**" សំដៅដល់ទំនិញ សំណង់ ឬសេវា។

៦. ពាក្យ "**ប្រទានកម្ម**" សំដៅដល់ការផ្ទេរអចលនទ្រព្យពីមនុស្សរស់ទៅឱ្យញាតិដោយមិនយកថ្លៃ។

៧. ពាក្យ "**ប្រធានសក្តិ**" សំដៅដល់បាតុភូត ឬជាព្រឹត្តិការណ៍កើតឡើងដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាន និងមិនអាចជំនះបាន ដូចជា គ្រោះធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី) សង្គ្រាម កុប្បកម្ម អគ្គិភ័យ ឬគ្រោះមហន្តរាយជាយថាហេតុ។

៨. ពាក្យ "**ភាគហ៊ុន**" សំដៅដល់ចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុន ឬផលប្រយោជន៍ ឬលក់អាជីវកម្មរបស់ក្រុមហ៊ុននីតិបុគ្គល ក្រុមអាជីវកម្ម និងសហគ្រាសឯកបុគ្គល ដែលបានចុះបញ្ជី ឬមិនបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។

៩. ពាក្យ "**មធ្យោបាយដឹកជញ្ជូនឬយានយន្ត**" សំដៅដល់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដូចជា រថយន្ត ទូក កាណូត កប៉ាល់ សាឡង់ ។ល។

១០. ពាក្យ "**លិខិតមានលក្ខណៈគតិយុត្ត**" សំដៅដល់លិខិតមានលក្ខណៈគតិយុត្តស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការពិនិត្យក្រុមហ៊ុន ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។

១១. ពាក្យ "**សន្តតិកម្ម**" សំដៅដល់ការផ្ទេរអចលនទ្រព្យពីមនុស្សស្លាប់ទៅឱ្យញាតិ តាមរយៈ ÷

- បណ្តាំជាលាយលក្ខណ៍អក្សរ ករណីគ្មានទំនាស់ ឬ
- បញ្ជាក់លើលិខិតយថាភូត ករណីគ្មានទំនាស់ ឬ
- សាលក្រម ឬសាលដីកាតុលាការ ករណីមានទំនាស់។

១២. ពាក្យ "**អចលនទ្រព្យ**" សំដៅដល់ដី ផ្ទះ អគារ និងសំណង់ផ្សេងៗ ទោះបីបានចុះបញ្ជី ឬមិនបានចុះបញ្ជី ដោយរដ្ឋបាលសុរិយោដី។

**ប្រការ ៥.-**

**ក. ការលើកលែងពន្ធ**

ពន្ធប្រថាប់ត្រា ត្រូវបានលើកលែងដូចខាងក្រោម ÷

១. ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល សម្រាប់ជាប្រយោជន៍សេដ្ឋកិច្ច ឬសង្គមកិច្ច ពីដីឯកជនរបស់រដ្ឋដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅដ្ឋាន ឬ/និងធ្វើកសិឧស្សាហកម្ម ឬកសិកម្មជាលក្ខណៈគ្រួសារ។

២. ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ក្នុងរង្វង់ញាតិ ÷

- ការធ្វើសន្តតិកម្ម រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និងរវាងយាយ-តាបង្កើត និងចៅបង្កើត
- ការធ្វើប្រទានកម្ម រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និងរវាងយាយ-តាបង្កើត និងចៅបង្កើត សម្រាប់តែការផ្ទេរលើកទីមួយប៉ុណ្ណោះ។

៣. ការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ។

ការផ្ទេរ និងការលើកលែងប្រាក់ពន្ធប្រថាប់ត្រាចំពោះកថាខណ្ឌ២ និងកថាខណ្ឌ៣ នៃប្រការនេះ មិនមានអនុភាពប្រតិសកម្មចំពោះប្រាក់ពន្ធដែលបានបង់រួច និងការផ្ទេរមុនការចេញប្រកាសនេះទេ។

៤. ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្ត ដែលត្រូវកត់ត្រាចុះក្នុងបញ្ជីសារពើភ័ណ្ឌរបស់ស្ថាប័ននានា នៃព្រះរាជាណាចក្រកម្ពុជា។

៥. ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្តរបស់បេសកកម្មការទូត ឬកុងស៊ុលបរទេស ឬអង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

៦. ការទិញមធ្យោបាយដឹកជញ្ជូនឬយានយន្ត ធ្វើជាទំនិញដើម្បីលក់វិញរបស់សហគ្រាសនានា ដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងបានបង់ពន្ធ-អាករប្រចាំខែ និងប្រចាំឆ្នាំ។ ដោយឡែក ការទិញមធ្យោបាយដឹកជញ្ជូនឬយានយន្តដែលបានចុះបញ្ជីនៅស្ថាប័នសាធារណការនិងដឹកជញ្ជូន មិនត្រូវបានលើកលែងពន្ធប្រថាប់ត្រានេះទេ។

៧. អ្នកវិនិយោគមូលបត្រដែលទទួលសិទ្ធិកាន់កាប់ភាគហ៊ុនតាមរយៈការជួញដូរមូលបត្រក្នុងទីផ្សារដំបូង ឬក្នុងទីផ្សារបន្ទាប់។

ការផ្ទេរភាគហ៊ុន ការទទួលសិទ្ធិកាន់កាប់ភាគហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការកែប្រែរចនាសម្ព័ន្ធភាគហ៊ុនិក ដូចជា ការបំបែកភាគហ៊ុន (Share split) របស់ក្រុមហ៊ុនដែលមានបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្រុមហ៊ុនដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈនៅក្នុងទីផ្សារដំបូង ឬនៅក្នុងទីផ្សារបន្ទាប់ ឬក្រុមហ៊ុនដែលធ្វើអាជីវកម្មពាក់ព័ន្ធក្នុងវិស័យមូលបត្រ ទោះបីតម្រូវឱ្យមានការកែប្រែលក្ខន្តិកៈក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មក៏ដោយ ការលើកលែងពន្ធប្រថាប់ត្រានេះត្រូវមានលិខិតបញ្ជាក់ពីគណៈកម្មការមូលបត្រកម្ពុជា។

ករណីក្រុមហ៊ុនមិនអាចធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈបាន ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អ្នកទទួលសិទ្ធិកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុននេះត្រូវជាប់ពន្ធប្រថាប់ត្រា និងត្រូវទូទាត់ពន្ធប្រថាប់ត្រានៃការផ្ទេរភាគហ៊ុនកន្លងមក ដោយអនុលោមតាមប្រកាសនេះ លើកលែងតែមានលិខិតបញ្ជាក់ដោយឡែកពីគណៈកម្មការមូលបត្រកម្ពុជា ដោយផ្អែកលើមូលហេតុសមស្រប ដូចជា ករណីប្រធានសក្តិជាដើម។

**ខ. ការអនុគ្រោះពន្ធ**

ពន្ធប្រថាប់ត្រាត្រូវបានអនុគ្រោះ ដូចខាងក្រោម ÷

- ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ រវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត និងរវាងឪពុក-ម្តាយក្មេកនិងកូនប្រសារ ត្រូវបានអនុញ្ញាតឱ្យដកចេញនូវមូលដ្ឋានគិតពន្ធប្រថាប់ត្រា ២០០ ០០០ ០០០ (ពីររយលាន) រៀល ចំពោះការធ្វើសន្តតិកម្ម និង ១០០ ០០០ ០០០ (មួយរយលាន) រៀល ចំពោះការធ្វើប្រទានកម្ម
- ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដដែល ជាប្រទានកម្មក្នុងរង្វង់ញាតិ រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និងរវាងយាយ-តាបង្កើតនិងចៅបង្កើត ចាប់ពីលើកទី២តទៅ ត្រូវបានអនុញ្ញាតឱ្យដកចេញនូវមូលដ្ឋានគិតពន្ធប្រថាប់ត្រា ១០០ ០០០ ០០០ (មួយរយលាន) រៀល។

ការលើកលែង ឬការអនុគ្រោះពន្ធប្រថាប់ត្រាក្នុងរង្វង់ញាតិខាងលើ ត្រូវមានឯកសារជាភ័ស្តុតាងបញ្ជាក់ទំនាក់ទំនងអំពីញាតិ ដូចជា សៀវភៅគ្រួសារ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និង/ឬឯកសារដទៃទៀត ដែលអាចបញ្ជាក់ទំនាក់ទំនងរវាងបុគ្គលមានចែងក្នុងកថាខណ្ឌ ១ នៃប្រការ ៤ នៃប្រកាសនេះ។

ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលត្រូវបានលើកលែងពន្ធ ឬការអនុគ្រោះពន្ធ មានប្រាក់ពន្ធស្មើ ០ (សូន្យ) រៀល ក៏ត្រូវអនុវត្តតាមនីតិវិធី និងបែបបទនៅរដ្ឋបាលសារពើពន្ធជាធរមាន ដើម្បីចុះបញ្ជី និងកត់ត្រាទិន្នន័យនូវរាល់ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យទាំងនោះ។ ដោយឡែក ចំពោះការលើកលែងពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ មិនតម្រូវឱ្យយកឯកសារមកបំពេញនីតិវិធីនៅរដ្ឋបាលសារពើពន្ធនោះទេ។

**ប្រការ ៦.-**

អត្រាពន្ធ និងការកំណត់ពន្ធប្រថាប់ត្រា មានដូចខាងក្រោម ÷

១. ៤% នៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យជាសំណង់ ឬ/និងដី ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន។

២. ៤% នៃតម្លៃមធ្យោបាយដឹកជញ្ជូនឬយានយន្ត ចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ។

៣. ០,១% នៃតម្លៃភាគហ៊ុន ចំពោះការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុន ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។

៤. ០,១% នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ។

៥. ១ ០០០ ០០០ (មួយលាន) រៀល ចំពោះលិខិតមានលក្ខណៈគតិយុត្ត ៣ប្រភេទគឺ លិខិតស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការបិទក្រុមហ៊ុន និងលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា (រួមទាំងលិខិតរំលាយក្រុមហ៊ុនបញ្ចូលគ្នារបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រសាធារណៈ ដូចមានចែងក្នុងកថាខណ្ឌនេះ)។

**ប្រការ ៧.-**

តម្លៃជាមូលដ្ឋានសម្រាប់គិតពន្ធប្រថាប់ត្រាត្រូវបានកំណត់ ដូចខាងក្រោម ÷

១. អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្ត ត្រូវគិតតាមតម្លៃទីផ្សារនាពេលផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់តម្លៃអចលនទ្រព្យ និងតម្លៃមធ្យោបាយដឹកជញ្ជូនឬយានយន្តសម្រាប់ធ្វើជាមូលដ្ឋានគិតពន្ធនេះ។

២. ភាគហ៊ុន ត្រូវគិតតាមតម្លៃទីផ្សារនាពេលប្រតិបត្តិការផ្ទេរភាគហ៊ុននោះកើតឡើង។

៣. កិច្ចសន្យា ត្រូវគិតតាមតម្លៃក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា។

៤. លិខិតមានលក្ខណៈគតិយុត្ត ត្រូវកំណត់ ១ ០០០ ០០០ (មួយលាន) រៀល ចំពោះលិខិតមានលក្ខណៈគតិយុត្តនីមួយៗ។

**ប្រការ ៨.-**

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធប្រថាប់ត្រា ឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេល ៣ខែ ÷

១. ចំពោះអចលនទ្រព្យដែលបានចុះបញ្ជី (មានប័ណ្ណកម្មសិទ្ធិ) បន្ទាប់ពីការសម្រេចនៃកំណត់បង្ហាញរបស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត និងអចលនទ្រព្យដែលមិនទាន់ចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) បន្ទាប់ពីមានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់ អភិបាលក្រុង ស្រុក ខណ្ឌ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ។

២. ចំពោះមធ្យោបាយដឹកជញ្ជូនឬយានយន្ត បន្ទាប់ពីថ្ងៃចុះហត្ថលេខារបស់អ្នកទទួលសិទ្ធិលើសំណុំឯកសារ "ពាក្យសុំផ្ទេរកម្មសិទ្ធិយានយន្ត" របស់មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី-ខេត្ត ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិ។

៣. ចំពោះភាគហ៊ុន បន្ទាប់ពីប្រតិបត្តិការផ្ទេរភាគហ៊ុនកើតឡើង ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរភាគហ៊ុន។

៤. ចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា បន្ទាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យា ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងកិច្ចសន្យានេះ។

៥. ចំពោះលិខិតមានលក្ខណៈគតិយុត្ត បន្ទាប់ពីការសម្រេចរបស់ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងលិខិតនេះ។

ចំពោះការផ្ទេរ ឬប្រតិបត្តិការទិញ លក់ ដូចខាងក្រោម ពុំចាំបាច់យកមកប្រថាប់ត្រានៅរដ្ឋបាលសារពើពន្ធនោះទេ ÷

- ការផ្ទេរ ឬការទទួលសិទ្ធិកាន់កាប់ភាគហ៊ុនពាក់ព័ន្ធនឹងវិស័យមូលបត្រ ដូចមានចែងក្នុងកថាខណ្ឌ ៧ នៃប្រការ ៥ នៃប្រកាសនេះ
- ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ ដូចមានចែងក្នុងកថាខណ្ឌ ៣ នៃប្រការ ៥ នៃប្រកាសនេះ
- ការទិញមធ្យោបាយដឹកជញ្ជូនឬយានយន្ត ធ្វើជាទំនិញដើម្បីលក់វិញរបស់សហគ្រាសនានា ដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងបានបង់ពន្ធ-អាករប្រចាំខែ និងប្រចាំឆ្នាំ ដូចមានចែងក្នុងកថាខណ្ឌ ៦ នៃប្រការ ៥ នៃប្រកាសនេះ។

**ប្រការ ៩.-**

១. អ្នកទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្ត អ្នកទទួលចុះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា អ្នកទទួលសិទ្ធិលើភាគហ៊ុន និងអ្នកទទួលសិទ្ធិលើលិខិតមានលក្ខណៈគតិយុត្តអនុលោមតាមប្រកាសនេះ ដែលមិនបានបង់ពន្ធប្រថាប់ត្រាទាន់ពេលវេលាកំណត់ដូចមានចែងក្នុងប្រការ ៨ ត្រូវពិន័យស្មើនឹងចំនួនប្រាក់ពន្ធប្រថាប់ត្រាដែលត្រូវបង់។

២. ប្រសិនបើម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់ថ្មីនោះ មិនបានបង់ពន្ធប្រថាប់ត្រាតាមច្បាប់នោះទេ ÷

- រដ្ឋបាលសុរិយោដី មិនអាចចេញវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យថ្មីនោះទេ
- អាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ (ថ្នាក់ឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ) មិនអាចមានសិទ្ធិផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនបានបង់ពន្ធប្រថាប់ត្រា ឬបង់ពន្ធប្រថាប់ត្រាក្រៅប្រព័ន្ធពន្ធដារនោះបានទេ ទោះជាអចលនទ្រព្យនោះបានចុះបញ្ជី ឬមិនបានចុះបញ្ជីក្តី ហើយត្រូវជំរុញនិងបញ្ជូនរាល់ករណីស្នើសុំផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យទាំងនោះឲ្យមកបង់ពន្ធប្រថាប់ត្រានៅរដ្ឋបាលសារពើពន្ធតាមច្បាប់ជាធរមាន
- ចំពោះការផ្ទេរកម្មសិទ្ធិលើមធ្យោបាយដឹកជញ្ជូន សម្រាប់រថយន្តគ្រប់ប្រភេទ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងលើស១៥០សេះ ស្ថាប័នសាធារណការ និងដឹកជញ្ជូន មិនអាចមានសិទ្ធិចេញប័ណ្ណសម្គាល់មធ្យោបាយដឹកជញ្ជូនឬយានយន្តថ្មីនោះដោយមិនបានបង់ពន្ធប្រថាប់ត្រានោះទេ លើកលែងតែការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ។

**ប្រការ ១០.-**

ប្រកាសលេខ ៧៣៥ សហវ.ប្រក.អពដ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការប្រមូលពន្ធប្រថាប់ត្រា ត្រូវទុកជានិរាករណ៍។

**ប្រការ ១១.-**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន ÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន **សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ប្រក

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរដ្ឋលេខាធិការប្រចាំការសម្រាប់ឆ្នាំ ២០១៦
## របស់ក្រសួងធនធានទឹក និងឧតុនិយម

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦
-បានឃើញអនុក្រឹត្យលេខ ៨៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
-បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
-បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
-បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ៍ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

-បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ

-បានឃើញប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលប្រការ ៤ ប្រការ ៥ ប្រការ ១៤ ប្រការ ១៦ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ

-យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងធនធានទឹក និងឧតុនិយម

## សម្រេច

**ប្រការ ១ ៖**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធីក្នុងជំពូក ៦០ (ការទិញ) និង ជំពូក ៦១ (សេវាកម្ម) នៅក្រសួងធនធានទឹក និងឧតុនិយម សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ ៥ ថ្មី នៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលប្រការ ៤ ប្រការ ៥ ប្រការ ១៤ ប្រការ ១៦ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២ ៖**

ចំនួនទឹកប្រាក់មួយជុំរង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ ៣ ៖**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ ៖**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋានហិរញ្ញវត្ថុរបស់ក្រសួងធនធានទឹក និងឧតុនិយម ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងធនធានទឹក និងឧតុនិយម ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**លឹម គានហោ**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមុខងារសាធារណៈ

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ៤

-រាជកិច្ច

-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

## តារាងឧបសម្ព័ន្ធផ្ទេរបុរេប្រទានថវិកាកម្មវិធីឆ្នាំ ២០១៦
## ក្រសួងធនធានទឹក និងឧតុនិយម

ឯកតា ៖ រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានផ្ទេរបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន ១ ជុំ បង្វិលផ្ទេរបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ ជុំ | ៦=៣/២ |
| | | | សរុបរួម | 50.333.200.000 | 4.426.200.000 | 1.370.800.000 | 3.055.400.000 | 342.700.000 | 30,97% |
| 60 | | | ការទិញ | 6.365.600.000 | 878.600.000 | 265.600.000 | 613.000.000 | 66.400.000 | 30,23% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 4.677.000.000 | 77.000.000 | 77.000.000 | 0 | 19.250.000 | 100,00% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់ សំអាត និងអនាម័យ | 17.000.000 | 17.000.000 | 17.000.000 | 0 | 4.250.000 | 100,00% |
| | | 60012 | សម្ភារៈផ្គត់ផ្គង់ សម្រាប់ថែទាំអាគារ ប្រាសាទ និងសំណង់ផ្សេងៗ | 15.000.000 | 15.000.000 | 15.000.000 | 0 | 3.750.000 | 100,00% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 40.000.000 | 40.000.000 | 40.000.000 | 0 | 10.000.000 | 100,00% |
| | | 60015 | ប្រេងឥន្ធនៈ និងប្រេងរំអិល | 4.600.000.000 | | | | | |
| | | 60018 | ផ្សេងៗ | 5.000.000 | 5.000.000 | 5.000.000 | 0 | 1.250.000 | 100,00% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 350.000.000 | 350.000.000 | 105.000.000 | 245.000.000 | 26.250.000 | 30,00% |
| | | 60021 | សម្ភារៈការិយាល័យ និងការបោះពុម្ព | 350.000.000 | 350.000.000 | 105.000.000 | 245.000.000 | 26.250.000 | 30,00% |
| | 6004 | | សំលៀកបំពាក់ និងការតុបតែង | 3.600.000 | 3.600.000 | 3.600.000 | 0 | 900.000 | 100,00% |
| | | 60042 | សំលៀកបំពាក់ការពារសុវត្ថិភាព | 1.000.000 | 1.000.000 | 1.000.000 | 0 | 250.000 | 100,00% |
| | | 60043 | មេដាយ ( គ្រឿងឥស្សរិយយស ) | 2.600.000 | 2.600.000 | 2.600.000 | 0 | 650.000 | 100,00% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 448.000.000 | 448.000.000 | 80.000.000 | 368.000.000 | 20.000.000 | 17,86% |
| | | 60051 | សម្ភារៈ និងបរិក្ខារបច្ចេកទេស | 250.000.000 | 250.000.000 | 50.000.000 | 200.000.000 | 12.500.000 | 20,00% |
| | | 60052 | សង្ហារឹម | 30.000.000 | 30.000.000 | 0 | 30.000.000 | 0 | 0,00% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 30.000.000 | 30.000.000 | 30.000.000 | 0 | 7.500.000 | 100,00% |
| | | 60054 | សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន | 138.000.000 | 138.000.000 | 0 | 138.000.000 | 0 | 0,00% |
| | 6006 | | ថាមពល និងទឹក | 887.000.000 | 0 | 0 | 0 | 0 | |
| | | 60061 | អគ្គិសនី | 832.000.000 | | | | | |
| | | 60062 | ទឹក | 55.000.000 | | | | | |
| 61 | | | សេវាខាងក្រៅ | 43.967.600.000 | 3.547.600.000 | 1.105.200.000 | 2.442.400.000 | 276.300.000 | 31,15% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានខ្ទាត់ធម្មតា | ឥណទាន ១ ជុំ បង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ ជុំ | ៦=៣/២ |
| | 6101 | | កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស | 10.000.000 | | | | | |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 30.000.000 | 30.000.000 | 30.000.000 | 0 | 7.500.000 | 100,00% |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុងនិងក្រៅប្រទេស | 400.000.000 | | | | | |
| | 6105 | | ការថែទាំ និងជួសជុល | 41.510.000.000 | 1.510.000.000 | 230.000.000 | 1.280.000.000 | 57.500.000 | 15,23% |
| | | 61052 | ការថែទាំ និងជួសជុលអាគារផ្សេងៗ និងប្រាសាទ | 500.000.000 | 500.000.000 | 0 | 500.000.000 | 0 | 0,00% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 70.000.000 | 70.000.000 | 70.000.000 | 0 | 17.500.000 | 100,00% |
| | | 61055 | ការថែទាំប្រព័ន្ធធារាសាស្ត្រ | 40.000.000.000 | | | | | |
| | | 61056 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | 60.000.000 | 60.000.000 | 30.000.000 | 30.000.000 | 7.500.000 | 50,00% |
| | | 61057 | ការថែទាំ និងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 80.000.000 | 80.000.000 | 80.000.000 | 0 | 20.000.000 | 100,00% |
| | | 61058 | ការថែទាំ និងជួសជុលផ្សេងៗ | 800.000.000 | 800.000.000 | 50.000.000 | 750.000.000 | 12.500.000 | 6,25% |
| | 6107 | | សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | 4.000.000 | 4.000.000 | 4.000.000 | 0 | 1.000.000 | |
| | | 61071 | សោហ៊ុយសិក្សាពិសោធន៍ | 4.000.000 | 4.000.000 | 4.000.000 | 0 | 1.000.000 | 100,00% |
| | 6110 | | ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ | 261.600.000 | 261.600.000 | 261.600.000 | 0 | 65.400.000 | 100,00% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 30.000.000 | 30.000.000 | 30.000.000 | 0 | 7.500.000 | 100,00% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 15.000.000 | 15.000.000 | 15.000.000 | 0 | 3.750.000 | 100,00% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 90.000.000 | 90.000.000 | 90.000.000 | 0 | 22.500.000 | 100,00% |
| | | 61104 | សោហ៊ុយពិធីបុណ្យ | 52.600.000 | 52.600.000 | 52.600.000 | 0 | 13.150.000 | 100,00% |
| | | 61105 | ចំណាយសម្រាប់វត្តអនុស្សាវរីយ៍នៅក្នុង និងក្រៅប្រទេស | 25.000.000 | 25.000.000 | 25.000.000 | 0 | 6.250.000 | 100,00% |
| | | 61106 | ចំណាយសម្រាប់ការការតាំងពិពណ៌នៅក្នុង និងក្រៅប្រទេស | 44.000.000 | 44.000.000 | 44.000.000 | 0 | 11.000.000 | 100,00% |
| | | 61107 | ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 5.000.000 | 5.000.000 | 5.000.000 | 0 | 1.250.000 | 100,00% |
| | 6111 | | ចំណាយលើការជាវសារព័ត៌មាន និងឯកសារ | 10.000.000 | 0 | 0 | 0 | 0 | |
| | | 61113 | ចំណាយលើការជាវសៀវភៅហិរញ្ញកិច្ច | 10.000.000 | | | | | |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 1.482.000.000 | 1.482.000.000 | 444.600.000 | 1.037.400.000 | 111.150.000 | 30,00% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 257.000.000 | 257.000.000 | 77.100.000 | 179.900.000 | 19.275.000 | 30,00% |
| | | 61122 | សោហ៊ុយបេសកកម្ម | 225.000.000 | 225.000.000 | 67.500.000 | 157.500.000 | 16.875.000 | 30,00% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 1.000.000.000 | 1.000.000.000 | 300.000.000 | 700.000.000 | 75.000.000 | 30,00% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 150.000.000 | 150.000.000 | 45.000.000 | 105.000.000 | 11.250.000 | |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 40.000.000 | 40.000.000 | 12.000.000 | 28.000.000 | 3.000.000 | 30,00% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន ១ ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ ជុំ | ៦=៣/២ |
| | | 61132 | សោហ៊ុយបេសកកម្ម | 50.000.000 | 50.000.000 | 15.000.000 | 35.000.000 | 3.750.000 | 30,00% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 60.000.000 | 60.000.000 | 18.000.000 | 42.000.000 | 4.500.000 | 30,00% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍ | 110.000.000 | 110.000.000 | 90.000.000 | 20.000.000 | 22.500.000 | 81,82% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 110.000.000 | 110.000.000 | 90.000.000 | 20.000.000 | 22.500.000 | 81,82% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី០៧ ខែ មីនា ឆ្នាំ ២០១៦
ជ. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង
មិញ បានសុវណ្ណអាធិប្បាសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦
ជ. អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
អ៊ុក សុវណ្ណារ៉ា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦
ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងជា
រដ្ឋទេយ្យករបុរេប្រទាន
មុយ មុនិន្ទ

បានឃើញ និងឯកភាព
ថ្ងៃទី០៧ ខែ មីនា ឆ្នាំ ២០១៦
រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦
រដ្ឋមន្ត្រី
ក្រសួងធនធានទឹក និងឧតុនិយម
លឹម គានហោ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០៦៤ ឧស.ករ.ប្រក-ចល

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៦

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ ផលិតម្សៅដំឡូងមី ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ របស់ក្រុមហ៊ុន ឌាន ដា បាយអូ-អេនើជី អ៊ិនវេសម៉ិន។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ឌាន ដា បាយអូ-អេនើជី អ៊ិនវេសម៉ិន (DIAN DA BIO-ENERGY INVESTMENT Co., Ltd.) តំណាងដោយ លោកស្រី DONG, XUYUN បង្កើតរោងចក្រ ផលិតម្សៅដំឡូងមី ដែលមានទីតាំងស្ថិតនៅ ភូមិកណ្តាល ឃុំឈើតុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ម្សៅមី | ១០៦១ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រផលិតម្សៅជំឡូងមី ឌាន ដា បាយអូ-អេនើជី អ៊ិនវេសមិន"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តពោធិ៍សាត់ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តពោធិ៍សាត់
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft

លេខ : ២១៧.....ឧស.អកក.ប្រក.ច.០៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០១៦

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន អ៊ិនធើណាស្យូណល ហ្វេសិន រ៉ូយ៉ាល់ ។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន អ៊ិនធើណាស្យូណល ហ្វេសិន រ៉ូយ៉ាល់ (INTERNATIONAL FASHION ROYAL CO., LTD.) តំណាងដោយ លោក **KIM JONG MIN** បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ សួនឧស្សាហកម្មកាណាឌីយ៉ា អគារលេខ៣៤ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ ៖** "រោងចក្រកាត់ដេរសម្លៀកបំពាក់ អ៊ិនធើណាស្យូណាល ហ្វេសិន រ៉ូយ៉ាល់"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសលេខ ១៨២ ឧរថ.កឧ.ប្រក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន អ៊ិនធើណាស្យូណល ហ្វេសិន រ៉ូយ៉ាល់ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលារាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ